ក្រសួងអប់រំ យុវជន និងកីឡា
វិទ្យាស្ថានជាតិអប់រំ

ADB







# ឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃការរៀន និងបង្រៀន ស្ទែមនៅមធ្យមសិក្សាទុតិយភូមិ

ខែមិថុនា ឆ្នាំ២០២៣

គម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទីII (USESDP-II)

# មាតិកា


បញ្ជីពាក្យកាត់ ........ 1

សន្ទានុក្រម ........ 1

សេចក្តីផ្តើម ........ 3

តើអ្វីទៅជាកញ្ចប់ឧបករណ៍ពិនិត្យតាមដាន និងវង្វាយតម្លៃ? ........ 3

ទិដ្ឋភាពទូទៅនៃឧបករណ៍ពិនិត្យតាមដាន និងវង្វាយតម្លៃស្ទែម ........ 4

តារាងបង្ហាញពីសកម្មភាពការពិនិត្យតាមដាន និងវាយតម្លៃស្ទែមនៅសាលារៀន ........ 5

ទិដ្ឋភាពទូទៅនៃដំណើរការប្រើប្រាស់ឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃស្ទែមសម្រាប់ការអភិវឌ្ឍគុណវុឌ្ឍិគណៈគ្រប់គ្រងស្ទែម គ្រូបង្រៀនស្ទែម និងសិស្ស ........ 6

ទិដ្ឋភាពទូទៅនៃគោលបំណងឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃស្ទែមនីមួយៗ ........ 7

អំពីឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃស្ទែម ........ 9

ក. គណៈគ្រប់គ្រងស្ទែម ........ 9

ទិដ្ឋភាពទូទៅនៃសកម្មភាពពិនិត្យតាមដាន និងការវាយតម្លៃគណៈគ្រប់គ្រងស្ទែម ........ 9

សេចក្តីលម្អិតពីការពិនិត្យតាមដាន និងវាយតម្លៃកម្រិតគណៈគ្រប់គ្រងស្ទែម ........ 11

1. ឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាគណៈគ្រប់គ្រងស្ទែម (ឧបសម្ព័ន្ធ ក) ........ 11
2. ការធ្វើស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រាគណៈគ្រប់គ្រងស្ទែម (ឧបសម្ព័ន្ធ ខ) ........ 14
3. ស្វ័យវង្វាយតម្លៃលើវឌ្ឍនភាពគណៈគ្រប់គ្រងស្ទែម (ឧបសម្ព័ន្ធ ខ) ........ 17
4. ឧបករណ៍សង្កេតលម្អិតលើការបង្រៀនស្ទែម (ឧបសម្ព័ន្ធ គ) ........ 20
5. ការសង្កេតរហ័សលើការបង្រៀនស្ទែម (ឧបសម្ព័ន្ធ ឃ) ........ 22
6. ផែនការសកម្មភាពគណៈគ្រប់គ្រងស្ទែមកម្រិតសាលារៀន (ឧបសម្ព័ន្ធ ង) ........ 25
7. ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំកម្រិតបុគ្គល (ឧបសម្ព័ន្ធ ច) ........ 27

ខ.គ្រូបង្រៀនស្ទែម ........ 35

ទិដ្ឋភាពទូទៅនៃសកម្មភាពពិនិត្យតាមដាន និងវាយតម្លៃកគ្រូបង្រៀន ........ 35

សេចក្តីលម្អិតលើសកម្មភាពពិនិត្យតាមដាន និងវាយតម្លៃគ្រូបង្រៀនស្ទែម ........ 35

1. ឧបករណ៍វង្វាយតម្លៃទិន្នន័យដើមគ្រាគ្រូបង្រៀនស្ទែម(ឧបសម្ព័ន្ធ ឆ) ........ 35
2. ឧបករណ៍ស្វ័យវង្វាយតម្លៃវឌ្ឍនភាពគ្រូបង្រៀនស្ទែម(ឧបសម្ព័ន្ធ ឆ) ........ 38
3. ឧបករណ៍សង្កេតលម្អិតលើការបង្រៀនស្ទែម(ឧបសម្ព័ន្ធ គ) ........ 41
4. ទម្រង់ផែនកាសកម្មភាពគណៈគ្រប់គ្រងស្ទែមកម្រិតសាលារៀន (ឧបសម្ព័ន្ធ ង) ........ 41

គ.សិស្សសិក្សាមុខវិជ្ជាស្ទែម ..... 42

ទិដ្ឋភាពទូទៅនៃសកម្មភាពពិនិត្យតាមដាន និងវាយតម្លៃសិស្ស..... 42

សេចក្តីលម្អិតអំពីសកម្មភាពពិនិត្យតាមដាន និងវាយតម្លៃនៅកម្រិតសិស្ស ..... 42

1. ទិន្នន័យដើមគ្រានៃការស្ទង់មតិស្តីពីការពេញចិត្តរបស់សិស្ស ( ឧបសម្ព័ន្ធ ជ )..... 42

2. ឧបករណ៍ស្ទង់មតិវឌ្ឍនភាពស្តីការពេញចិត្តរបស់សិស្សលើមុខវិជ្ជាស្ទែម ( ឧបសម្ព័ន្ធជ ) ..... 46

របាយការណ៍ពិនិត្យឡើងវិញលើការផ្តល់មតិកែលម្អ..... 48

ឯកសារយោង ..... 49

ឧបសម្ព័ន្ធ ..... 50

ឧបសម្ព័ន្ធ កៈ ឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាគណៈគ្រប់គ្រងស្ទែម ..... 51

ឧបសម្ព័ន្ធ ខៈ ឧបករណ៍ស្វ័យវាយតម្លៃទិន្នន័យដើមគ្រា និងស្វ័យវាយតម្លៃវឌ្ឍនភាពគណៈគ្រប់គ្រងស្ទែម ..... 55

ឧបសម្ព័ន្ធ គៈ ឧបករណ៍សង្កេតលម្អិតលើការបង្រៀនស្ទែម..... 63

ឧបសម្ព័ន្ធ ឃៈ ឧបករណ៍សង្កេតរហ័សលើការបង្រៀនស្ទែម..... 68

ឧបសម្ព័ន្ធ ងៈ ទម្រង់ផែនការសកម្មភាពគណៈគ្រប់គ្រងស្ទែមកម្រិតសាលារៀន ..... 72

ឧបសម្ព័ន្ធ ច ៈ ទម្រង់ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំកម្រិតបុគ្គល ..... 77

ឧបសម្ព័ន្ធ ឆៈ ឧបករណ៍វាយតម្លៃទិន្នន័យដើមគ្រា និងស្វ័យវាយតម្លៃវឌ្ឍនភាពគ្រូបង្រៀនស្ទែម ..... 81

ឧបសម្ព័ន្ធ ជៈ ឧបករណ៍ស្ទង់មតិទិន្នន័យដើមគ្រា និងវឌ្ឍនភាពស្តីពីការពេញចិត្តរបស់សិស្សលើមុខវិជ្ជាស្ទែម ..... 89

ឧបសម្ព័ន្ធ ឈៈ របាយការណ៍ពិនិត្យតាមដាននិងវាយតម្លៃស្ទែមសម្រាប់ផ្តល់មតិកែលម្អដល់សាលារៀន..... 96

## បញ្ជីពាក្យកាត់

| | |
|---|---|
| វ.ជ.អ | វិទ្យាស្ថានជាតិអប់រំ |
| ស.ស.គ | គណៈគ្រប់គ្រងស្វែម |
| អ.យ.ក | ក្រសួងអប់រំ យុវជន និងកីឡា |

## សន្ទានុក្រម

| | |
|---|---|
| ផែនការសកម្មភាព | សកម្មភាពដែលមានកំណត់គោលដៅនៃការកែលម្អច្បាស់លាស់ ដោយមានការពិនិត្យតាមដានឡើងវិញ |
| ការកែលម្អបន្ថែម | ចំណុចដែលត្រូវអភិវឌ្ឍបន្ថែមរួមមាន ជំនាញ ចំណេះដឹង ឬសមត្ថភាពរបស់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀនជុំវិញការដឹកនាំ ការគ្រប់គ្រង និងការបង្រៀន។ |
| ការវាយតម្លៃ | វិធីសាស្ត្រក្នុងការវាយតម្លៃ វាស់វែង និងចងក្រងឯកសារអំពីការត្រៀមខ្លួនក្នុងការសិក្សា វឌ្ឍនភាពនៃការសិក្សា ការទទួលបានជំនាញ ឬតម្រូវការអប់រំរបស់គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងសិស្ស។ |
| គ្រូប្រឹក្សាយោបល់ | អ្នកឯកទេសផ្នែកស្វែមដែលជួយកំណត់សេចក្តីត្រូវការ និងជួយប្រឹក្សាយោបល់លើការបង្កើតផែនការសកម្មភាពកម្រិតសាលារៀន និងផែនការសម្រាប់គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន និងជាគ្រូប្រឹក្សាយោបល់លើបញ្ហាបគរុកោសល្យបង្រៀន ឬសកម្មភាពនានាជុំវិញការពិសោធន៍ និងការការសង្កេតការបង្រៀនជាដើម។ |
| គ្រូណែនាំ | អ្នកណែនាំដើរតួនាទីជាមគ្គុទ្ទេស អ្នកទីប្រឹក្សា ឬគ្រូបង្រៀនដើម្បីផ្តល់ការអភិវឌ្ឍសមត្ថភាពបន្ថែម។ |
| ការពិនិត្យតាមដាន | វិធីសាស្ត្រដែលប្រើដើម្បីពិនិត្យមើលសកម្មភាពជាប្រចាំដែលជួយធានាគុណភាពនៃការអប់រំស្វែមនៅសាលារៀន។ |
| សាលារៀនបណ្តាញ | បណ្តាសាលារៀនដែលទទួលបានការគាំទ្រ និងការអនុវត្តចេញពីក្នុងគម្រោង<br>អភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី2( USESDPII )។ |

| | |
|---|---|
| **ការវាយតម្លៃហានិភ័យ** | ផ្តោតលើការកំណត់នូវគ្រោះថ្នាក់នៅគ្រប់កម្រិតទាំងអស់ ហើយអាចផ្តល់ព័ត៌មានសំខាន់ៗសម្រាប់ការពង្រឹងការអនុវត្តសុវត្ថិភាព ការបង្កើតនីតិវិធីត្រឹមត្រូវ និងធានាថាអ្នកពាក់ព័ន្ធ បន្ទប់ពិសោធន៍ទាំងអស់ត្រូវបាន បណ្តុះបណ្តាលយ៉ាងត្រឹមត្រូវ។ |
| SMART | អក្សរកាត់ក្នុងភាសាអង់គ្លេសដែលចេញមកពីពាក្យ៖ Specific ជាក់លាក់ Measurableវាស់វែងបាន Achievableសម្រេចបាន Relevant ពាក់ព័ន្ធ និងTimely ទាន់ពេលវេលា។ ការកំណត់គោលដៅស្មាតនេះត្រូវបានកំណត់ឱ្យប្រើប្រាស់លើការកំណត គោលដៅអនុវត្តលើផែនការសកម្មភាពរបស់គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន។ |
| **គណៈគ្រប់គ្រងស្ទែម** | សំដៅលើគណៈកម្មាធិការគ្រប់គ្រងការងារអប់រំស្ទែមនៅសាលារៀន ដែលមានការចូលរួមដោយគណៈគ្រប់គ្រងសាលារៀន និងប្រធានបច្ចេកទេសមុខវិជ្ជាស្ទែម ដែលទទួលបន្ទុកលើការអប់រំស្ទែម។ |
| **វិទ្យាល័យធនធាន** | វិទ្យាល័យធនធានទាំង50 ក្នុងគម្រោងអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី2( USESDPII )។ |
| **ស្ទែម** | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។ |
| **ការស្ទង់មតិការពេញចិត្តរបស់សិស្ស** | ការស្ទង់មតិដែលសួរសិស្សអំពីទស្សនៈរបស់ពួកគេអំពីបទពិសោធន៍សិក្សាផ្តោតលើការអប់រំស្ទែម ។ លទ្ធផលត្រូវបានប្រើប្រាស់ ដើម្បីព័ត៌មានវិភាគដល់ការធ្វើផែនការ កែលម្អរបស់គ្រូបង្រៀននាពេលអនាគត។ |
| **ការសង្កេតលម្អិត** | ការសង្កេតលម្អិតលើការបង្រៀន ដើម្បីកំណត់ចំណុចខ្លាំង និងផ្នែកដែលត្រូវការ ការអភិវឌ្ឍន៍បន្ថែម។ ហើយផ្តល់ការពិភាក្សាដោយអ្នកសង្កេតការណ៍ និងគ្រូបង្រៀនដែលត្រូវបានសង្កេត ដោយផ្ទៀងផ្ទាត់លើលទ្ធផលនៃសកម្មភាពសម្រាប់ការ អភិវឌ្ឍន៍វិជ្ជាជីវៈ។ |
| **ការសង្កេតរហ័ស** | ការសង្កេតខ្លីៗផ្តោតលើចំណុចជាក់លាក់មួយ ឬពីរនៅក្នុងថ្នាក់រៀន ឬការបង្រៀនមួយ ឬច្រើន។ ជាធម្មតាថ្នាក់ជាច្រើនអាចត្រូវបានសង្កេតរហ័សក្នុងពេលដ៏ខ្លី។ ការវិភាគ នៃលទ្ធផលដែលផ្តល់នូវការផ្តោតលើអភិវឌ្ឍន៍ឬ ការកែលម្អរបស់គ្រូបង្រៀន។ |

## សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជាមានទំនួលខុសត្រូវជាចម្បងក្នុងការផ្តល់ការអប់រំប្រកបដោយគុណភាពដល់សិស្សានុសិស្ស គ្រប់គ្នា ដែលទំនួលខុសត្រូវនេះគឺមានន័យថាត្រូវតែមានការយកចិត្តទុកដាក់ការពារ និងបន្តកែលម្អជានិច្ចលើ គុណភាពនៃការបង្រៀន ការរៀន និងការវាយតម្លៃនៅក្នុងប្រព័ន្ធអប់រំរបស់ខ្លួននៅកម្រិតសាលារៀន ដែលមានអ្នក ពាក់ព័ន្ធចូលរួមទាំងគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន មាតាបិតា ឬអាណាព្យាបាលសិស្សជាដើម។ ការអប់រំ នៅសតវត្សរ៍ទី21 គឺទាមទារការទទួលខុសត្រូវខ្ពស់ និងការធានាបាននូវសុខុមាលភាព និងការគាំពារកុមារ ឬ សិស្ស។ តាមរយៈការធានាថាសិស្សានុសិស្សមានលទ្ធភាពទទួលបានការអប់រំដែលមានគុណភាពល្អ ទទួលបាន នូវការសហការ ការចូលរួមរៀនសូត្រដោយសេចក្តីរំភើបរីករាយ ខណៈដែលឱ្យសិស្សមានឱកាសក្នុងការទទួល បានបទពិសោធន៍ល្អៗ ជាក់ស្តែងទៅនឹងជីវិតប្រចាំថ្ងៃ ពោលគឺអាចដោះស្រាយបញ្ហាជាក់ស្តែងពិតប្រាកដដោយ ភាពច្នៃប្រឌិតបាន។ កត្តាទាំងអស់នេះនឹងជះឥទ្ធិពលវិជ្ជមានដល់សុខុមាលភាពរបស់ពួកគាត់។ ការពាំនាំនូវការ អប់រំស្ទែមទៅក្នុងកម្មវិធីសិក្សានៅកម្រិតមធ្យមសិក្សាទុតិយភូមផ្តល់ឱកាសដល់សិស្សានុសិស្សអាចចូលរួមពេញ លេញលើការសិក្សាពហុមុខវិជ្ជារួមបញ្ចូលគ្នា ការច្នៃប្រឌិត និងការអង្កេតដែលទាក់ទងនឹងការដោះស្រាយបញ្ហា ពិតជាក់ស្តែង។ អាស្រ័យហេតុនេះទើបវត្ថុបំណងរួមរបស់កញ្ចប់ឧបករណ៍ពិនិត្យតាមដាន និងវង្វាយតម្លៃនេះត្រូវ បានចងក្រងឡើង ដើម្បីធានាថាសិស្សចូលរួមក្នុងការអប់រំស្ទែមប្រកបដោយគុណភាពខ្ពស់ដែលគាំទ្រដោយ សាលារៀនធនធានដ៏ល្អ គណៈគ្រប់គ្រងស្ទែម និងគ្រូបង្រៀនដែលមានបទពិសោធន៍ និងគុណវុឌ្ឍិគ្រប់គ្រាន់។

## តើអ្វីទៅជាកញ្ចប់ឧបករណ៍ពិនិត្យតាមដាន និងវង្វាយតម្លៃ?

កញ្ចប់ឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃនេះមានសំណុំឧបករណ៍ដែលត្រូវបានបង្កើតឡើងជាពិសេស ដើម្បីពិនិ ត្យតាមដាន និងវាយតម្លៃគុណភាពនៃការបង្រៀន ការសិក្សា និងការវាយតម្លៃស្ទែមនៅក្នុងសាលារៀនមធ្យមសិក្សា ទុតិយភូមិ។ គុណភាពទាំងអស់នេះនិងត្រូវសម្រេចបានដោយការត្រួតពិនិត្យ និងវាយតម្លៃចេញពីទស្សនៈរបស់ អ្នកពាក់ព័ន្ធបីរួមមានដូចជា គណៈគ្រប់គ្រងស្ទែម គ្រូបង្រៀនមុខវិជ្ជាស្ទែម និងសិស្សានុសិស្ស។ ការពិនិត្យតាម ដាន និងវាយតម្លៃអ្នកទាំងបីក្រុមនេះនឹងនាំទៅដល់ការវាយតម្លៃដែលត្រឹមត្រូវ និងអាចជឿទុកចិត្តបានក្នុងការឆ្លុះ បញ្ចាំងអំពីគុណភាពនៃការគ្រប់គ្រងសាលារៀន និងការបង្រៀនមុខវិជ្ជាស្ទែម។ ប្រសិនបើឧបករណ៍វង្វាយតម្លៃ ទាំងអស់នេះត្រូវបានយកមកវិភាគប្រកបដោយគោលបំណងច្បាស់លាស់ ជាក់លាក់ត្រឹមត្រូវ និងដោយភាពស្មោះ ត្រង់ វានឹងអាចបញ្ជាក់ពីលទ្ធផលសិក្សារបស់សិស្សកាន់តែប្រសើរឡើង។ ឧបករណ៍ពិនិត្យតាមដាន និងវង្វាយ តម្លៃរួមបញ្ចូលទិន្នន័យបរិមាណវិស័យ និងគុណវិស័យ ដែលមិនត្រឹមតែកំណត់សេចក្តីត្រូវការ និងការកែលម្អ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្ហាញរបៀបនៃការបង្កើតផែនការសកម្មភាព និងការអនុវត្តដើម្បីធ្វើការកែលម្អផងដែរ។ គណៈគ្រប់គ្រងស្ទែម និងគ្រូបង្រៀន ត្រូវបានរំពឹងទុកយ៉ាងខ្ពស់ថា ពួកគាត់អាចឆ្លុះបញ្ចាំង និងពិនិត្យមើល

សកម្មភាពរបស់ខ្លួនផ្ទាល់ក្នុងការសម្រេចបាននូវការកែលម្អឈ្មោះទៅរកភាពប្រសើរឡើងយ៉ាងឆាប់រហ័ស ជានិរន្តរភាព និងជាប្រចាំនៅក្នុងការលើកស្ទួយដល់លទ្ធផលសិក្សារបស់សិស្ស។

## ទិដ្ឋភាពទូទៅនៃឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃស្នែម

តារាងទី1 ខាងក្រោមនេះបង្ហាញពីទិដ្ឋភាពទូទៅមួយនៃសកម្មភាពពិនិត្យតាមដាន និងកាវាយតម្លៃការរៀន និងបង្រៀនស្នែមដែលបានគ្រោងទុកនៅក្នុងសាលារៀនមធ្យមសិក្សាទុតិយភូមិ។ តារាងនេះបង្ហាញពីរូបភាពនៃការវាយតម្លៃទៅតាមដំណាក់កាលនីមួយៗក្នុងចំណោមអ្នកពាក់ព័ន្ធផ្ទាល់ទាំងបីក្រុមនៅកម្រិតសាលារៀនរួមមាន ថ្នាក់ដឹកនាំសាលារៀន និងប្រធានក្រុមបច្ចេកទេសមុខវិជ្ជាស្នែម (គណៈគ្រប់គ្រងស្នែម) គ្រូបង្រៀនមុខវិជ្ជាស្នែម និងសិស្ស ដែលយើងត្រូវការការពិនិត្យតាមដាន និងវាយតម្លៃឱ្យបានទៀងទាត់ជុំវិញការងារដឹកនាំ គ្រប់គ្រង ការបង្រៀន និងរៀនស្នែមដែលប្រភេទនៃសកម្មភាពនីមួយៗបង្ហាញថា នរណាខ្លះជាអ្នកដឹកនាំការពិនិត្យតាមដាន និងវាយតម្លៃនេះ? ហើយត្រូវការប្រើប្រាស់មធ្យោបាយអ្វីខ្លះ? (តាមអនឡាញ ឬជួបមុខផ្ទាល់មែនឬទេ? និងថាតើការពិនិត្យតាមដាន ឬវាយតម្លៃគួរតែប្រើប្រាស់មធ្យោបាយទាំងពីរដែរឬទេ?)។ ឧបករណ៍ក្នុងឧបសម្ព័ន្ធដែលនឹងផ្តល់សេចក្តីណែនាំលម្អិតអំពីរបៀបប្រើប្រាស់ និងច្បាប់ចម្លងនៃឧបករណ៍នីមួយៗផងដែរ។

សាលារៀននីមួយៗនឹងទទួលបានច្បាប់ចម្លងនៃឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃការរៀន និងបង្រៀនទាំងអស់តាមប្រពន្ធអនឡាញ ហើយពួកគាត់អាចចូលទៅប្រើប្រាស់ឧបករណ៍ស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រា និងស្វ័យវង្វាយតម្លៃលើវឌ្ឍនភាពក៏ដូចជាឯកសារផ្សេងៗទៀតដែលតម្រូវឱ្យគណៈគ្រប់គ្រងស្នែម គ្រូបង្រៀន និងសិស្សនៅសាលារៀនទាំងនោះបំពេញ។ សាលារៀននីមួយៗត្រូវប្រគល់ច្បាប់ចម្លងនៃស្វ័យវង្វាយតម្លៃរបស់ខ្លួនជូនទៅកាន់វិទ្យាស្ថានជាតិអប់រំក្រោយពេលបំពេញចប់រួចរាល់តាមរយៈគ្រូបង្គោលនៃវិទ្យាស្ថានជាតិអប់រំដែលទទួលបន្ទុកការងារជួយគាំទ្រនៅសាលារៀនរបស់ពួកគាត់។ ការផ្ញើទិន្នន័យស្វ័យវង្វាយតម្លៃជូនដល់វិទ្យាស្ថានជាតិអប់រំវិញនេះគឺមានសារសំខាន់ដែលទាមទារនូវការបំពេញទិន្នន័យឱ្យបានត្រឹមត្រូវច្បាស់លាស់ និងមានសុពលភាព យកជាការបាន ដើម្បីយកមកធ្វើជាព័ត៌មានមូលដ្ឋានសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈ។

# តារាងបង្ហាញពីសកម្មភាពការពិនិត្យតាមដាន និងវាយតម្លៃស្ទែមនៅសាលារៀន

| កម្រិត | ឧបករណ៍ | អ្នកដឹកនាំ | ប្រភេទ | តាមដាន | វាយតម្លៃ | ឧបសម្ព័ន្ធ |
|---|---|---|---|---|---|---|
| គណៈគ្រប់គ្រងស្ទែម | 1). ការត្រួតពិនិត្យកិច្ចពិភាក្សាសម្រាប់គណៈគ្រប់គ្រងស្ទែម (ប្រចាំឆ្នាំ) | វ.ជ.អ | អនឡាញ ជួបផ្ទាល់ | X | X | ក |
| | 2). ស្វ័យវាយតម្លៃទិន្នន័យដើមគ្រាគណៈគ្រប់គ្រងស្ទែម (ប្រចាំឆ្នាំ) | គណៈគ្រប់គ្រងស្ទែម | អនឡាញ | X | X | ខ |
| | 3). ស្វ័យវាយតម្លៃវឌ្ឍនភាពគណៈគ្រប់គ្រងស្ទែម (ប្រចាំឆ្នាំ) | គណៈគ្រប់គ្រងស្ទែម | អនឡាញ | X | X | ខ |
| | 4). ការសង្កេតលម្អិតលើការបង្រៀនស្ទែម (អប្បបរិមា1ដង/ឆ្នាំ) | គណៈគ្រប់គ្រងស្ទែម / គ្រូបង្គោលផ្នែកស្ទែម / ក្រុមគ្រូបង្រៀន | ជួបផ្ទាល់ | X | | គ |
| | 5). ការសង្កេតរហ័សលើការបង្រៀនស្ទែម (តាមសេចក្តីត្រូវការ) | គណៈគ្រប់គ្រងស្ទែម / គ្រូបង្គោលផ្នែកស្ទែម | ជួបផ្ទាល់ | X | | ឃ |
| | 6). ផែនការសកម្មភាពគណៈគ្រប់គ្រងស្ទែមកម្រិតសាលារៀន (ជាប្រចាំ) | វ.ជ.អ/ គណៈគ្រប់គ្រងស្ទែម | អនឡាញ ជួបផ្ទាល់ | X | | ង |
| | 7). ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំកម្រិតបុគ្គល (ជាប្រចាំ) | គណៈគ្រប់គ្រងស្ទែម | អនឡាញ ជួបផ្ទាល់ | X | | ច |
| គ្រូបង្រៀន | 1). ស្វ័យវាយតម្លៃទិន្នន័យដើមគ្រារបស់គ្រូបង្រៀនស្ទែម (ប្រចាំឆ្នាំ) | វ.ជ.អ | អនឡាញ | X | X | ច |
| | 2). ស្វ័យវាយតម្លៃវឌ្ឍនភាពគ្រូបង្រៀនស្ទែម (ប្រចាំឆ្នាំ) | វ.ជ.អ | អនឡាញ | X | X | ច |
| | 3). ការសង្កេតលម្អិតលើការបង្រៀនស្ទែម (ជាក្រុមតាមជាក់ស្តែង) | គ្រូបង្គោលផ្នែកស្ទែម / ក្រុមគ្រូបង្រៀន | ជួបផ្ទាល់ | X | | គ |
| | 4). ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំកម្រិតបុគ្គល (ជាប្រចាំ) | គ្រូបង្រៀនស្ទែម | អនឡាញ ជួបផ្ទាល់ | X | | ច |
| សិស្ស | 1). ការស្ទង់មតិទិន្នន័យដើមគ្រាស្តីពីការពេញចិត្តរបស់សិស្សលើមុខវិជ្ជាស្ទែម (ប្រចាំឆ្នាំ) | វ.ជ.អ | អនឡាញ | X | X | ជ |
| | 2). ការស្ទង់មតិពិនិត្យវឌ្ឍនភាពស្តីពីការពេញចិត្តរបស់សិស្សលើមុខវិជ្ជាស្ទែម (ប្រចាំឆ្នាំ) | វ.ជ.អ | អនឡាញ | X | X | ជ |

*តារាងទី 1 ៖ បង្ហាញពីសកម្មភាពការពិនិត្យតាមដាន និងវាយតម្លៃស្ទែមនៅសាលារៀន*

រូបភាពទី1 ខាងក្រោមបង្ហាញពីឥទ្ធិពលនៃវដ្តនៃការត្រួតពិនិត្យ និងការវាយតម្លៃជាប្រចាំដែលផ្សារភ្ជាប់ទៅនឹងការប្រើប្រាស់ឧបករណ៍ពិនិត្យតាមដាន និងការវាយតម្លៃស្វែមទាំងអស់។ ភាពស៊ីសង្វាក់គ្នានៃការអនុវត្តគឺជាមូលដ្ឋានគ្រឹះនៃដំណើរការនេះសម្រាប់ការកែលម្អជានិរន្តរភាព និងការអភិវឌ្ឍន៍រយៈពេលវែង។ មូលដ្ឋានគ្រឹះនៃការកែលម្អ និងការអភិវឌ្ឍវិជ្ជាជីវៈគឺផ្អែកលើ ក) ការវិភាគលម្អិតដោយប្រើប្រាស់ឧបករណ៍ការត្រួតពិនិត្យកិច្ចពិភាក្សាសម្រាប់គណៈគ្រប់គ្រងស្វែម និងឧបករណ៍វង្វាយតម្លៃទិន្នន័យដើមគ្រា និងស្វ័យវង្វាយតម្លៃស្តីពីវឌ្ឍនភាព ការស្ទង់មតិការពេញចិត្តរបស់សិស្ស ការសង្កេតការបង្រៀន និងតម្រូវការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំកម្រិតបុគ្គល ខ) ការកំណត់បញ្ហាជាក់លាក់ពិតប្រាកដពីមួយទៅមួយ គ) ការបង្កើតផែនការសកម្មភាពដោយប្រើប្រាស់គោលដៅSMART ដើម្បីដោះស្រាយបញ្ហានីមួយៗដែលបានកំណត់ និង ឃ) ការអនុវត្តការពិនិត្យឡើងវិញយ៉ាងហ្មត់ចត់អំពីវឌ្ឍនភាព និងការធ្វើផែនការឡើងវិញក្នុងករណីចាំបាច់។

## ទិដ្ឋភាពទូទៅនៃដំណើរការប្រើប្រាស់ឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃស្វែមសម្រាប់ការអភិវឌ្ឍគុណវុឌ្ឍិគណៈគ្រប់គ្រងស្វែម គ្រូបង្រៀនស្វែម និងសិស្ស




*រូបភាព 1៖ វដ្តស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រា និងស្វ័យវង្វាយតម្លៃលើវឌ្ឍនភាពចូលរួមចំណែកក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ*

## និដ្ឋភាពទូទៅនៃគោលបំណងឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃស្ទែមនីមួយៗ

### ឧបសម្ព័ន្ធ ក៖ ឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាសម្រាប់គណៈគ្រប់គ្រងស្ទែម

ឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាគណៈគ្រប់គ្រងស្ទែមផ្ដោតការយកចិត្តទុកដាក់ពីសំណាក់គណៈគ្រប់គ្រងសាលារៀន និងប្រធានបច្ចេកទេសនៃមុខវិជ្ជាស្ទែមទៅលើចំណុចគន្លឹះសំខាន់ៗចំពោះការកែលម្អលទ្ធផលសិក្សារបស់សិស្សលើមុខវិជ្ជាស្ទែម ។ គណៈគ្រប់គ្រងស្ទែមនឹងពិនិត្យឡើងវិញនូវភស្តុតាង ដែលទទួលបានពីការប្រើប្រាស់ឧបករណ៍នីមួយៗខាងក្រោម ក្នុងគោលបំណងផ្តល់នូវព័ត៌មានលម្អិតអំពីការបំពេញឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាសម្រាប់គណៈគ្រប់គ្រងស្ទែមនេះ ។ ការបំពេញឧបករណ៍ពិនិត្យការពិភាក្សានេះតម្រូវឱ្យគណៈគ្រប់គ្រងស្ទែមប្រមូលទិន្នន័យស្ថិតិស្តីពីវត្តមានសិស្ស ចំនួនចូលរៀនរបស់សិស្សក្នុងមុខវិជ្ជាស្ទែមនីមួយៗ និងការបន្តការសិក្សាក្នុងមុខវិជ្ជាស្ទែម ។

### ឧបសម្ព័ន្ធ ខ៖ ឧបករណ៍ស្វ័យវាយតម្លៃទិន្នន័យដើមគ្រា និងស្វ័យវាយតម្លៃវឌ្ឍនភាពគណៈគ្រប់គ្រងស្ទែម

គណៈគ្រប់គ្រងស្ទែមប្រើប្រាស់ការស្ទង់មតិមួយនេះ ដើម្បីវាយតម្លៃចំណេះដឹងថ្មីៗដែលត្រូវបានអភិវឌ្ឍ និងការយល់ដឹងអំពីតួនាទី និងទំនួលខុសត្រូវជាគណៈគ្រប់គ្រងសាលារៀន និងប្រធានបច្ចេកទេសមុខវិជ្ជាស្ទែម។ កត្តានេះនឹងផ្តល់ឱ្យគណៈគ្រប់គ្រងស្ទែម និងវិទ្យាស្ថានជាតិអប់រំទទួលបានទិន្នន័យដើម្បីដឹងអំពីសេចក្តីត្រូវការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ។ តាមរយៈវាយតម្លៃនេះ គេអាចរំពឹងថានឹងទទួលបានការកើនឡើងនូវលទ្ធផលសិក្សា និងការរីកចម្រើនរបស់សិស្សបានល្អប្រសើរជាមុន។

### ឧបសម្ព័ន្ធ គ៖ ឧបករណ៍សង្កេតលម្អិតលើការបង្រៀនស្ទែម

ឧបករណ៍នេះផ្តល់ក្របខ័ណ្ឌមួយដល់គណៈគ្រប់គ្រងស្ទែម ក្រុមគ្រូបង្រៀន គ្រូបង្រៀន និងគ្រូប្រឹក្សាយោបល់ផ្នែកស្ទែមអាចមើលឃើញពីតម្រូវការអភិវឌ្ឍរបស់គ្រូបង្រៀនមុខវិជ្ជាស្ទែម ។ គណៈគ្រប់គ្រងស្ទែម គ្រូបង្រៀន និងគ្រូប្រឹក្សាយោបល់ផ្នែកស្ទែមនឹងទទួលបានព័ត៌មានអំពីគុណភាពនៃការបង្រៀន ការរៀន និងការវាយតម្លៃស្ទែមដើម្បីផ្តល់ជាព័ត៌មានក្នុងការកំណត់នូវការកែតម្រូវនានានៃការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំរបស់គ្រូបង្រៀនផ្នែកស្ទែមម្នាក់ៗ។

#### ឧបសម្ព័ន្ធ ឃ៖ ឧបករណ៍សង្កេតរយៈពេលខ្លីលើការបង្រៀនស្ទែម

ឧបករណ៍វាយតម្លៃនេះនឹងផ្តល់ឱកាសសម្រាប់គណៈគ្រប់គ្រងស្ទែមអាចធ្វើការសង្កេតលើសកម្មភាពជាក់លាក់នានាដែលពាក់ព័ន្ធទៅនឹងការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀនលើការបង្រៀន ការរៀន និងការវាយតម្លៃ។ គណៈគ្រប់គ្រងស្ទែម គ្រូបង្រៀន និងគ្រូប្រឹក្សាផ្នែកស្ទែមនឹងទទួលបានព័ត៌មានជុំវិញទិដ្ឋភាពដ៏ជាក់លាក់ក្នុងការកំណត់នូវគុណភាពនៃការបង្រៀន ការរៀន និងការវាយតម្លៃលើមុខវិជ្ជាស្ទែមក៏ដូចជាផ្តល់នូវឱកាសសម្រាប់កំណត់នូវព័ត៌មាននានាក្នុងយកមកប្រើប្រាស់ក្នុងដំណើរការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គ្រូបង្រៀនផងដែរ។

ទម្រង់ផែនការសកម្មភាពគណៈគ្រប់គ្រងស្ទែមកម្រិតសាលារៀនគឺជាឧបករណ៍ផ្តល់កន្លែងដល់គណៈគ្រប់គ្រងស្ទែមដើម្បីរៀបចំផែនការកែលម្អការបង្រៀន ការរៀន និងការវាយតម្លៃស្ទែម នៅកម្រិតសាលារៀនរបស់ពួកគាត់ដោយប្រើប្រាស់លទ្ធផលចេញពីឧបសម្ព័ន្ធ ក – ឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាគណៈគ្រប់គ្រងស្ទែម។

## ឧបសម្ព័ន្ធច៖ ទម្រង់ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំកម្រិតបុគ្គល

ទម្រង់ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំកម្រិតបុគ្គលនេះផ្តល់ឱ្យគណៈគ្រប់គ្រងស្ទែម (សមាជិកម្នាក់ៗ) និងគ្រូបង្រៀនបង្រៀនមុខវិជ្ជាស្ទែមពិនិត្យដ៏ហ្មត់ចត់ឡើងវិញនូវសេចក្តីត្រូវការរបស់ពួកគាត់លើការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ។ គ្រូបង្រៀននឹងរួមបញ្ចូលនូវលទ្ធផលដែលយកចេញមកពីការសង្កេតដោយប្រើប្រាស់ឧបករណ៍សង្កេតលម្អិតលើការបង្រៀនស្ទែម និងឧបករណ៍សង្កេតរហ័សលើការបង្រៀនស្ទែម និងយន្តការផ្សេងៗទៀតដើម្បីជួយកំណត់នូវសេចក្តីត្រូវការនានាសម្រាប់យកមកបណ្តុះបណ្តាលក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

## ឧបសម្ព័ន្ធ ឆ៖ ឧបករណ៍ស្វ័យវាយតម្លៃទិន្នន័យដើមគ្រា និងស្វ័យវាយតម្លៃវឌ្ឍនភាពគ្រូបង្រៀនស្ទែម

គ្រូបង្រៀនមុខវិជ្ជាស្ទែមប្រើប្រាស់ការស្ទង់មតិមួយនេះដើម្បីវាយតម្លៃចំណេះដឹងបច្ចុប្បន្ន និងចំណេះដឹងដែលបានអភិវឌ្ឍរបស់ពួកគាត់ដើម្បីឈ្វេងយល់អំពីវិធីសាស្ត្រការបង្រៀន ការរៀន និងការវាយតម្លៃលើមុខវិជ្ជាស្ទែម។ ឧបករណ៍នេះនឹងផ្តល់ឱ្យគ្រូបង្រៀន គណៈគ្រប់គ្រងស្ទែម និងវិទ្យាស្ថានជាតិអប់រំទទួលបានព័ត៌មានដើម្បីកំណត់ពីតម្រូវការនានាសម្រាប់យកមកបណ្តុះបណ្តាលក្នុងការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ។ តាមរយៈការវាយតម្លៃនេះគេនឹងទទួលបានការកើនឡើងនូវលទ្ធផលសិក្សា និងការរីកចម្រើនរបស់សិស្ស។

## ឧបសម្ព័ន្ធ ជ៖ ឧបករណ៍ស្ទង់មតិទិន្នន័យដើមគ្រា និងវឌ្ឍនភាពស្តីពីការពេញចិត្តរបស់សិស្សលើមុខវិជ្ជាស្ទែម

សិស្សដែលសិក្សាមុខវិជ្ជាស្ទែមត្រូវបំពេញការស្ទង់មតិមួយនេះដើម្បីផ្តល់ជាទស្សនៈរបស់ពួកគាត់អំពីបទពិសោធន៍នៃការរៀនមុខវិជ្ជាស្ទែមនៅក្នុងសាលារៀនរបស់ពួកគាត់។ ការស្ទង់មតិនេះនេះនឹងផ្តល់ឱ្យគណៈគ្រប់គ្រងស្ទែម គ្រូបង្រៀន និងវិទ្យាស្ថានជាតិអប់រំអាចឈ្វេងយល់ឱ្យបានស៊ីជម្រៅជុំវិញទស្សនៈផ្សេងៗគ្នាមួយជ្រុងទៀតដែលឆ្លុះបញ្ចាំងពីគុណភាព និងការអនុវត្តនៃការបង្រៀន ការរៀន និងការវាយតម្លៃស្ទែមចេញពីទស្សនៈរបស់សិស្សដោយផ្ទាល់តែម្តង។ លទ្ធផលទទួលបានចេញពីការស្ទង់មតិនេះនឹងផ្តល់ជាព័ត៌មានសម្រាប់គ្រប់ភាគីទាំងអស់ធ្វើការឆ្លុះបញ្ចាំងអំពីអ្វីដែលកំពុងដំណើរការល្អ និងអ្វីដែលត្រូវកែលម្អបន្ថែមទៀត។

## អំពីឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃស្ទែម

ខាងក្រោមនេះគឺជាកាពន្យល់លម្អិតអំពីប្រើប្រាស់ឧបករណ៍ពិនិត្យតាមដាន និងវង្វាយតម្លៃការរៀន និងបង្រៀនស្ទែមនៅមធ្យមសិក្សាទុតិយភូមិ។ គោលបំណងនៃការប្រើប្រាស់ឧបករណ៍វង្វាយតម្លៃទាំងប្រាំបីគឺដើម្បីឆ្លើយតប និងវាស់វែងទៅលើផលជះនៃវគ្គបណ្តុះបណ្តាលស្តីពីការរៀន និងបង្រៀនស្ទែមនៅមធ្យមសិក្សាទុតិយភូមិសម្រាប់វិទ្យាល័យធនធានទាំងហាសិប និងបណ្តាសាលារៀនបណ្តាញផ្សេងៗទៀតនៅទូទាំងប្រទេសកម្ពុជា។ ឧបករណ៍ពិនិត្យតាមដាន និងវង្វាយតម្លៃនេះត្រូវបានបង្កើតឡើងដើម្បីផ្តោតលើការត្រួតពិនិត្យលទ្ធផលធំៗចំនួនពីរគឺ៖

1. តើសាលារៀនកំពុងតែអនុវត្តចំណេះដឹងដែលពួកគាត់បានរៀននៅក្នុងវគ្គបណ្តុះបណ្តាលស្តីពីការរៀន និងបង្រៀនស្ទែមនៅមធ្យមសិក្សាទុតិយភូមិ ដែលរៀបចំដោយវិទ្យាស្ថានជាតិអប់រំដែរឬទេ?
2. តើអ្វីទៅគឺជាផលជះលើលទ្ធផលនៃកាសិក្សារបស់សិស្សក្រោយសាលារៀនទទួលបានការបណ្តុះបណ្តាលស្តីពីការរៀន និងបង្រៀនស្ទែម?

ឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃស្ទែមត្រូវបានបែងចែកជា 3ផ្នែកធំៗ និងផ្តោតលើការវាយតម្លៃចេញពីទស្សនៈផ្សេងៗគ្នាបីកម្រិតគឺ

ក៖ គណៈគ្រប់គ្រងស្ទែម
ខ៖ គ្រូបង្រៀនមុខវិជ្ជាស្ទែម
គ៖ សិស្ស

## ក. គណៈគ្រប់គ្រងស្ទែម

ឧបករណ៍វង្វាយតម្លៃ

1. ឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាគណៈគ្រប់គ្រងស្ទែម (ឧបសម្ព័ន្ធ ក)
2. ឧបករណ៍ស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រា (ឧបសម្ព័ន្ធ ខ)
3. ឧបករណ៍ស្វ័យវង្វាយតម្លៃវឌ្ឍនភាពគណៈគ្រប់គ្រងស្ទែម(ឧបសម្ព័ន្ធ ខ)
4. ឧបករណ៍សង្កេតលម្អិតលើការបង្រៀនស្ទែម(ឧបសម្ព័ន្ធ គ)
5. ឧបករណ៍សង្កេតរហ័សលើការបង្រៀនស្ទែម (ឧបសម្ព័ន្ធ ឃ)
6. ទម្រង់ផែនការសកម្មភាពគណៈគ្រប់គ្រងស្ទែមកម្រិតសាលារៀន (ឧបសម្ព័ន្ធ ង)
7. ទម្រង់ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំកម្រិតបុគ្គល (ឧបសម្ព័ន្ធ ច)

## ទិដ្ឋភាពទូទៅនៃសកម្មភាពពិនិត្យតាមដាន និងការវាយតម្លៃគណៈគ្រប់គ្រងស្ទែម

1. គ្រូបង្គោលវិទ្យាស្ថានជាតិអប់រំគួរតែធ្វើការពិភាក្សា (ដោយផ្ទាល់ ឬតាមអនឡាញ) ជាមួយគណៈគ្រប់គ្រងសាលារៀន ឬប្រធានក្រុមមុខវិជ្ជាស្ទែម ឬករណីមួយទៀតគ្រាន់តែពិនិត្យមើលលើការបំពេញឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាគណៈគ្រប់គ្រងស្ទែម និងផែនការសកម្មភាពគណៈគ្រប់គ្រងស្ទែមកម្រិតសាលារៀន។ ឧបករណ៍នេះ (ឧបសម្ព័ន្ធ ក) អាចត្រូវបានប្រើប្រាស់ដើម្បីណែនាំគណៈគ្រប់គ្រងស្ទែម និង/ឬ គ្រូ

បង្គោល វិទ្យាស្ថានជាតិអប់រំដើម្បីឆ្លើយតបភ្លាមៗ។ ការពិភាក្សានេះនឹងរួមបញ្ចូលគណៈគ្រប់គ្រងស្នែម ដែលជាអ្នកផ្តល់ឧទាហរណ៍ជាក់ស្តែង ដើម្បីបង្ហាញគ្រូបង្គោលវិទ្យាស្ថានជាតិអប់រំនូវព័ត៌មាននានាក្នុង ឧបករណ៍នេះ។ គោលបំណងនៃការធ្វើបែបនេះគឺដើម្បីវាស់ស្ទង់ការចូលរួមរបស់គណៈគ្រប់គ្រងស្ទែម គ្រូបង្រៀនមុខវិជ្ជាស្ទែមក្នុងការផ្តល់ការគាំទ្រ ការណែនាំ និងការអភិវឌ្ឍន៍ជាប្រចាំលើការបង្រៀន ការរៀន និងការវាយតម្លៃស្ទែមនៅក្នុងសាលារៀនរបស់ពួកគាត់។

2. គណៈគ្រប់គ្រងសាលារៀន និងប្រធានក្រុមមុខវិជ្ជាស្ទែមនឹងត្រូវបំពេញឧបករណ៍ស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រា (ឧបសម្ព័ន្ធ ខ) ជាមុនសិន ទើបពួកគាត់អាចប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាគណៈគ្រប់គ្រងស្ទែមនេះបានតាមក្រោយ។.

3. គណៈគ្រប់គ្រងសាលារៀន និងប្រធានក្រុមមុខវិជ្ជាស្ទែមនឹងត្រូវបំពេញការវាយតម្លៃលើឧបករណ៍ស្វ័យរង្វាយតម្លៃវឌ្ឍនភាព(ឧបសម្ព័ន្ធ ខ) នៅរៀងរាល់ពេល៦ខែម្តង បន្ទាប់ពីពួកគាត់បានបញ្ចប់ការធ្វើស្វ័យរង្វាយតម្លៃទិន្នន័យដើមគ្រារួចហើយកាលពី៦ខែមុន។ ឧបករណ៍នេះនឹងជួយតាមដានវឌ្ឍនភាពរបស់គណៈគ្រប់គ្រងស្ទែមចំពោះទំនុកចិត្តរបស់ពួកគាត់លើការអប់រំស្ទែមនៅកម្រិតសាលារៀន។

4. ឧបករណ៍សង្កេតលម្អិតលើការបង្រៀនស្ទែម (ឧបសម្ព័ន្ធ គ) គណៈគ្រប់គ្រងស្ទែម គ្រូបង្រៀន និងគ្រូប្រឹក្សាយោបល់ផ្នែកស្ទែម គឺជាអ្នកដែលធ្វើការសង្កេតការបង្រៀនរបស់គ្រូបង្រៀនស្ទែម ទៅតាមពេលវេលាសមស្របណាមួយដែលបានព្រមព្រៀងគ្នា។ គោលបំណងនៃឧបករណ៍នេះគឺសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្ស។

5. ឧបករណ៍សង្កេតរហ័សការបង្រៀនស្ទែម(ឧបសម្ព័ន្ធ ឃ) ត្រូវបានបង្កើតឡើង ដើម្បីគ្របដណ្តប់លើប្រធានបទជាច្រើនក្នុងរយៈពេលដ៏ខ្លី និងតាមបរិបទថ្នាក់រៀនស្ទែមនីមួយៗ។ ឧបករណ៍ទាំងនេះផ្តល់ឱកាសដ៏ល្អសម្រាប់គណៈគ្រប់គ្រងស្ទែមដើម្បីចូលសង្កេតលើការបង្រៀនស្ទែមនៅតាមថ្នាក់រៀនស្ទែមក្នុងគោលបំណងសង្កេតមើលគុណភាពនៃអ្វីដែលកំពុងកើតឡើងជាទៀងទាត់ និងជាផ្នែកមួយយក្នុងការជួយគាំទ្រកែលម្អ ដោយការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំរបស់គ្រូបង្រៀនស្ទែម។

6. គណៈគ្រប់គ្រងស្ទែមត្រូវបំពេញព័ត៌មានចូលទៅក្នុងទម្រង់ផែនការសកម្មភាពគណៈគ្រប់គ្រងស្ទែមនៅកម្រិតសាលារៀន(ឧបសម្ព័ន្ធ ង) ដោយពួកគាត់ត្រូវកំណត់ឱ្យបាននូវសកម្មភាពជាគោលដៅនានាដែលគាំទ្រដល់គ្រប់សកម្មភាពទាំងអស់នៃការពិនិត្យតាមដាន និងវាយតម្លៃក្នុងសាលារៀនរបស់ពួកគាត់។ ទម្រង់ផែនការសកម្មភាពនេះអាចយកមកប្រើប្រាស់បានដោយសារតែវាផ្តោតលើចំណុចដ៏ជាក់លាក់នូវព័ត៌មានដែលយចេញពីការវាយតម្លៃទាំងបីរបស់គណៈគ្រប់គ្រងស្ទែមដូចបានរៀបរាប់ខាងលើ។ ម្យ៉ាងវិញទៀតសាលារៀនក៏អាចបន្ថែមសកម្មភាពបន្ថែមទៀតទៅក្នុងផែនការសកម្មភាពគណៈគ្រប់គ្រងស្ទែមនៅកម្រិតសាលារៀននេះបានដែរ បើទោះជាផែនការសកម្មភាពនេះ កំពុងតែយកមកអនុវត្តនាពេលនេះក៏ដោយ។

7. គណៈគ្រប់គ្រងស្ទែម និងគ្រូបង្រៀនស្ទែម ត្រូវបង្កើតផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំចេញពីទម្រង់ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈស្ទែមជាប្រចាំកម្រិតបុគ្គលក្នុង( ឧបសម្ព័ន្ធ ច ) បន្ទាប់ពីធ្វើស្វ័យវាយតម្លៃទិន្នន័យដើមគ្រា និងស្វ័យ វង្វាយតម្លៃលើវឌ្ឍនភាពរបស់ពួកគាត់រួចរាល់ហើយ។ សកម្មភាពនេះគឺដើម្បីជួយអភិវឌ្ឍសមត្ថភាព និងសក្តានុពលរបស់គណៈគ្រប់គ្រងស្ទែមម្នាក់ៗ។ ការបង្កើតផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅកម្រិត គណៈគ្រប់គ្រងស្ទែមគឺមានការរំពឹងទុកថាគណៈគ្រប់គ្រងស្ទែមម្នាក់ៗនឹងអាចកំណត់ចំណុចខ្លាំងរបស់ខ្លួនស្តីពីការគ្រប់គ្រង ដឹកនាំ និងការជួយគាំទ្រដល់សាលារៀន និងគ្រូបង្រៀនស្ទែម ហើយពួកគាត់ក៏អាចចែករំលែកបទពិសោធន៍ទាំងនេះជាមួយអ្នកដទៃផ្សេងទៀតបានផងដែរ។ ពួកគាត់ក៏ត្រូវបានគេរំពឹងដែរថានឹងអាចកំណត់ថាអ្វីទៅជាផ្នែកដែលត្រូវការការកែលម្អបន្ថែមទៀតសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈរបស់គាត់ជាប្រចាំផងដែរ។ គណៈគ្រប់គ្រងស្ទែមអាចប្រើប្រាស់ទម្រង់ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈនេះ និងបន្ថែមសកម្មភាពផ្សេងៗទៀតបាន បើទោះជាកំពុងតែអនុវត្តផែនការនេះក៏ដោយ ព្រោះថាផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈនេះអាចធ្វើបច្ចុប្បន្នកម្ម ឬកែប្រែសកម្មភាពដែលបន្សីនឹងបរិបថជាក់ស្តែងបាន។

## សេចក្តីលម្អិតពីការពិនិត្យតាមដាន និងវាយតម្លៃកម្រិតគណៈគ្រប់គ្រងស្ទែម

### 1. ឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាគណៈគ្រប់គ្រងស្ទែម ( ឧបសម្ព័ន្ធ ក )

ពេលវេលាត្រូវបានទទួលស្គាល់ថាគឺជាធនធានដ៏មានតម្លៃសម្រាប់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងការពិនិត្យតាមដាន និងការវាយតម្លៃស្ទែម។ អាស្រ័យហេតុនេះកិច្ចពិភាក្សានេះគឺមានគោលដៅសង្ខេបៗ និងប្រើប្រាស់ពេលខ្លីមិនលើសពីមួយម៉ោងកន្លះ(៩០នាទី )ឡើយ។ សម្រាប់នាទីដំបូងនៃកិច្ចពិក្សានេះគួរចាត់ទុកជាការសន្ទនាណែនាំគ្នាជុំវិញទិដ្ឋភាពសំខាន់ៗមួយចំនួននៃការគ្រប់គ្រង និងការជួយគាំទ្រដល់ការបង្រៀន ការរៀន និងការវាយតម្លៃស្ទែមនៅកម្រិតសាលារៀន។

**ឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាគណៈគ្រប់គ្រងស្ទែមមានសំណួរដែលពាក់ព័ន្ធទៅនឹង៖**

1. **ចំនួនវត្តមានសិស្ស និងចំនួនសិស្សត្រួតថ្នាក់** (ផ្តល់ការណែនាំសម្រាប់គណៈគ្រប់គ្រងស្ទែម/គ្រូបង្រៀន ដើម្បី ពិនិត្យតាមដាន )
2. **លទ្ធផលសិក្សារបស់សិស្ស** ( ការវាយតម្លៃតាមដំណាក់ និងការវាយតម្លៃចុងក្រោយ– ដើម្បីវាយតម្លៃពីផលជះ )
3. **ការជ្រើសរើសគ្រូបង្រៀនស្ទែម** ( ឱកាសដើម្បីឆ្លុះបញ្ចាំងពីបញ្ហានេះ និងសកម្មភាពដើម្បីកែលម្អ )
4. **ការគ្រប់គ្រងបន្ទប់ពិសោធន៍** ( សុខភាពនិងសុវត្ថិភាព, ការរៀបចំបន្ទប់ពិសោធន៍ ភាពសកម្ម )
5. **ផែនការបង្រៀន** ( ឱកាសដើម្បីពិនិត្យមើលផែនការបង្រៀន កិច្ចតែងការបង្រៀន ដើម្បីវាយតម្លៃថាតើស្ទែមត្រូវបានរួមបញ្ចូលគ្នាបានល្អប៉ុណ្ណា )
6. **លទ្ធផលនៃការសង្កេត** ( របាយការណ៍ និងចំណុចកែលម្អ )
7. **លទ្ធផលនៃការស្ទង់មតិ ស្តីពីការពេញចិត្តរបស់សិស្ស** ( ឆ្លុះបញ្ចាំងពីការកែលម្អ និងផែនការសកម្មភាពគោលដៅ )
8. **តម្រូវការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ** ( ឆ្លុះបញ្ចាំងពីសេចក្តីត្រូវការ និងសកម្មភាពពីការស្ទង់មតិទាំងអស់ )

ក្នុងអំឡុងពេលនៃដំណាក់កាលដំបូងនៃការពិនិត្យតាមដានរបស់វិទ្យាស្ថានជាតិអប់រំ វាអាចមានភស្តុតាងតិចតួចដែលមានស្រាប់នៅក្នុងសាលារៀន។ ទោះជាយ៉ាងណាក៏ដោយកិច្ចពិភាក្សាដំបូងជាមួយគណៈគ្រប់គ្រងស្នែមគឺដើម្បីផ្តល់ឱកាសពិភាក្សាអំពីសេចក្តីត្រូវការនានាលើការពិនិត្យតាមដាន និងការវាយតម្លៃស្ទែមទាំងប្រាំបីនេះក្នុងគោលបំណងរៀបចំផែនការសម្រាប់ការតពិនិត្យតាមដាន និងការវាយតម្លៃនាពេលអនាគតតាមរយៈអនឡាញ ឬកិច្ចពិភាក្សាដោយផ្ទាល់។ ឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សានៅក្នុងឧបសម្ព័ន្ធ ក មានចំណុចគន្លឹះសម្រាប់ចាប់ផ្តើមកការពិភាក្សា។ សំណួរគន្លឹះបំផុសកិច្ចពិភាក្សាត្រូវបានដាក់បញ្ចូលក្នុងឧបករណ៍នេះ ដើម្បីជាជំនួយស្មារតីដល់កិច្ចពិភាក្សារបស់គណៈគ្រប់គ្រងស្ទែម ។

## ទិដ្ឋភាពទូទៅ៖ ឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាសម្រាប់គណៈគ្រប់គ្រងស្ទែម

ឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាផ្តោតលើកិច្ចការទាំងប្រាំបីចំណុចរបស់គណៈគ្រប់គ្រងស្ទែមលើកត្តាជំរុញសំខាន់ៗសម្រាប់ការកែលម្អលទ្ធផលសិក្សាសិស្សលើមុខវិជ្ជាស្ទែម។ គណៈគ្រប់គ្រងស្ទែមនឹងពិនិត្យតាមដានឡើងវិញនូវភស្តុតាងដែលទទួលបានពីការប្រើប្រាស់ឧបករណ៍នីមួយៗខាងក្រោមដើម្បីជាព័ត៌មានក្នុងការបំពេញឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សានេះ។ ឧបករណ៍នេះនឹងតម្រូវឱ្យគណៈគ្រប់គ្រងស្ទែមបង្ហាញទិន្នន័យស្ថិតិវត្តមានសិស្ស និងចំនួនសិស្សជ្រើសរើសយកមុខវិជ្ជាស្ទែម។

## វត្ថុបំណង

ឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាសម្រាប់គណៈគ្រប់គ្រងស្ទែមគឺជាឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃ ដែលប្រើប្រាស់ដើម្បីផ្តល់ការវិភាគរួមទៅលើបច្ចុប្បន្នភាពនៃគុណភាពនៃការគ្រប់គ្រង ការបង្រៀន ការរៀន និងការវាយតម្លៃមុខវិជ្ជាស្ទែម។

## ដំណើរការ

### គំនូសតាងបង្ហាញលំហូរប្រើប្រាស់ឧបករណ៍



- វ.ជ.អនឹងផ្ញើច្បាប់ចម្លងអេឡិចត្រូនិចនៃឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃការរៀន និងបង្រៀនស្ទែម យ៉ាងហោចណាស់ពីរសប្តាហ៍មុនពេលកំណត់ការចុះពិនិត្យតាមដាន ឬជួបពិភាក្សាជាមួយគណៈគ្រប់គ្រងស្ទែម។ ការផ្ញើឧបករណ៍ឱ្យបានមុនពេលកំណត់នេះនឹងជួយផ្តល់ពេលវេលាគ្រប់គ្រាន់ដល់គណៈគ្រប់គ្រងសាលារៀន ដើម្បីរៀបចំពិនិត្យតាមដានដោយខ្លួនឯង និងអាចកំណត់ការរំពឹងទុក ក៏ដូចជាតម្រូវការរបស់ខ្លួនជុំវិញការអប់រំស្ទែមនៅសាលារៀន។
- គណៈគ្រប់គ្រងស្ទែមនឹងត្រូវប្រមូលផ្តុំ និងពិនិត្យមើលគំរូជាឧទាហរណ៍ចំពោះសំណួរមុនពេលពួកគេបំពេញឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សានេះ។
- គណៈគ្រប់គ្រងស្ទែមនឹងបំពេញព័ត៌មានចូលក្នុងឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សា (ឧបសម្ព័ន្ធ ក) ជាមួយនឹងការវិភាគទិន្នន័យសាលារៀនរបស់ខ្លួន និងពង្រាងផែនការសកម្មភាព (ឧបសម្ព័ន្ធ ង).
- គ្រូបង្គោលវ.ជ.អ នឹងរៀបចំការប្រជុំតាមអ៊ីនធឺណិត ឬធ្វើដំណើរទស្សនកិច្ចទៅកាន់សាលារៀនដោយផ្ទាល់ដើម្បីជួបពិភាក្សាជាមួយគណៈគ្រប់គ្រងស្ទែមទៅតាមពេលវេលា និងទីកន្លែងដែលសមស្រប។
- វ.ជ.អ និងគណៈគ្រប់គ្រងស្ទែមនឹងរៀបចំកិច្ចប្រជុំតាមអ៊ីនធឺណិត ឬជួបដោយផ្ទាល់ដើម្បីពិភាក្សាអំពីព័ត៌មានដែលបានផ្តល់ជូន។ ការប្រជុំត្រូវគ្រោងទុកក្នុងរយៈពេលប្រហែលជា 1,5 ម៉ោង (មួយម៉ោងកន្លះ)។
- នៅពេលដែលកិច្ចពិភាក្សាតាមអ៊ីនធឺណិត ឬដោយផ្ទាល់មិនអាចធ្វើទៅបាននោះគណៈគ្រប់គ្រងស្ទែម នឹងផ្ញើឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាសម្រាប់គណៈគ្រប់គ្រងស្ទែម ព័ត៌មានដែលបានបំពេញក្នុង(ឧបសម្ព័ន្ធ ក) និងទិន្នន័យដែលបានវិភាគរួចទៅកាន់ វ.ជ.អ។
- ការពិភាក្សាអាចត្រូវបានផ្សព្វផ្សាយក្នុងសាលារៀនដើម្បីផ្តល់ជាឱកាសមួយក្នុងការលើកកម្ពស់ដល់បរិយាកាសធ្វើការសហការរួមគ្នា និងការបង្កើតទំនាក់ទំនងការងារដ៏ល្អ ដែលវាអាចចាត់ទុកថាជាដំណើរការមួយដែលផ្តល់ប្រសិទ្ធភាពខ្លាំងក្នុងការជួយគាំទ្រដល់សាលារៀន។
- ឯកសារ ឬទិន្នន័យជាភស្តុតាងផ្សេងៗទៀតគួរតែត្រូវបានភ្ជាប់ជាឯកសារយោង ដើម្បីភស្តុតាងគាំទ្រដល់ការសម្រេចចិត្ត (ដូចដែលបានលើកឡើងពីមុន)។ ប្រសិនបើគណៈគ្រប់គ្រងស្ទែមមិនមានទេនោះសូមពិភាក្សាអំពីវិធីក្នុងការអភិវឌ្ឍន៍ប្រព័ន្ធកសាងឯកសារ ឬទិន្នន័យទាំងនោះដោយប្រើប្រាស់ឧបករណ៍ពិនិត្យតាមដាន និងឯកសារផ្សេងៗទៀតដែលមាននៅក្នុងឧបសម្ព័ន្ធនីមួយៗ។
- ប្រសិនបើមានឱកាសក្នុងការជួបពិភាក្សាជាមួយគណៈគ្រប់គ្រងស្ទែមនៅសាលារៀន សូមទៅពិនិត្យមើលបន្ទប់ពិសោធន៍ និងថ្នាក់រៀនដែលប្រើប្រាស់សម្រាប់ការបង្រៀនមុខវិជ្ជាស្ទែម និងជួបជាមួយគ្រូបង្រៀនមុខវិជ្ជាស្ទែម ។ សូមធ្វើការវិភាគលើវត្ថុបំណង ដោយប្រើប្រាស់ឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាគណៈគ្រប់គ្រងស្ទែម រួចហើយបំពេញព័ត៌មាននៅលើឧបករណ៍នោះ។
- គណៈគ្រប់គ្រងស្ទែមរៀបចំផែនការសកម្មភាពការងារអប់រំស្ទែមនៅកម្រិតសាលារៀន (ឧបសម្ព័ន្ធ ង) ហើយផ្ញើទៅវ.ជ.អ ។
- វ.ជ.អ កំណត់កាលបរិច្ឆេទសមស្របមួយសម្រាប់កិច្ចប្រជុំពិនិត្យតាមដាន ដើម្បីពិនិត្យមើលវឌ្ឍនភាព (ម្តងក្នុងមួយឆ្នាំនៅចុងឆមាសទី 2)។

**អ្នកចូលរួម**

- គ្រូបង្គោលវិទ្យាស្ថានជាតិអប់រំ - អ្នកសំភាសន៍ និងជាអ្នកកំណត់កិច្ចភាក្សា

- គណៈគ្រប់គ្រងស្នែម (ក្រុមស្នូលលើការងារអប់រំស្នែម) - អ្នកសម្ភាសន៍ និងអ្នកផ្តល់ឯកសារ ឬទិន្នន័យជាកស្តុតាង។
- គណៈគ្រប់គ្រងសាលារៀន - អ្នកត្រូវសំភាសន៍ និងគ្រូបង្គោលវ.ជ.អ (អ្នកសំភាសន៍ និងអ្នកកោះហៅ) - ការប្រជុំពិនិត្យតាមដានលើអ៊ីនធឺណិតនៅចុងឆ្នាំ។

**ពេលវេលា**

- គណៈគ្រប់គ្រងស្នែមបំពេញព័ត៌មានចូលក្នុងឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សា – សប្តាហ៍ទី 3 ដល់ទី 4 ។
- ការពិភាក្សាពិនិត្យតាមដានវឌ្ឍនភាពដំបូង ដោយផ្ទៀងផ្ទាត់នឹងឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សានិងត្រូវធ្វើឡើងបន្ទាប់ពីរយៈពេល 5 សប្តាហ៍ដោយគិតចាប់ផ្តើមចេញពីឆមាសទីមួយនៃឆ្នាំសិក្សា។
- គណៈគ្រប់គ្រងស្នែមពិនិត្យមើលវឌ្ឍនភាព (ភ្ជាប់ទៅផែនការសកម្មភាពស្នែមកម្រិតសាលារៀន) នៅ 6 ខែ (គណៈគ្រប់គ្រងស្នែម)
- គណៈគ្រប់គ្រងស្នែម និងវ.ជ.អ ពិនិត្យមើលវឌ្ឍនភាព (ភ្ជាប់ទៅផែនការសកម្មភាពកម្រិតសាលារៀន) នៅចុងឆមាសទី 2 ។

## 2. ការធ្វើស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រាគណៈគ្រប់គ្រងស្នែម (ឧបសម្ព័ន្ធ ខ)

ឧបករណ៍ស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រា គណៈគ្រប់គ្រងស្នែម តាមអ៊ីនធឺណិត គឺមានទាំងជាភាសាខ្មែរ និងអង់គ្លេស ហើយនឹងត្រូវការចំណាយពេលប្រហែល 15/20 នាទីដើម្បីបំពេញការវាយតម្លៃនេះ។ សូមចំណាំថាទាំងស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រា និងស្វ័យវង្វាយតម្លៃលើវឌ្ឍនភាពគឺដូចគ្នា។ ច្បាប់ចម្លងជាក្រដាសក៏មាននៅក្នុងឧបសម្ព័ន្ធ ខ សម្រាប់អ្នកដែលមិនមានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាផងដែរ។

**ទិដ្ឋភាពទូទៅ៖ ឧបករណ៍ស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រាសម្រាប់គណៈគ្រប់គ្រងស្នែម**

ឧបករណ៍ស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រាសម្រាប់គណៈគ្រប់គ្រងស្នែមគឺជាកម្រងសំណួរស្ទង់មតិដែលប្រើប្រាស់ដោយគណៈគ្រប់គ្រងស្នែម ដើម្បីវាយតម្លៃចំណេះដឹង និងការយល់ដឹងអំពីបច្ចុប្បន្នភាពនៃតួនាទី និងទំនួលខុសត្រូវ ក៏ដូចជាការកែលម្អរបស់ពួកគាត់ជុំវិញការអប់រំស្នែម។ កម្រងសំណួរនេះនិងផ្តល់នូវទិន្នន័យសម្រាប់ជាព័ត៌មានមូលដ្ឋានដល់គណៈគ្រប់គ្រងស្នែម និងវិទ្យាស្ថានជាតិអប់រំសម្រាប់យកមករៀបចំកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈដែលចាំបាច់ដល់គណៈគ្រប់គ្រងស្នែម ដែលជាជាកិច្ចការមួយក្នុងការជួយលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សផងដែរ។

**វត្ថុបំណង**

ឧបករណ៍ស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រាសម្រាប់គណៈគ្រប់គ្រងស្នែមត្រូវបានប្រើប្រាស់ដើម្បីពិនិត្យតាមដាន និងវាយតម្លៃចំណេះដឹង ជំនាញ និងសមត្ថភាពដំបូងរបស់គណៈគ្រប់គ្រងស្នែមពោលគឺប្រធានបច្ចេកទេសមុខវិជ្ជាស្នែម និងគណៈគ្រប់គ្រងសាលារៀនទទួលបន្ទុកកិច្ចការងារអប់រំស្នែមនៅសាលារៀន ដែលផ្តោតទៅលើកិច្ចការគ្រប់គ្រងរៀបចំការងារអប់រំស្នែមជាមួយគ្រូបង្រៀនមុខវិជ្ជាស្នែមនៅក្នុងសាលារៀនរបស់ពួកគាត់។

**ដំណើរកា**

## គំនូសតាងបង្ហាញលំហូរប្រើប្រាស់ឧបករណ៍




- គ្រូបង្គោលវ.ជ.អត្រូវជានាថាគណៈគ្រប់គ្រងស្វែមមានតំណភ្ជាប់នៅក្នុងសាលារៀនគោលដៅនីមួយៗ។
- គណៈគ្រប់គ្រងស្វែមពិសេសគណៈគ្រប់គ្រងសាលារៀនទទួលបន្ទុកការងារស្វែម និងប្រធានក្រុមបច្ចេកទេសមុខវិជ្ជាស្វែមចាំបាច់បំពេញកម្រងសំណួរស្ទង់មតិស្តីពីស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រាយ៉ាងហោចណាស់ត្រឹមសប្តាហ៍ទី3នៃឆ្នាំសិក្សា។ ការបំពេញការស្ទង់មតិនេះត្រូវតែធ្វើឡើងឱ្យបានមុនពេលកាលកំណត់នៃកិច្ចពិភាក្សារវាងគ្រូបង្គោលវ.ជ.អ និងគណៈគ្រប់គ្រងស្វែម។
- វ.ជ.អចាំបាច់ត្រូវតែផ្ញើលទ្ធផលនៃការស្ទង់មតិនេះត្រឡប់ទៅកាន់គណៈគ្រប់គ្រងស្វែមវិញ។
- ភាគីទាំងអស់នឹងរក្សាទុកព័ត៌មានដោយសុវត្ថិភាព និងមិនត្រូវចែករំលែកព័ត៌មានចេញពីការស្ទង់មតិនេះជាមួយភាគីទីបីណាមួយឡើយ។
- គណៈគ្រប់គ្រងស្វែមនឹងពិនិត្យឡើងវិញនូវលទ្ធផលចេញពីការស្ទង់មតិស្តីពីស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រានេះ និងកំណត់ចំណុចខ្លាំង និងផ្នែកសំខាន់ៗសម្រាប់ការកែលម្អរបស់ខ្លួន។
- សមាជិកម្នាក់ៗក្នុងគណៈគ្រប់គ្រងស្វែមនឹងបង្កើតផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈកម្រិតបុគ្គលដែលឆ្លុះបញ្ចាំងពីការងារនៅក្នុងសាលារៀនរបស់ខ្លួន។
- គណៈគ្រប់គ្រងស្វែមនៅសាលារៀននឹងផ្តល់ព័ត៌មានស្តីពីតម្រូវការអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួនជូនដល់គ្រូបង្គោលវិទ្យាស្ថានជាតិអប់រំ។ ភាគីទាំងពីរនឹងរៀបចំផែនការ និងអនុវត្តការបណ្តុះបណ្តាលវិជ្ជាជីវៈដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការទាំងនោះ។
- គណៈគ្រប់គ្រងស្វែមនៅសាលារៀននឹងពិនិត្យតាមដានវឌ្ឍនភាព ដោយផ្ទៀងផ្ទាត់ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈកម្រិតបុគ្គលជាប្រចាំ។
- គណៈគ្រប់គ្រងស្វែមនិងវិទ្យាស្ថានជាតិអប់រំនឹងពិភាក្សាអំពីវឌ្ឍនភាពដោយផ្ទៀងផ្ទាត់នឹងផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈនៅចុងឆមាសទី 2។

- គណៈគ្រប់គ្រងស្ទេមថ្មីតម្រូវឱ្យធ្វើស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រាឱ្យបានឆាប់រហ័សនាពេលដែលចូលកាន់តួនាទីរបស់ខ្លួន ដើម្បីទទួលបាននូវដំណើរការបរិយាប័ន្នការងារដែលធានាថាមន្ត្រីកាន់ការងារអប់រំស្ទែមគ្រប់រូបអាចទទួលបានឱកាសអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

## អ្នកចូលរួម

- គ្រូបង្គោលវ.ជ.អ - ផ្តល់នូវតំណភ្ជាប់ស្ទង់មតិស្វ័យវង្វាយតម្លៃ និងសម្របសម្រួលរៀបចំផែនការ និងផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈជាប្រចាំ។
- គណៈគ្រប់គ្រងស្ទែម (ក្រុមស្នូលលើការងារអប់រំស្ទែម) - ទទួលយកការស្ទង់មតិស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រា និងរៀបចំផែនការបណ្តុះបណ្តាលវិជ្ជាជីវៈជាប្រចាំកម្រិតបុគ្គល។
- គណៈគ្រប់គ្រងស្ទែម និងគ្រូបង្គោលវ.ជ.អ - ប្រជុំពិនិត្យតាមដានតាមអនឡាញនៅចុងឆ្នាំលើការបណ្តុះបណ្តាលវិជ្ជាជីវៈជាប្រចាំ។

## ពេលវេលា

- ស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រាសម្រាប់គណៈគ្រប់គ្រងស្ទែមធ្វើឡើងមុនសប្តាហ៍ទី3។
- វិទ្យាស្ថានជាតិអប់រំផ្តល់លទ្ធផលនៃស្វ័យវង្វាយតម្លៃនេះទៅគណៈគ្រប់គ្រងស្ទែមនៅសប្តាហ៍ទី4។
- គណៈគ្រប់គ្រងស្ទែមវិភាគលទ្ធផល និងរៀបចំផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈកម្រិតបុគ្គល – សប្តាហ៍ទី 4 ដល់ ទី 5
- គ.គ.ស និង វ.ជ.អ រៀបចំផែនការ និងផ្តល់ការបណ្តុះបណ្តាលលើការអភិវឌ្ឍវិជ្ជាជីវៈ - ធ្វើជាប្រចាំ
- គ.គ.សពិនិត្យមើលវឌ្ឍនភាព (ផ្ទៀងផ្ទាត់ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈកម្រិតបុគ្គល) ដោយទៀងទាត់ (ដោយលើកជារបៀបវារៈកិច្ចប្រជុំរវាងសមាជិកនៃគណៈគ្រប់គ្រងស្ទែម)
- គ.គ.ស និងគ្រូបង្គោលវ.ជ.អ ពិនិត្យមើលវឌ្ឍនភាព (ផ្ទៀងផ្ទាត់ទៅនឹងផែនការសកម្មភាពកម្រិតបុគ្គល) នៅចុងបញ្ចប់នៃឆមាសទី 2 ។

តំណភ្ជាប់ជាភាសាខ្មែរ៖ https://forms.office.com/e/C9JxTWNmdX

កូដQRភ្ជាប់ទៅកាន់ការស្ទង់មតិជាភាសាខ្មែរ៖




English link: ស្ទែម គ.គ.ស Baseline and Progress Self-Assessment (office.com)

English QR Code:




## 3. ស្វ័យវង្វាយតម្លៃលើវឌ្ឍនភាពគណៈគ្រប់គ្រងស្ទែម ( ឧបសម្ព័ន្ធ ខ )

ឧបករណ៍ស្វ័យវង្វាយតម្លៃលើវឌ្ឍនភាពគណៈគ្រប់គ្រងស្ទែមតាមអនឡាញគឺដូចគ្នានឹងឧបករណ៍ស្វ័យវង្វាយតម្លៃទិន្នន័យ ដើមគ្រាហើយនឹងយកមកអនុវត្តតាមពេលដែលបានគ្រោងទុកនៃផែនការអភិវឌ្ឍបុគ្គលិក និងពិនិត្យឡើងវិញដោយគណៈគ្រប់គ្រងស្ទែម។ សមាជិកនៃគណៈគ្រប់គ្រងស្ទែមម្នាក់ៗត្រូវបំពេញស្វ័យវង្វាយតម្លៃនេះរៀងរាល់ពេល6 ខែបន្ទាប់ពីពួកគាត់បានបញ្ចប់ស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រារួចរាល់។ លទ្ធផលនៃស្វ័យតម្លៃទាំងពីរនេះនឹងត្រូវប្រើប្រាស់សម្រាប់ការប្រៀបធៀបគ្នា។ នៅពេលនោះគេអាចកំណត់បាននូវការកែលម្អ ហើយឱកាសកំណត់បន្ថែមលើផែនការនៃការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ។ ឧបករណ៍ស្វ័យវង្វាយតម្លៃលើវឌ្ឍនភាពគឺមានទាំងជាភាសាខ្មែរ និងភាសាអង់គ្លេស។ ការបំពេញស្វ័យវង្វាយតម្លៃលើវឌ្ឍនភាពនេះតម្រូវឱ្យចំណាយពេលប្រហែល 15 ទៅ20នាទី។ តំណភ្ជាប់គឺដូចគ្នាបេះបិទទៅនឹងស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រា ។

**ទិដ្ឋភាពទូទៅ៖ ស្វ័យវង្វាយតម្លៃវឌ្ឍនភាពសម្រាប់គណៈគ្រប់គ្រងស្ទែម**

ស្វ័យវង្វាយតម្លៃវឌ្ឍនភាពសម្រាប់គណៈគ្រប់គ្រងស្ទែមគឺដូចគ្នាទៅនឹងឧបករណ៍វង្វាយតម្លៃទិន្នន័យដើមគ្រាសម្រាប់គណៈគ្រប់គ្រងស្ទែមដែរ ហើយកម្រងសំណួរស្ទង់មតិនេះនឹងត្រូវគេយកមកប្រើប្រាស់ដើម្បីតាមដានវឌ្ឍនភាពនៃចំណេះដឹង និងការយល់ដឹងអំពីតួនាទី និងភារកិច្ចទទួលខុសត្រូវរបស់គណៈគ្រប់គ្រងស្ទែមក្នុងអំឡុងពេល6ខែបន្ទាប់ពីគណៈគ្រប់គ្រងស្ទែមបានបំពេញកម្រងសំណួរស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រារួចមក។ លទ្ធផលចេញការស្វ័យវង្វាយតម្លៃទាំងពីរនេះ នឹងត្រូវបានយកមកប្រៀបធៀប។ ចំណុចដែលបានកែលម្អនឹងត្រូវមើលឃើញ និងគេអាចកំណត់ឱកាសសម្រាប់ធ្វើការផែនការអភិវឌ្ឍវិជ្ជាជីវៈបន្តទៀត។ តំណភ្ជាប់ទៅកាន់ការបំពេញកម្រងសំណួរស្ទង់មតិស្វ័យវង្វាយតម្លៃវឌ្ឍនភាពគឺគេអាចប្រើកម្រងសំណួរស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រាដដែលដែលតម្រូវឱ្យគណៈគ្រប់គ្រងស្ទែមចំណាយពេលប្រហែលជា15 ទៅ20នាទីក្នុងការបំពេញ។

## វត្ថុបំណង

ដើម្បីពិនិត្យតាមដាន វាយតម្លៃ និងប្រៀបធៀបចំណេះដឹង ជំនាញ និងសមត្ថភាពគណៈគ្រប់គ្រងស្ទែមដែលផ្តោតទៅលើកិច្ចការគ្រប់គ្រងរៀបចំការងារអប់រំស្ទែមជាមួយគ្រូបង្រៀនមុខវិជ្ជាស្ទែមនៅក្នុងសាលារៀនរបស់ពួកគាត់បន្ទាប់ពីទទួលបានការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំតបតាមតម្រូវការជាក់ស្តែងក្នុងពេលកំណត់មួយ។

## ដំណើរការ

### គំនូសតាងបង្ហាញលំហូរប្រើប្រាស់ឧបករណ៍




- គ្រប់សមាជិកទាំងអស់នៃគណៈគ្រប់គ្រងស្ទែមត្រូវជានាបានទទួលតំណភ្ជាប់ស្វ័យវង្វាយតម្លៃវឌ្ឍនភាព។

- ការបំពេញស្វ័យវង្វាយតម្លៃវឌ្ឍនភាពគណៈគ្រប់គ្រងស្នែមត្រូវធ្វើឡើងក្រោយពេល6ខែពីបានបំពេញស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រារួច។
- គណៈគ្រប់គ្រងសាលារៀននឹងត្រូវតាមដាន និងធានាថាគ្រប់សមាជិកទាំងអស់នៃគណៈគ្រប់គ្រងស្នែមរួមមានទាំងប្រធានមុខវិជ្ជាស្នែមផងដែរ បានបញ្ចប់ការធ្វើស្វ័យវាយតម្លៃវឌ្ឍនភាពនេះ។
- គ្រូបង្គោលវ.ជ.អនឹងចែករំលែកទិន្នន័យវិភាគប្រៀបធៀប (ភាពខុសគ្នារវាងលទ្ធផលក្នុងការធ្វើស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រា និងស្វ័យវង្វាយតម្លៃវឌ្ឍនភាពសម្រាប់សាលារៀននីមួយៗ និងចែកចាយលទ្ធផលទៅកាន់គណៈគ្រប់គ្រងសាលារៀនដែលសមស្រប។ ការចែករំលែកទិន្នន័យនេះនឹងជួយឱ្យគេអាចកំណត់នូវសេចក្តីត្រូវការរបស់សមាជិកម្នាក់នៃគណៈគ្រប់គ្រងស្នែម និងការអភិវឌ្ឍន៍របស់ពួកគាត់។
- ដំណើរការនេះអាចត្រូវបានធ្វើម្តងទៀតរៀងរាល់ 6 ខែម្តង ដើម្បីធានាថាគណៈគ្រប់គ្រងសាលារៀន ប្រធានមុខវិជ្ជាស្នែម និងវិទ្យាស្ថានជាតិអប់រំមានទំនុកចិត្តថាពួកគាត់រៀបចំផែនការ និងផ្តល់ការគាំទ្រដ៏សមស្របដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្សលើមុខវិជ្ជាស្នែម។
- គណៈគ្រប់គ្រងស្នែមថ្មីតម្រូវឱ្យធ្វើស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រាឱ្យបានឆាប់រហ័សនាពេលដែលចូលកាន់តួនាទីរបស់ខ្លួន ដើម្បីធានាបាននូវដំណើរការបរិយាប័ន្នការងារដែលធានាថាមន្ត្រីកាន់ការងារអប់រំស្នែមគ្រប់រូបអាចទទួលបានឱកាសអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

## អ្នកចូលរួម

- គ្រូបង្គោលវ.ជ.អ - ផ្តល់នូវតំណភ្ជាប់ស្ទង់មតិស្វ័យវង្វាយតម្លៃ និងសម្របសម្រួលរៀបចំផែនការ និង ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈជាប្រចាំ។
- គណៈគ្រប់គ្រងស្នែម (ក្រុមស្នូលលើការងារអប់រំស្នែម) - ស្វ័យវង្វាយតម្លៃវឌ្ឍនភាព និងរៀបចំផែនការបណ្តុះបណ្តាលវិជ្ជាជីវៈជាប្រចាំកម្រិតបុគ្គល។ ពួកគាត់ត្រូវបន្តពិនិត្យតាមដានវឌ្ឍនភាពនៅពេលប្រជុំ។
- គណៈគ្រប់គ្រងស្នែម និងគ្រូបង្គោលវ.ជ.អ - ប្រជុំពិនិត្យតាមដានតាមអនឡាញនៅចុងឆ្នាំលើការបណ្តុះបណ្តាលវិជ្ជាជីវៈជាប្រចាំ។

## ពេលវេលា

- ស្វ័យវង្វាយតម្លៃវឌ្ឍនភាពគណៈគ្រប់គ្រងស្នែមធ្វើឡើងនៅចុងឆមាសទី1 និងចុងឆមាសទី2នៃឆ្នាំសិក្សា។
- វ.ជ.អចេញលទ្ធផលជូនគ.គ.សរយៈពេល 1 សប្តាហ៍បន្ទាប់ពីការបំពេញស្វ័យតម្លៃវឌ្ឍនភាព។
- គ.គ.សវិភាគលទ្ធផល និងរៀបចំផែនការសកម្មភាពកម្រិតបុគ្គលក្នុងរយៈពេល 2 សប្តាហ៍។
- គ.គ.ស និងវ.ជ.អ រៀបចំផែនការ និងផ្តល់ការបណ្តុះបណ្តាល - បន្តជាប្រចាំ។
- គ.គ.សពិនិត្យមើលវឌ្ឍនភាព (ផ្ទៀងផ្ទាត់ផែនការសកម្មភាពផ្ទាល់ខ្លួន) នៅចន្លោះពេលទៀងទាត់ (របៀបវារៈកិច្ចប្រជុំគ.គ.ស)

- គ.គ.ស និងគ្រូបង្គោលវ.ជ.អពិនិត្យមើលវឌ្ឍនភាព (ផ្ទៀងផ្ទាត់ទៅនឹងផែនការសកម្មភាពកម្រិតបុគ្គល) នៅចុងបញ្ចប់នៃឆមាសទី 2 ។

## 4. ឧបករណ៍សង្កេតលម្អិតលើការបង្រៀនស្នែម (ឧបសម្ព័ន្ធ គ)

គណៈគ្រប់គ្រងស្នែមនឹងប្រើប្រាស់ឧបករណ៍សង្កេតលម្អិតលើការបង្រៀនស្នែម (ឧបសម្ព័ន្ធ គ) ដើម្បីសង្កេតមើលមើលការបង្រៀនរបស់គ្រូបង្រៀនស្នែមម្នាក់ៗតាមកាលវិភាគបង្រៀនដ៏សមស្របរបស់ពួកគាត់ជាប្រចាំ។ ការសង្កេតនេះត្រូវធ្វើយ៉ាងហោចណាស់ ២ដងក្នុងមួយឆ្នាំ។ កាធ្វើបែបនេះនិងផ្តល់ឱកាសបន្ថែមដល់ការសង្កេតឱ្យបានញឹកញាប់បន្ថែមទៀតទៅកាន់គ្រូបង្រៀនថ្មីៗផ្សេងទៀត ដែលមានបទពិសោធន៍បង្រៀននៅតិច ឬដំណើរការបង្រៀននៅមិនទាន់ល្អនៅឡើយ (គ្រូបង្រៀនដែលបង្រៀនសិស្សមិនទាន់ទទួលបានលទ្ធផលល្អនៅឡើយ)។ គណៈគ្រប់គ្រងស្នែមនឹងអាចកំណត់បាននូវចំណុចនានាជុំវិញការអនុវត្តការបង្រៀនដែលល្អប្រសើរ និងផ្នែកដែលត្រូវការការអភិវឌ្ឍន៍បន្ថែមទៀត។ គណៈគ្រប់គ្រងស្នែមក៏យល់ដឹងពីទិដ្ឋភាពរួមនៃគុណភាពនៃដំណើរការបង្រៀន ការរៀន និងការវាយតម្លៃស្នែមនៅក្នុងសាលារៀនរបស់ពួកគាត់។ ដូចគ្នានេះដែរអ្នកប្រឹក្សាផ្នែកស្នែម និងក្រុមគ្រូបង្រៀនអាចប្រើប្រាស់ឧបករណ៍សង្កេតលម្អិតលើការបង្រៀនស្នែមរួមគ្នា ដើម្បីបង្កើតបរិយាកាសដ៏ល្អដល់ការបង្រៀន ការរៀន និងការវាយតម្លៃប្រកបដោយមេត្រីភាព។

ការធ្វើការសង្កេតដោយប្រើប្រាស់ការសង្កេតមេរៀនផ្តល់នូវការគាំទ្រ និងដំណើរការអភិវឌ្ឍន៍ដល់គ្រូបង្រៀន (O'Leary, 2023)។ របាយការណ៍ធ្វើការសង្កេតលើការបង្រៀនអាចយកមកប្រើប្រាស់ដើម្បីកំណត់គោលដៅគាំទ្រដល់ការអភិវឌ្ឍន៍វិជ្ជាជីវៈសម្រាប់គ្រូបង្រៀនម្នាក់ៗ ឬនៅពេលដែលសំយោគទិន្នន័យ និងលទ្ធផលទាំងមូលចប់សព្វគ្រប់ហើយ យើងអាចដឹងថាតើនរណាត្រូវការបណ្តុះបណ្តាលដូចគ្នា។ អ្វីដែលសំខាន់គឺអ្នកការសង្កេតក្នុងពេលធ្វើការសង្កេតត្រូវការឱកាសដើម្បីផ្តោតលើការសង្កេតយ៉ាងហ្មត់ចត់ និងត្រូវមានសមត្ថភាពក្នុងការសម្រេចចិត្ត និងផ្តល់អាទិភាពលើចំណុចសម្រាប់ការអភិវឌ្ឍន៍ដោយការសហការជាមួយអ្នកការសង្កេតដ៏ទៃទៀត (O'Leary, 2013) ។ គ្រូបង្រៀនគួរតែប្រើប្រាស់លទ្ធផលនៃឧបករណ៍ស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រា ឧបករណ៍ស្វ័យវង្វាយតម្លៃលើឌ្ឍនភាព និងមតិកែលម្អពីការធ្វើការសង្កេតរបស់ពួកគាត់ ដើម្បីកំណត់ និងអភិវឌ្ឍផ្នែកដែលមានភាពស្រពិចស្រពិលជុំវិញការបង្រៀន ការរៀន និងការវាយតម្លៃស្នែម ។ តាមរយៈដំណើរការនេះ ការផ្តោតសំខាន់នៃការធ្វើការសង្កេតរបស់គ្រូបង្រៀនត្រូវតែផ្តោតលើគុណភាពនៃការសិក្សារបស់សិស្ស (ពោលគឺការរីកចំរើនរបស់សិស្ស) ជាជាងការអនុវត្តរបស់គ្រូបង្រៀន។

ឧបករណ៍នេះត្រូវបន្សុីគ្នា ជាពិសេសជាមួយនឹងស្តង់ដាស្នែមទាំង15 ហើយក៏រួមបញ្ចូលផងដែរជាមួយ ការបង្រៀនទូទៅ ការរៀន និងសូចនាករវាយតម្លៃដែលមាននៅក្នុងឧបករណ៍ស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រា និងឧបករណ៍ស្វ័យវង្វាយតម្លៃលើវឌ្ឍនភាពគ្រូបង្រៀនស្នែម។ វាជាឧបករណ៍វាយតម្លៃតាមដំណាក់ ដើម្បីពិនិត្យតាមដាន និងកែលម្អគុណភាព និងលទ្ធផលសម្រាប់សិស្ស។

សម្រាប់ជំហានដំបូងទាំងនេះនៃការអភិវឌ្ឍន៍គុណភាពនៃការបង្រៀន ការរៀន និងការវាយតម្លៃដោយមិនមានការគំរាមកំហែងបន្លាចដល់អ្នកចូលរួម គឺមានសារៈសំខាន់ក្នុងការទ្រទ្រង់ និងការកែលម្អជាប្រចាំប្រកបដោយនិន្តរភា

៣។ តំណាក់កាលចុងក្រោយគឺគំរូផ្សេងទៀតអាចនឹងលេចចេញ និងអភិវឌ្ឍឡើង ដែលជាកាគាំទ្រការកែលម្អការបង្រៀន ការរៀន និងការវាយតម្លៃស្ទែមប្រកបដោយគុណភាព និងនិរន្តរភាព។

**ទិដ្ឋភាពទូទៅ៖ ឧបករណ៍សង្កេតលម្អិតលើការបង្រៀនស្ទែម**

ឧបករណ៍នេះផ្ដល់នូវក្របខ័ណ្ឌសម្រាប់គណៈគ្រប់គ្រងស្ទែមប្រើប្រាស់សម្រាប់ឈ្វេងយល់បន្ថែមលើតម្រូវការអភិវឌ្ឍរបស់គ្រូបង្រៀនស្ទែម។ ឧបករណ៍វាយតម្លៃនេះនឹងផ្ដល់ឱ្យគណៈគ្រប់គ្រងស្ទែម គ្រូបង្រៀន និងអ្នកណែនាំប្រឹក្សាយោបល់នូវព័ត៌មានអំពីគុណភាពនៃការបង្រៀន ការរៀន និងការវាយតម្លៃមុខវិជ្ជាស្ទែមដើម្បីផ្តល់ព័ត៌មានអំពីតម្រូវការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន។

## វត្ថុបំណង

ដើម្បីផ្ដល់នូវយន្តការពិនិត្យតាមដានដែលអាចបត់បែនបាន និងគាំទ្រសម្រាប់បុគ្គលិកអប់រំផ្នែកស្ទែមទាំងអស់នៅក្នុងសាលារៀនរួមមាន គ្រូបង្រៀន អ្នកណែនាំ អ្នកប្រឹក្សាយោបល់ មិត្តរួមការងារ និងគណៈគ្រប់គ្រងស្ទែម ដើម្បីកំណត់ភាពខ្លាំង និងផ្នែកដែលត្រូវការអភិវឌ្ឍបន្ថែមហើយធ្វើការលើការចែករំលែកភាពខ្លាំង និងការកែលម្អទាំងនោះសម្រាប់ការអភិវឌ្ឍន៍ក្នុងការបង្រៀន ការរៀន និងការវាយតម្លៃលើមុខវិជ្ជាស្ទែម។

## ដំណើរការ

## គំនូសតាងបង្ហាញលំហូរប្រើប្រាស់ឧបករណ៍




## ដំណើរការ

- គ្រូបង្រៀនស្ទែមទទួលយកការធ្វើស្ទ័យវង្វាយតម្លៃទិន្នន័យដើមគ្រារបស់គ្រូបង្រៀនស្ទែម( ឧបសម្ព័ន្ធ ឆ )
- ចំណុចត្រូវអភិវឌ្ឍបន្ថែមត្រូវបានកំណត់ និងបញ្ចូលក្នុងផែនការអភិវឌ្ឍវិជ្ជាជីវៈកម្រិតបុគ្គល( ឧបសម្ព័ន្ធ ច )

- គ្រូបង្រៀនស្នែមត្រូវធ្វើការពិភាក្សាជាមួយគ្រូបង្រៀនរួមអាជីពរបស់ខ្លួន គណៈគ្រប់គ្រងស្នែម និងអ្នកប្រឹក្សាយោបល់ដើម្បីរៀបចំការធ្វើផែនការសង្កេតការបង្រៀន ។ គ្រូស្នែម
អាចសង្កេតមើលសហសេវិកដែលមានបទពិសោធន៍ច្រើនជាងរបស់ពួកគេ
ឬមិត្តរួមការងារអាចសង្កេតមើលពួកគេ។ ឧបករណ៍សង្កេតលម្អិតលើការបង្រៀនស្នែម( ឧបសម្ព័ន្ធ គ )
ត្រូវបានប្រើប្រាស់ដើម្បីផ្តល់ការវាយការណ៍។
- ការណែនាំ/ការប្រឹក្សាយោបល់អាចធ្វើឡើងដោយផ្តោតលើតម្រូវការបុគ្គលរបស់គ្រូបង្រៀនស្នែមម្នាក់ៗ។ សមាជិកណាមួយនៃគ្រូបង្រៀនស្នែមដែលមានចំណេះដឹង និងបទពិសោធច្រើនអាចបង្ហាញគំរូនេះបាន។
- ការសង្កេតការបង្រៀនរៀបចំឡើង អមដោយការពិភាក្សាប្រកបដោយវិជ្ជាជីវៈអំពីរបៀបកែលម្អការអនុវត្តការបង្រៀន។
- សមាជិកម្នាក់នៃគណៈគ្រប់គ្រងស្នែមអនុវត្តការសង្កេត ឬការធ្វើការសង្កេតលើគ្រូបង្រៀនស្នែមម្នាក់ៗ យ៉ាងហោចណាស់ម្តងក្នុងមួយឆ្នាំ។
- គ្រូបង្រៀនស្នែមពិនិត្យមើលវឌ្ឍនភាពដោយផ្ទៀតផ្ទាត់ទៅនឹងផែនការសកម្មភាពកម្រិតបុគ្គល
របស់ពួកគេជាមួយសមាជិកផ្សេងៗទៀត។
បន្ទាប់មកពួកគេរៀបចំផែនការសម្រាប់ការកែលម្អនាពេលអនាគត និងបន្តវដ្តវិលជុំនៃការអភិវឌ្ឍវិជ្ជាជីវៈ ។

### អ្នកចូលរួម

- គ្រូបង្គោលវ.ជ.អ ៖ ពិនិត្យមើលវឌ្ឍនភាពនៃការសង្កេតក្នុងអំឡុងពេលពិភាក្សាប្រចាំឆ្នាំ។
- គណៈគ្រប់គ្រងស្នែម៖ (អនុវត្តការធ្វើការសង្កេតលើការបង្រៀនរបស់គ្រូបង្រៀនស្នែម និងបំពេញព័ត៌មានចូលក្នុងឧបករណ៍ធ្វើការសង្កេតលម្អិតលើការបង្រៀន-ជាអប្បបរមាម្តងក្នុងមួយឆ្នាំ)។
- អ្នកណែនាំ អ្នកប្រឹក្សាយោបល់ និងគ្រូបង្រៀនស្នែមជាមិត្តរួមអាជីព៖ ជ្រើសរើសដោយគ្រូ ស្នែម ដោយមានការព្រមព្រៀងរវាងភាគីទាំងអស់។

### ពេលវេលា

- ការធ្វើការសង្កេតលម្អិតត្រូវអនុវត្តយ៉ាងហោចណាស់មួយដងក្នុងមួយឆ្នាំ និងតាមដានតម្រូវការអភិវឌ្ឍវិជ្ជាជីវៈ ។
- គ្រូបង្រៀនស្នែមកំណត់តម្រូវការអភិវឌ្ឍវិជ្ជាជីវៈរបស់ពួកគាត់បន្ទាប់ពីការធ្វើស្វ័យវាយតម្លៃទិន្នន័យដើមគ្រាការពិនិត្យវឌ្ឍនភាព និងការធ្វើការសង្កេតរបស់គណៈគ្រប់គ្រងស្នែម។
- អ្នកណែនាំ គ្រូប្រឹក្សាយោបល់ និងមិត្តរួមការងារប្រើប្រាស់វិធីសាស្ត្រធ្វើការសង្កេតនេះ ដើម្បីជួយកំណត់ចំណុច និងតម្រូវការវិជ្ជាជីវៈបន្ថែម ។ ការសង្កេតការបង្រៀននេះអាចធ្វើញឹកញាប់តាមតម្រូវការរបស់គ្រូបង្រៀនមុខវិជ្ជាស្នែម ព្រោះវាជាដំណើរការបន្តជាប្រចាំ។

## 5. ការសង្កេតរហ័សលើការបង្រៀនស្នែម ( ឧបសម្ព័ន្ធ ឃ )

ការសង្កេតរហ័សលើការបង្រៀនស្នែមដើរតួនាទីស្រដៀងគ្នាទៅនឹងការធ្វើការសង្កេតលម្អិតលើការបង្រៀនស្នែម ដែរគ្រាន់តែខុសគ្នាត្រង់ថាការសង្កេតនេះប្រើប្រាស់រយៈពេលខ្លីជាងតែប៉ុណ្ណោះ។ គណៈគ្រប់គ្រងស្នែម គ្រូ

បង្រៀន និងគ្រូប្រឹក្សាយោបល់ផ្នែកស្នែមគ្រាន់តែធ្វើការដើរឆ្លងកាត់ថ្នាក់បង្រៀនស្នែមនីមួយៗក្នុងរយៈពេលដ៏ខ្លីបំផុត (អតិបរមា 5 ឬ10នាទីក្នុងថ្នាក់នីមួយៗ) ដោយមានការផ្តោតយ៉ាងច្បាស់លាស់អំពីអ្វីដែលពួកគាត់ចង់សង្កេត។ ឧទាហរណ៍គណៈគ្រប់គ្រងស្នែមអាចសម្រេចចិត្តថាពួកគាត់ចង់ឱ្យការដើរសង្កេតថ្នាក់នីមួយៗផ្តោតលើសុវត្ថិភាព ក្នុងបន្ទប់ពិសោធន៍។ នៅពេលពួកគាត់ដើរសង្កេតធតាមថ្នាក់ឬបន្ទប់ពិសោធន៍វិទ្យាសាស្ត្រនីមួយៗ ពួកគាត់អាចពិនិត្យមើលថាតើគ្រូបង្រៀន និងសិស្សបានអនុវត្តតាមវិធានការសុខភាពនិងសុវត្ថិភាពដែរឬទេ។ នេះអាចជាឧទាហរណ៍នៃការវាយតម្លៃហានិភ័យជាលាយលក្ខណ៍អក្សរសម្រាប់ការពិសោធន៍ ដែលក្នុងការពិសោធន៍នោះ ពួកគាត់បានគោរពធតាមគោលការណែនាំអំពីសុខភាពនិងសុវត្ថិភាព និងពួកគាត់មានការយល់ដឹងអំពីគ្រោះថ្នាក់ជាមួយការប្រើប្រាស់ឧបករណ៍ និងសម្ភារៈពិសោធន៍ទាំងនោះ។ ផ្នែកផ្សេងទៀតគឺផ្តោតលើការយកចិត្តទុកដាក់ទៅលើ ផែនការបង្រៀន ការវាយតម្លៃតាមដំណាក់ ការចូលរួមរបស់សិស្ស ល្បឿននៃការបង្រៀនមេរៀន គុណភាពនៃការសួរសំណួរ និងចម្លើយជាដើម។

ប្រភេទនៃការសង្កេតនេះអាចកំណត់បានយ៉ាងឆាប់រហ័សចំពោះការអនុវត្តល្អៗ និងផ្នែកដែលត្រូវការកែលម្អ។ អ្វីទាំងនេះគឺជាផែនការដ៏ល្អបំផុត នៅពេលដែលសកម្មភាពនៃការសង្កេតទាំងនេះត្រូវបានផ្តោតការយកចិត្តទុកដាក់នៅក្នុងការធ្វើពិសោធ និងថ្នាក់រៀនដែលពាក់ព័ន្ធ ដែលគណៈគ្រប់គ្រង និងគ្រូបង្រៀនបង្រៀនស្នែម អាចបង្ហាញព្រួយបារម្ភណាមួយចំចំពោះការបង្រៀននេះ។ អ្វីដែលសំខាន់គឺការផ្តោតការយកចិត្តទុកដាក់លើការសិក្សារបស់សិស្ស (មានន័យថាការរីកចម្រើនរបស់សិស្ស) ជាជាងការអនុវត្តន៍របស់គ្រូបង្រៀន។ ជាធម្មតាគ្រូបង្រៀនមិនត្រូវបានគេប្រាប់ទុកមុនសម្រាប់ការសង្កេតនេះឡើយ ប៉ុន្តែមានគោលបំណងហេតុផលសមស្របណាមួយដែលគាំទ្រដល់គ្រូបង្រៀន។ ការសង្កេតនេះប្រហែលជាកើតឡើង ប្រសិនបើគ្រូបង្រៀនណាម្នាក់ត្រូវការការគាំទ្រពីគ្រូបង្រៀនដែលមានបទពិសោធន៍ច្រើនឆ្នាំ ដើម្បីចូលរួមសង្កេតមើលការអនុវត្តជាក់លាក់របស់ខ្លួន។

ការសង្កេតរហ័សលើការបង្រៀនស្នែម គឺនឹងជួយផ្តល់មតិកែលម្អជាពិសេសអំពីប្រធានបទដែលបានគ្រោងទុក។ វានឹងកំណត់ចំណុចនៃការអនុវត្តល្អៗ និងផ្នែកដែលត្រូវការកែលម្អទាំងនោះ។ លទ្ធផល និងសកម្មភាពនេះអាចត្រូវបានបន្ថែមទៅក្នុងផែនការសកម្មភាពគណៈគ្រប់គ្រងស្នែម( ឧបសម្ព័ន្ធ ង) និងផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈស្នែមជាប្រចាំកម្រិតបុគ្គល ( ឧបសម្ព័ន្ធ ច)។ ការពិនិត្យតាមដានឡើងវិញជាប្រចាំអំពីវឌ្ឍនភាព និងផលជះនឹងមានវត្តមាននៅពេលនោះ។

## ទិដ្ឋភាពទូទៅ៖ ឧបករណ៍សង្កេតរហ័សលើការបង្រៀនស្នែម

ឧបករណ៍សង្កេតរហ័សលើការបង្រៀនស្នែម ( ឧបសម្ព័ន្ធ ឃ) ត្រូវបានចងក្រងឡើងដើម្បីផ្តោតលើការសង្កេតដែលមានចំណុចជាច្រើនត្រូវបានយកមកពិនិត្យនៅពេលដែលគ្រូបង្រៀនមេរៀនស្នែម។ គ្រូបង្រៀនមុខវិជ្ជាស្នែមផ្តល់ពេលវេលាសមស្របដល់គណៈគ្រប់គ្រងស្នែម ដើម្បីសង្កេតមើលគុណភាពនៃការបង្រៀនមេរៀនស្នែមនៅក្នុងថ្នាក់រៀន ក៏ដូចជាអ្វីដែលកំពុងកើតឡើងជាប្រចាំ និងជួយគាំទ្រការ កែលម្អ ដោយផ្តល់ការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំដល់គ្រូបង្រៀនមុខវិជ្ជាស្នែម។

## វត្ថុបំណង

ឧបករណ៍នេះផ្តល់នូវវិធីសាស្រ្តសង្ខេបដែលជួយគាំទ្រដល់ដំណើរការអនុវត្ត និងផ្តោតលើការតាមដាន និងសង្កេតការអនុវត្ត ការបង្រៀន ការរៀន និងការវាយតម្លៃរបស់គ្រូបង្រៀនមុខវិជ្ជាស្នែមនៅក្នុងថ្នាក់រៀន និងបន្ទប់ពិសោធន៍ច្រើនដងក្នុងមួយឆ្នាំ។ យន្តការគាំទ្រសម្រាប់បុគ្គលិកទទួលបន្ទុកការងារអប់រំស្នែមរួមមាន គ្រូបង្រៀន អ្នកណែនាំ គ្រូប្រឹក្សាយោបល់ ក្រុមគ្រូបង្រៀនរួមការងារជាមួយ និងគណៈគ្រប់គ្រងស្នែមដើម្បីកំណត់ភាពខ្លាំង និងផ្នែកសម្រាប់ការអភិវឌ្ឍបន្ថែមហើយធ្វើការលើការចែករំលែកភាពខ្លាំងទាំងនោះ និងកែលម្អផ្នែកទាំងនោះសម្រាប់ការអភិវឌ្ឍន៍ក្នុងការបង្រៀន ការរៀន និងការវាយតម្លៃលើមុខវិជ្ជាស្នែម ។

## ដំណើរការ

## គំនូសតាងលំហូរ




## ដំណើរការ

- អនុវត្តស្វ័យវាយតម្លៃទិន្នន័យដើមគ្រា និងស្វ័យវាយតម្លៃវឌ្ឍនភាព គណៈគ្រប់គ្រងស្នែមអាចប្រើប្រាស់ និងកំណត់ចំណុចដែលគួរកែលម្អដ៏ជាក់លាក់។
- គណៈគ្រប់គ្រងស្នែមក៏អាចពិនិត្យមើលចំណុចដែលត្រូវកែលម្អផងដែរឧទាហរណ៍ ផ្នែកសុខភាព និងសុវត្ថិភាព។
- គណៈគ្រប់គ្រងស្នែមជ្រើសរើសប្រធានបទមួយ ឬពីរដើម្បីជាមូលដ្ឋាននៃការសង្កេត។
- គណៈគ្រប់គ្រងស្នែមអនុវត្តការដើរឆ្លងកាត់ក្នុងថ្នាក់/បន្ទប់ពិសោធន៍ឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។
- គណៈគ្រប់គ្រងស្នែមផ្តល់មតិត្រឡប់អំពីលទ្ធផល និងភារៈកិច្ចរបស់បុគ្គលិកស្នែម ដើម្បីរៀបចំផែនការអភិវឌ្ឍវិជ្ជាជីវៈជាមួយមិត្តរួមការងារ អ្នកណែនាំ គ្រូបង្វឹក ឬគណៈគ្រប់គ្រងស្នែម។
- គ្រូបង្រៀនស្នែមបំពេញបន្ថែមទៅលើផែនការសកម្មភាពកម្រិតបុគ្គលរបស់ពួកគាត់ និងចូលរួមក្នុងសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈ ។
- ភាគីទាំងអស់ពិនិត្យមើលវឌ្ឍនភាពឈានឆ្ពោះទៅរកគោលដៅសម្រេចបាននូវសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈ។

- គណៈគ្រប់គ្រងស្វែមអនុវត្តការសង្កេតរហ័ស ដើម្បីពិនិត្យមើលថាតើការអនុវត្តមានភាពប្រសើរឡើងដែរឬទេ។
- គណៈគ្រប់គ្រងស្វែមអនុវត្តការធ្វើការសង្កេតរហ័សបន្ថែមទៀតដើម្បីពិនិត្យមើលចំណុចគួរកែលម្អ។
- គណៈគ្រប់គ្រងស្វែមពិនិត្យមើលវឌ្ឍនភាពក្នុងកំឡុងពេលកិច្ចប្រជុំ។

### អ្នកចូលរួម

- គណៈគ្រប់គ្រងស្វែម - អនុវត្តការសង្កេតឆ្លងកាត់តាមតម្រូវការ និងនៅពេលចាំបាច់។
- គណៈគ្រប់គ្រងស្វែម អ្នកណែនាំ គ្រូប្រឹក្សាយោបល់ និងករួមការងារជាមួយផ្តល់សកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈ។

### ពេលវេលា

- ការផ្តោតលើការសង្កេតអាចត្រូវបានពិនិត្យមើលការវិភាគស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រារបស់គ្រូបង្រៀនមុខវិជ្ជាស្វែមកន្លងមក។ សប្តាហ៍ទី 4/5
- គណៈគ្រប់គ្រងស្វែមអនុវត្តការសង្កេតជាប្រចាំពេញមួយឆ្នាំ។ តាមស្ថានភាព និងពេលវេលាចាំបាច់។
- អនុវត្តសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈដោយផ្ទៀងផ្ទាត់ទៅនឹងលទ្ធផលស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រា ស្វ័យវង្វាយតម្លៃវឌ្ឍនភាព  និងការបង្ហាញលទ្ធផលនៃការសង្កេតរហ័ស។
- អ្នកណែនាំ គ្រូប្រឹក្សាយោបល់ និងមិត្តរួមការងារគាំទ្រដើម្បីជួយកំណត់ពីចំណុចត្រូវកែលម្អ និងតម្រូវការអភិវឌ្ឍវិជ្ជាជីវៈ ។ គឺជាដំណើរការបន្តជាប្រចាំ។
- គណៈគ្រប់គ្រងស្វែមនឹងពិនិត្យតាមដានមើលលទ្ធផលនៅពេលប្រជុំ។

## 6. ផែនការសកម្មភាពគណៈគ្រប់គ្រងស្វែមកម្រិតសាលារៀន ( ឧបសម្ព័ន្ធ ង )

ផែនការសកម្មភាពគណៈគ្រប់គ្រងស្វែមនៅកម្រិតសាលារៀនគឺជាឯកសារដែលមានកំណត់ជំហានដែលត្រូវធ្វើឡើង ដើម្បីសម្រេចបាននូវគោលដៅមួយឬច្រើន។ ទម្រង់នេះគឺញែកគោលដៅដែលមានច្រើនទៅជាជំហានតូចៗដែលអាចធ្វើសកម្មភាពបាន អាចអនុវត្តតាមបាន និងតាមដានបានយ៉ាងងាយស្រួល។

គណៈគ្រប់គ្រងស្វែមនឹងចងក្រងសេចក្តីព្រាងផែនការសកម្មភាពគណៈគ្រប់គ្រងស្វែមកម្រិតសាលាចេញពីទម្រង់ផែនការសកម្មភាពដែលស្ថិតនៅក្នុង ( ឧបសម្ព័ន្ធ ង ) បន្ទាប់ពីការបញ្ចប់ការបំពេញព័ត៌មានចូលក្នុងឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាគណៈគ្រប់គ្រងស្វែម  ( ឧបសម្ព័ន្ធ  ក ) រួចរាល់ហើយ។ ការងារនេះនឹងជួយធានាថាសាលារៀនកំពុងកសាងសមត្ថភាពក្នុងការធ្វើស្វ័យវង្វាយតម្លៃ និងផែនការផ្ទៃក្នុងរបស់ខ្លួន។

គ្រូបង្គោលវិទ្យាស្ថានជាតិអប់រំនឹងពិនិត្យតាមដានមើលផែនការសកម្មភាពរបស់គណៈគ្រប់គ្រងស្វែមនៅកម្រិតសាលារៀន   ដើម្បីវាយតម្លៃថាតើសាលារៀនមានភាពរឹងមាំពិតប្រាកដកម្រិតណា   ការប្រកួតប្រជែងនឹងមានវត្តបំណងច្បាស់លាស់កម្រិតណា។

កិច្ចពិភាក្សាលម្អិតមួយស្តីពីការសរសេរគោលដៅស្មាត( SMART ) នៅលើផែនការសកម្មភាពមានដូចខាងក្រោម។ ទម្រង់ផែនការសកម្មភាពគណៈគ្រប់គ្រងស្វែមកម្រិតសាលារៀន និងទម្រង់ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈស្វែមជាប្រចាំកម្រិតបុគ្គលគឺមានផែនការ និងគោលដៅដែលទាក់ទងនឹងចំណុចជាច្រើន ប៉ុន្តែការផ្តោតសំខាន់គឺនៅលើការអប់រំស្វែម និងការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ។

## ទិដ្ឋភាពទូទៅ៖ ទម្រង់ផែនការសកម្មភាពគណៈគ្រប់គ្រងស្ទែមកម្រិតសាលារៀន

ទម្រង់ផែនការសកម្មភាពគណៈគ្រប់គ្រងស្ទែមកម្រិតសាលារៀនគឺជាទម្រង់រៀបចំផែនការកែលម្អការបង្រៀន ការរៀន និងការវាយតម្លៃស្ទែមនៅកម្រិតសាលារៀនដោយប្រើលទ្ធផលចេញពីឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាគណៈគ្រប់គ្រងស្ទែមក្នុង( ឧបសម្ព័ន្ធ ក )។

## វត្ថុបំណង

ទម្រង់ផែនការសកម្មភាពនេះត្រូវយកមកប្រើប្រាស់ដើម្បីតាមដាន និងកែលម្អគុណភាពនៃការបង្រៀន ការរៀន និងការវាយតម្លៃស្ទែមជាប្រចាំនៅកម្រិតសាលារៀន។ វាផ្តល់នូវសកម្មភាពលម្អិតជាបន្តបន្ទាប់ និងគោលដៅ SMART ដែលផ្តោតលើផ្នែកសម្រាប់ការអភិវឌ្ឍន៍ ដើម្បីកែលម្អលទ្ធផលសិក្សារបស់សិស្សសម្រាប់មុខវិជ្ជាស្ទែមទាំងអស់នៅសាលារៀន។

## ដំណើរការ

## គំនូសតាងលំហូរ




- ឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាគណៈគ្រប់គ្រងស្ទែមបានបញ្ចប់។
- ទិន្នន័យដើមគ្រា ( ការពិនិត្យតាមដានសមស្រប ) ប្រើដើម្បីជាធាតុចូលដល់ការពិនិត្យកិច្ចពិភាក្សា។
- គ.គ.សវិភាគលើទិន្នន័យនៃរបាយការណ៍ការសង្កេតលម្អិត និងការសង្កេតរហ័ស។
- វ.ជ.អ ដើម្បីផ្ញើលទ្ធផលស្វ័យវង្វាយម្លៃទិន្នន័យដើមគ្រា និងស្វ័យវង្វាយតម្លៃវឌ្ឍនភាពរបស់គណៈគ្រប់គ្រងស្ទែម គ្រូបង្រៀនស្ទែម និងសិស្ស។
- គ.គ.ស រៀបចំផែនការសកម្មភាពកម្រិតសាលារៀន ( ឧបសម្ព័ន្ធ ង ) ។

- គ.គ.ស ត្រួតពិនិត្យផែនការសកម្មភាពសាលាកំឡុងពេលប្រជុំ គ.គ.ស ។
- គ.គ.ស និង វ.ជ.អ តាមដានវឌ្ឍនភាពនៃផែនការសកម្មភាពរបស់សាលានៅចុងបញ្ចប់នៃឆមាសទីពីរ និងធ្វើកំណែប្រែលើផែនការងារសម្រាប់ឆ្នាំសិក្សាបន្ទាប់។
- គ.គ.ស បន្តធ្វើការឆ្ពោះទៅរកគោលដៅ SMART លើផែនការសកម្មភាពកម្រិតសាលារៀន ពីមួយឆ្នាំទៅមួយឆ្នាំ។

**អ្នកចូលរួម**

- គ.គ.ស - បញ្ចប់ផែនការសកម្មភាពកម្រិតសាលារផនជាមួយនឹងគោលដៅ SMART ។
- គ.គ.ស - ពិនិត្យតាមដានវឌ្ឍនភាពនៅឯកិច្ចប្រជុំ គ.គ.ស ។
- គ.គ.ស - អនុវត្តការពិនិត្យឡើងវិញនៅខែទី6 នៅចុងបញ្ចប់នៃឆមាសទី 1 ។
- គ.គ.ស និង វ.ជ.អ អនុវត្តការពិនិត្យឡើងវិញនៃផែនការសកម្មភាពរបស់សាលានៅចុងឆមាសទី 2 ។
- គ.គ.ស ធ្វើកំណែប្រែផែនការសកម្មភាពសាលាគោលដៅ SMART ដើម្បីបន្តកែលម្អលទ្ធផលសិស្ស។
- គ.គ.ស បន្តពិនិត្យមើលវឌ្ឍនភាព និងធ្វើបច្ចុប្បន្នភាពសកម្មភាពនៅឯកិច្ចប្រជុំ គ.គ.ស ពីមួយឆ្នាំទៅមួយឆ្នាំ។

**ពេលវេលា**

- ផែនការសកម្មភាពកម្រិតសាលារៀនត្រូវបានបំពេញបន្ទាប់ពីការបញ្ចប់ដំបូងនៃបញ្ជីពិនិត្យការពិភាក្សា – សប្តាហ៍ទី 5 ។
- ការប្រជុំពិនិត្យតាមដានរបស់គ.គ.ស - តាមកាលវិភាគប្រជុំរបស់គ.គ.ស ។
- ការប្រជុំពិនិត្យតាមដានផែនការសកម្មភាពកម្រិតសាលារៀនចុងក្រោយ - ចុងបញ្ចប់នៃឆមាសទី 1 ។

ការប្រជុំពិនិត្យតាមដានរបស់គ.គ.ស/វ.ជ.អ - ចុងបញ្ចប់នៃឆមាសទី 2 ។

## 7. ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំកម្រិតបុគ្គល ( ឧបសម្ព័ន្ធ ច )

គណៈគ្រប់គ្រងស្វែមអាចប្រើទម្រង់ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈស្វែមជាប្រចាំកម្រិតបុគ្គលនេះបន្ថែមទៅលើអ្វីដែល ពួកគាត់កំពុងអនុវត្តជាមួយគ្រូប្រឹក្សាផ្នែកស្វែម។ រឿងបីសំខាន់ដែលគួរចងចាំនោះគឺ1). គោលដៅគឺផ្អែកលើការអនុវត្តវត្តជាក់លាក់ ឬការអនុវត្តណាដែលតម្រូវឱ្យមានការកែលម្អ ដើម្បីផធ្វើឱ្យប្រសើរឡើង ទៅលើលទ្ធផលការសិក្សារបស់សិស្ស 2). គោលដៅដែលបង្កើតឡើងតាមអក្សរកាត់ ថាគោលដៅស្មាត ('SMART Goal') និង 3) ការពិនិត្យឡើងវិញនូវសកម្មភាពដែលត្រូវបានអនុវត្តជាញឹកញាប់ដើម្បីពិនិត្យតាមដានវឌ្ឍនភាព។ ផែនការសកម្មភាពគឺជាឯកសាររស់ដែលទាមទារអោយមានការពិនិត្យជាប្រចាំ និងការធ្វើបច្ចុប្បន្នភាពលើផែនការជាប្រចាំ។

មុនពេលកិច្ចពិភាក្សាលើផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំកម្រិតបុគ្គលលើការអប់រំស្វែម វាមានសារៈសំខាន់ណាស់ក្នុងការកំណត់និយមន័យថាតើការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំគឺជាមានន័យយ៉ាងដូចម្តេចជាមុនសិន ។

## តើការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំគឺជាអ្វី?

ការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ(ការអភិវឌ្ឍវិជ្ជាជីវៈ) គឺជាការរួមបញ្ចូលគ្នានៃវិធីសាស្ត្រ គំនិត និងបច្ចេកទេសជាច្រើន ដែលនឹងជួយដល់គ្រូបង្រៀន និង គណៈគ្រប់គ្រងស្ទែមក្នុងការគ្រប់គ្រងការរៀនសូត្រ ការអភិវឌ្ឍ និងការរីកចម្រើនរបស់ពួកគាត់។ ការផ្តោតសំខាន់ការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំគឺផ្តោតលើសូចនាករការអនុវត្តសំខាន់ៗ (ក្នុងបរិបទនេះគឺជាស្តង់ដារស្ទែមទាំង15)។ ការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ គឺមានអត្ថប្រយោជន៍ដូចជាអាចពន្យល់គ្រូបង្រៀន និងសិស្សថាពិតភពពិតគឺមានសារៈសំខាន់ខ្លាំងណាស់។ កត្តានេះនឹងត្រូវបានឆ្លុះបញ្ចាំងតាមរយៈ ការចូលរួមរបស់សិស្ស និងសេចក្តីរីករាយចំពោះលទ្ធផលនៃការលើកកម្ពស់គុណវុឌ្ឍិស្ទែមរបស់គ្រូបង្រៀន ។ សារសំខាន់មួយទៀតគឺថាការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំគឺជាការជួយគាំទ្រការអនុវត្តរួមគ្នា និងការអភិវឌ្ឍន៍កម្រិតបុគ្គលម្នាក់ៗ។ គណៈគ្រប់គ្រងស្ទែម និងគ្រូបង្រៀនទាំងអស់នឹងចូលរួមក្នុងការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំជារៀងរាល់ឆ្នាំដែលការអភិវឌ្ឍន៍វិជ្ជាជីវៈនេះនឹងត្រូវបានកែសម្រួលទៅតាមសេចក្តីត្រូវការ និងការអភិវឌ្ឍស្ទែមរបស់បុគ្គលម្នាក់ៗ។

ប្រធានបទដែលអាចអាចរួមបញ្ចូលក្នុងការអភិវឌ្ឍវិជ្ជាជីវៈរួមមាន៖

- បរិយាប័ន្ន និងសមភាព (បំពេញសេចក្តីត្រូវការរបស់សិស្សម្នាក់ៗ)
- ការរៀបចំផែនការសិក្សាមុខវិជ្ជាស្ទែម
- ការកំណត់ប្រភេទសិស្ស (កំណត់នូវសេចក្តីត្រូវការរបស់សិស្សម្នាក់ៗក្នុងគោលបំណងធ្វើផែនការ)
- ការបង្រៀនបែបគិតរិះរក (IBL)
- ការសិក្សាផ្អែកលើបញ្ហាការសិក្សាផ្អែកលើការអនុវត្ត ឬការពិសោធន៍
- ការប្រើប្រាស់ឧបករណ៍សម្រាប់ធ្វើពិសោធ
- ការវាយតម្លៃតាមដំណាក់
- ការគិតបែបស៊ីជម្រៅ

ការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំអាចធ្វើឡើងតាមរយៈការជួបដោយផ្ទាល់1និង1 វគ្គការបង្វឹកឬការណែនាំ ការគាំទ្រពីមិត្តភ័ក្តិ(គ្រូជួយគ្រូ) ការធ្វើការសង្កេត ឬការសង្កេតការគាំទ្រនៅក្នុងថ្នាក់ ការស្រាវជ្រាវប្រតិបត្តិ ការរំលឹកទ្រឹស្តីចេញពីកាលិកប្បត្តិស្រាជ្រាវ សហគមន៍សិក្សាវិជ្ជាជីវៈ ស្វ័យឆ្លុះបញ្ចាំងទិនានុប្បវត្តិសិក្សា ឬស្វ័យសិក្សាឬតាមប្រពន្ធ័អ៊ីនធឺណិត។ ការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំកើតឡើង ប្រសិនបើសកម្មភាពទាំងអស់នេះអាចផ្ទៀងផ្ទាត់បាន និងនាំទៅរកការអភិវឌ្ឍគុណវុឌ្ឍិរបស់គ្រូបង្រៀន ។

ការគាំទ្រពីមិត្តភ័ក្តិជាក្រុមគ្រូបង្រៀន (គ្រូជួយគ្រូ) អាចជាវិធីសាស្ត្រដ៏មានប្រយោជន៍លើការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ និងជាដំណើរការជួយគាំទ្របន្ថែម។ ការគាំទ្រពីក្រុមគ្រូបង្រៀនអាចកើតឡើងដោយមានជាសកម្មភាព ដូចខាងក្រោម៖

- ចែករំលែកគំនិតគ្នាជុំវិញការបង្រៀន ការរៀន និងការវាយតម្លៃ – ការពិសោធន៍ ការបង្រៀនបែបគិតរិះរក (IBL) ការផ្សារភ្ជាប់ទៅនឹងបាតុភូតជាក់ស្តែង ការភ្ជាប់មុខវិជ្ជាស្ទែមផ្សេងៗទៀត ការរៀនសូត្រសកម្ម និងការសួរសំណួរប្រកបដោយប្រសិទ្ធភាពជាដើម។

- ចែករំលែកគំនិត និងធ្វើបច្ចុប្បន្នកម្មជុំវិញ ចំណេះដឹងលើមុខវិជ្ជាគោលរួមមាន៖ គីមីវិទ្យា IT គណិតវិទ្យា ផែនដី រូបវិទ្យា ជីវវិទ្យា។
- ចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីការធ្វើការសង្កេត។
- ថតវីដេអូខ្លីៗពីការបង្រៀនមេរៀនផ្សេងៗគ្នា (ដោយមានការយល់ព្រមពីមាតាបិតា ឬអាណាព្យាបាលរបស់សិស្សក្នុងករណីចាំបាច់) និងត្រូវពិនិត្យជាមួយមិត្តរួមការងារ។
- ពិនិត្យឡើងវិញទម្រង់ធ្វើការសង្កេត និងស្វែងយល់ពីកត្តាដែលធ្វើឱ្យមេរៀនស្ទែមមានលក្ខណៈល្អប្រសើ។
- រៀបចំគំរូកិច្ចតែងការមេរៀន ដើម្បីរួមបញ្ចូលលក្ខណៈវិនិច្ឆ័យទាំងអស់ដែលមាននៅលើទម្រង់សង្កេតមេរៀន (ស្ទែមកម្រិត3)
- អនុវត្តការសង្កេតលើការបង្រៀនរបស់ក្រុមគ្រូជាមិត្តរួមការងារ ផ្តល់មតិកែលម្អ ពិនិត្យនិងបង្កើតផែនការកែលម្អ (ផ្កាយ 2 និងបំណងប្រាថ្នាជាដើម)
- អនុវត្តការបណ្តុះបណ្តាលស្រាវជ្រាវប្រតិបត្តិ និងការធ្វើការស្រាវជ្រាវប្រតិបត្តិ។
- ចូលរួមជាមួយអ្នកប្រឹក្សាផ្នែកស្ទែម ឬគ្រូបង្វឹក។

## តើគណៈគ្រប់គ្រងស្ទែម និងគ្រូបង្រៀនអាចកំណត់ប្រធានបទសម្រាប់ធ្វើផែនការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំបានយ៉ាងដូចម្តេច?

គណៈគ្រប់គ្រងស្ទែម និងគ្រូបង្រៀនស្ទែមប្រើប្រាស់ឧបករណ៍ស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រា ឧបករណ៍ស្វ័យវង្វាយតម្លៃលើវឌ្ឍនភាពសម្រាប់ការឆ្លុះបញ្ចាំងពីកម្រិតនៃទំនុកចិត្តរបស់ពួកគាត់ និងការកំណត់កត្តា ដែលផ្សារភ្ជាប់ទៅនឹងការបង្រៀន ការរៀន និងការវាយតម្លៃស្ទែម។ គណៈគ្រប់គ្រងស្ទែម និងគ្រូបង្រៀនស្ទែមក៏អាចកំណត់លក្ខណៈផ្សេងៗទៀត ដែលពួកគាត់ចង់អភិវឌ្ឍក្នុងអំឡុងពេលនៃការបំពេញការងារប្រចាំថ្ងៃ។ នៅពេលកំណត់បាននូវអ្វីដែលពួកគាត់ត្រូវការហើយ ការវាយតម្លៃនីមួយៗអាចត្រូវបានពិនិត្យ និងសរសេរដាក់បញ្ចូលទៅក្នុងទម្រង់ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំកម្រិតបុគ្គល។ ដើម្បីឱ្យការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ មានប្រសិទ្ធភាព គេចាំបាច់ត្រូវរៀបចំផែនការឱ្យបានល្អ និងត្រួតពិនិត្យ ឬ តាមដានជាប្រចាំ។

## ទម្រង់ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈស្ទែមជាប្រចាំកម្រិតបុគ្គល

ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈស្ទែមជាប្រចាំកម្រិតបុគ្គលផ្តល់ឱ្យគ្រូបង្រៀន និងគណៈគ្រប់គ្រងស្ទែមការផ្តោតយកចិត្តទុកដាក់មួយ (ឧបសម្ព័ន្ធ ធ) ចាប់យកសេចក្តីត្រូវការក្នុងការបណ្តុះបណ្តាល និងការអភិវឌ្ឍគុណវុឌ្ឍិផ្ទាល់ខ្លួនរបស់ពួកគាត់នៅពេលតែមួយ។ គ្រូបង្រៀនក៏អាចមានផែនការពិភាក្សាជាមួយ គណៈគ្រប់គ្រងស្ទែម អ្នកប្រឹក្សាផ្នែកស្ទែម ឬមិត្តរួមការងារដែលមានបទពិសោធន៍ច្រើនជាងខ្លួនផងដែរ។

មានបីដំណាក់កាល ដែលមានសារៈសំខាន់នៅពេលសរសេរ និងត្រួតពិនិត្យទម្រង់ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈ ស្ទែមជាប្រចាំកម្រិតបុគ្គលនេះ៖

1. កំណត់ពីរឬបីគោលដៅសំខាន់ៗ ដែលអាចកែលម្អលទ្ធផលសិក្សារបស់សិស្ស
2. សរសេរគោលដៅតាមលក្ខខណ្ឌ SMART

3. បន្តការពិនិត្យវឌ្ឍនភាព ឬផលជះដោយពិនិត្យមើលគោលដៅ ហើយសម្របខ្លួនទៅតាមគោលដៅទីមួយប្រសិនបើចាំបាច់។

**ដំណើរការ**

គណៈគ្រប់គ្រងស្នេម ឬគ្រូបង្រៀនបំពេញផែនការសកម្មភាព ( ឧបសម្ព័ន្ធ ឆ ) តាមប្រពន្ធអេឡិចត្រូនិក និងអនុវត្តសកម្មភាពដើម្បីសម្រេចគោលដៅ និងការពិនិត្យឡើងវិញ។ ជាដំបូងបង្អស់ គ្រូបង្រៀនត្រូវបានលើកទឹកចិត្តឱ្យពិនិត្យមើលលទ្ធផលដែលចេញពីឧបករណ៍ស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រារបស់ពួកគាត់ និងកំណត់កន្លែងដែលពួកគាត់មានទំនុកចិត្ត ក្នុងការបង្រៀន ការរៀន និងការវាយតម្លៃស្នេម ។ ការធ្វើបែបនេះជាការបង្កើនក្រមសីលធម៌ដ៏ល្អ និងជួយកំណត់ចំណុចកែលម្អនានាចេញពីការគាំទ្រពីមិត្តរួមការងាររបស់ខ្លួន។ វាគឺជាកន្លែងដែលគ្រូម្នាក់ៗត្រូវធ្វើការជាក្រុមដែលមានកម្រិតទំនុកចិត្តខុសៗគ្នា។ ដូច្នេះពួកគាត់អាចចែករំលែកបទពិសោធន៍ និងរៀនពីគ្នាទៅវិញទៅមកបាន។

> ឧទាហរណ៍៖ គ្រូបង្រៀនពីរនាក់អាចកំណត់ថា ពួកគាត់គ្មានទំនុកចិត្ត នៅពេលដែលសិស្សកំពុងប្រើប្រាស់ឧបករណពិសោធន៍វិទ្យាសាស្ត្រ អំឡុងពេលពិសោធន៍ក្នុងថ្នាក់រៀនរបស់ពួកគាត់។ គ្រូម្នាក់ទៀតប្រហែលជាធ្វើស្វ័យវាយតម្លៃថា គាត់មានទំនុកចិត្តខ្ពស់សម្រាប់សកម្មភាពដូចគ្នានេះ។ ការចូលរួមជាមួយគ្រូទាំងបីនាក់នេះ នៅក្នុងក្រុមគាំទ្រមិត្តភ័ក្តិ ដែលជាកន្លែងពួកគាត់អាចពិភាក្សាអំពីបញ្ហាជាក់លាក់ ធ្វើការសង្កេតគាំទ្រគ្នាទៅវិញទៅមក និងផ្តល់មតិស្ថាបនាប្រកបដោយសក្តានុពលក្នុងការកែលម្អការអនុវត្ត និងកសាងទំនុកចិត្ត។

គេអាចកំណត់ ឧទាហរណ៍ផ្សេងៗទៀតចេញពីលទ្ធផលនៃការស្ទង់មតិទិន្នន័យដើមគ្រា និងវឌ្ឍនភាពលើការពេញចិត្តរបស់សិស្ស។ គេអាចសម្គាល់បានថាសិស្សពិតជាមានភាពធុញទ្រាន់ ដោយសារតែគ្រូបង្រៀន បង្រៀនសិស្សដោយគ្រាន់តែអានចេញពីសៀវភៅសិក្សាគោលនោះ។ មតិកែលម្អប្រកបដោយគុណភាពពីសិស្សអាចប្រើដើម្បីរៀបចំផែនការកែលម្អមេរៀនរបស់គ្រូនោះ។

នៅពេលចំណុចនៃឧត្តមានុវត្ត និងចំណុចកែលម្អត្រូវបានកំណត់បានជាក់លាក់រួចហើយគេត្រូវសរសេរគោលដៅដែលអាចជួយបង្កើតការកែលម្អលទ្ធផលសិក្សាសិស្សបាន។ ដូច្នេះការប្រើប្រាស់ការកំណត់គោលដៅដោយការប្រើប្រាស់គោលការ SMART គឺ ដើម្បីសម្រេចបាននូវសកម្មភាពអភិវឌ្ឍន៍នីមួយៗជាក់លាក់ប្រកបដោយភាពឆ្លាតវៃ។ បើគ្មានការកំណត់គោលដៅដោយប្រើប្រាស់លក្ខខណ្ឌ SMARTទេ គោលដៅគឺពិកបាកក្នុងការសម្រេចបានលទ្ធផល ជាពិសេសលទ្ធផលសិក្សារបស់សិស្សនឹងមិនប្រសើរឡើងដែរ។

## ការកំណត់គោលដៅដោយប្រើប្រាស់លក្ខខណ្ឌ SMART

តើលក្ខខណ្ឌ SMART មានន័យយ៉ាងណាក្នុងការអនុវត្ត? SMART គឺជាអក្សរកាត់ដែលតំណាងឱ្យ៖

| | |
|---|---|
| S = ( Specific) | ជាក់លាក់ |
| M = (Measurable) | អាចវាស់វែងបាន |
| A = ( Achievable) | អាចសម្រេចបាន |

R = ( Relevant) ពាក់ព័ន្ធ

T = ( Timely) ទាន់ពេលវេលា

ការកំណត់គោលដៅដោយប្រើប្រាស់លក្ខខណ្ឌ SMART សម្រាប់សកម្មភាពអភិវឌ្ឍគុណវុឌ្ឍិនីមួយៗនឹងជួយឱ្យគណៈគ្រប់គ្រងស្នែម និងគ្រូបង្រៀនសម្រេចបាននូវគោលដៅរបស់ពួកគាត់លើអភិវឌ្ឍនកម្រិតទំនុកចិត្ត និងកែលម្អលទ្ធផលរបស់សិស្ស។

## ឧទាហរណ៍នៃគោលដៅដែលមិនប្រើប្រាស់លក្ខខណ្ឌ SMART

ដោយមើលលើឧទាហរណ៍ពីប្រអប់ខាងលើ គ្រូបង្រៀនម្នាក់ដែលមិនមានទំនុកចិត្តទាល់តែសោះក្នុងចំណោមគ្រូបង្រៀនទាំងពីរនាក់នោះ បានធ្វើការពិសោធន៍ជាមួយឧបករណ៍ពិសោធន៍នៅក្នុងថ្នាក់រៀនជាមួយនឹងសិស្សរបស់ពួកគាត់។ គាត់បានបំពេញព័ត៌មានក្នុងទម្រង់ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈស្នែមជាប្រចាំ កម្រិតបុគ្គលដូចខាងក្រោម៖

| |
|---|
| ដកស្រង់ចេញពី**ទម្រង់**ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈ ស្នែម ជាប្រចាំ កម្រិតបុគ្គល របស់គ្រូនៅដើមឆ្នាំសិក្សា។<br><br>គោលដៅសម្រាប់ការពិសោធន៍៖<br><br>*"ខ្ញុំចង់អានពីការណែនាំឧបករណ៍ពិសោធន៍ ដូច្នេះខ្ញុំអាចរៀនពីរបៀបប្រើឧបករណ៍ពិសោធន៍វិទ្យាសាស្ត្រ។"* |

គោលដៅនេះ គឺមើលទៅហាក់ដូចជាសមហេតុផលដែរ ប៉ុន្តែវាគឺមានកំហុស។ ហេតុអ្វីបានជាវាមិនមែនជាគោលដៅដែលមានលក្ខខណ្ឌ SMART ?

S = គោលដៅនេះមិនមានភាពជាក់លាក់ទេ ព្រោះគ្រូបង្រៀនមិនបានកំណត់នូវចំណុចណាមួយដែលពួកគាត់ត្រូវរៀនពិតប្រាកដ។ តើឧបករណ៍វិទ្យាសាស្ត្រអ្វីខ្លះ ? មិនមានការលើកឡើងថាតើគោលដៅ នេះនឹងជួយសិស្សរបស់ពួកគេយ៉ាងដូចម្តេច ?- គោលដៅគឺធំទូលាយ និងទូរទៅពេកឬទេ ?

M = គោលដៅមិនអាចវាស់វែងបានទេ ព្រោះវាគ្មានវិធី ដើម្បីដឹងថាវាអាចសម្រេចឬអត់។ តើឧបករណ៍វិទ្យាសាស្ត្រអ្វីខ្លះ ? តើគាត់ចង់អានអ្វី ? អានសៀវភៅអ្វី ? អត្ថបទទិនានុប្បវត្តិមែនទេ ? ចំនួនប៉ុន្មានក្បាលទៅ ? គាត់អាចនឹងធ្វើការលើគោលដៅនេះជាច្រើនខែមែនទេ ?

A = វាពិបាកក្នុងការប៉ាន់ស្មាន ថាតើវាអាចសម្រេចបានឬអត់ ដោយសារវាមិនមានវិធី ដើម្បីដឹងច្បាស់ថាឧបករណ៍មានអ្វីខ្លះនឹងអ្វីដែលត្រូវអាន។ តើវាត្រូវនិងកម្រិតទេ ? តើពួកគេនឹងជ្រើសរើសអក្សរសិល្ប៍បច្ចេកទេសខ្ពស់ ដែលពិបាកពេកឬទេ ?

R = គោលដៅគឺទូលំទូលាយពេក ព្រោះមានការលើកឡើងអំពីឧបករណ៍វិទ្យាសាស្ត្រ ប៉ុន្តែតើវាជាឧបករណ៍ដែលគ្រូបង្រៀនប្រើទេ? ពួកគាត់អាចអំពីការប្រើប្រាស់តេឡេស្កុប ពីព្រោះពួកគាត់ចាប់អារម្មណ៍លើពួកវា ប៉ុន្តែពួកគាត់មិនចាំបាច់ប្រើវា ដើម្បីបង្រៀនមេរៀនរបស់ពួកគាត់ទេ។

T = មិនមានពេលវេលាកំណត់ច្បាស់លាស់លើសកម្មភាពទេ ដូច្នេះវាអាចចំណាយពេលច្រើនខែ ដើម្បីសម្រេចបាន។

| |
|---|
| ដកស្រង់ចេញពីផែនការសកម្មភាពកម្រិតបុគ្គល របស់គ្រូម្នាក់នៅដើមឆ្នាំសិក្សា<br><br>*គោលដៅសម្រាប់ការពិសោធន៍៖*<br><br>*"ខ្ញុំនឹងអានសៀវភៅណែនាំសម្រាប់ការប្រើប្រាស់មីក្រូទស្សន៍ M14 ថ្មី ហើយមើលឃ្លីបវីដេអូក្នុង YouTube ឱ្យបានចំនួនបីវីដេអូអំពីម៉ូដែលដូចគ្នាក្នុងរយៈពេលពីរសប្តាហ៍ខាងមុខ។ វានឹងជួយឱ្យខ្ញុំរៀន កសាងទំនុកចិត្ត និងអាចបណ្តុះបណ្តាលសិស្សរបស់ខ្ញុំឱ្យប្រើវាដោយទំនុកចិត្តក្នុងការពិសោធន៍ ត្រឹមចុងឆ្នាំសិក្សា 2023"។* |

## ហេតុអ្វីបានជាត្រូវប្រើប្រាស់ការកំណត់គោលដៅ ដោយប្រើប្រាស់លក្ខខណ្ឌSMART?

S = វាគឺជាក់លាក់។ វាបញ្ជាក់យ៉ាងច្បាស់អំពីអ្វីដែលពួកគាត់នឹងធ្វើ ដើម្បីសម្រេចបានគោលដៅ – អានសៀវភៅណែនាំពីឧបករណ៍មីក្រូទស្សន៍ និងមើលបីវីដេអូ YouTube អំពីគំរូដូចគ្នា។

M = វាអាចវាស់វែងបាន។ វាបង្ហាញពីលទ្ធផលដែលពួកគាត់ចង់បាន - ដើម្បីឱ្យសិស្សអាចប្រើមីក្រូទស្សន៍បានដោយទំនុកចិត្ត។ គ្រូអាចសង្កេតឬវាយតម្លៃសិស្សដោយប្រើមីក្រូទស្សន៍។

A = អាចសម្រេចបាន។ ដើម្បីអានសៀវភៅណែនាំមួយ និងមើលវីដេអូ YouTube ខ្លីៗចំនួនបីក្នុងរយៈពេលពីរសប្តាហ៍គឺសមហេតុផល។ សិស្សមានឱកាសល្អក្នុងកសាងទំនុកចិត្តសម្រាប់ប្រើប្រាស់ឧបករណ៍នៅចុងឆ្នាំ។

R = វាគឺពាក់ព័ន្ធគ្នា។ ស្វ័យវាយតម្លៃដើមគ្រា របស់ពួកគាត់ បានកំណត់ថានេះគឺជាចំណុចដែលពួកគាត់មិនមានទំនុកចិត្ត។ សកម្មភាពដែលមាននៅក្នុងគោលដៅរួម គឺទាក់ទងទៅនឹង គោលបំណងបង្រៀនដែលចង់ឱ្យសិស្សមានទំនុកចិត្តក្នុងការប្រើប្រាស់មីក្រូទស្សន៍។

T = ទាន់ពេល។ គាត់បានបញ្ជាក់ថា វានឹងចំណាយពេលពីរសប្តាហ៍ ដើម្បីអាន និងមើលវីដេអូ។ គាត់ក៏បញ្ជាក់ដែរថា ពួកគាត់ចង់ឱ្យសិស្សមានទំនុកចិត្តនៅពេលឆមាសបញ្ចប់។

## ទិដ្ឋភាពទូទៅ៖ ទម្រង់ផែនការការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំកម្រិតបុគ្គល

ទម្រង់ផែនការការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំកម្រិតបុគ្គលប្រើប្រាស់សមាជិកម្នាក់នៃគណៈគ្រប់គ្រងស្វែម និងគ្រូបង្រៀនស្វែម ដើម្បីពិនិត្យ និងធ្វើផែនការឱ្យបានស៊ីជម្រៅជុំវិញតម្រូវការអភិវឌ្ឍវិជ្ជាជីវៈរបស់ពួកគាត់ ក្រោយពេលបានធ្វើវិភាគទៅលើលទ្ធផលនៃស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រា និងស្វ័យវង្វាយតម្លៃវឌ្ឍនភាព (ទាំងគណៈគ្រប់គ្រងស្វែម និងគ្រូបង្រៀនមុខវិជ្ជាស្វែម)។ គ្រូបង្រៀនត្រូវបញ្ចូលលទ្ធផលចេញពីការធ្វើការសង្កេតលម្អិត និងការធ្វើការសង្កេតរយៈខ្លីរួមទាំងយន្តការផ្សេងទៀតដែលជួយកំណត់ពីតម្រូវការសម្រាប់បណ្តុះបណ្តាលបន្ថែម។

## វត្ថុបំណង

ឧបករណ៍នេះប្រើប្រាស់ដើម្បីផ្តល់នៅផែនការសកម្មភាពលម្អិត និងហ្មត់ចត់របស់គណៈគ្រប់គ្រងស្វែម និងគ្រូបង្រៀនមុខវិជ្ជាស្វែមជុំវិញការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំលើការអប់រំស្វែម ដែលវត្ថុបំណងនៃការការលម្អ និងការអភិវឌ្ឍសមត្ថភាពបន្ថែមនេះត្រូវបញ្ចូលនូវគោលការSMART និងការកំណត់លើការពិនិត្យតាមដានវឌ្ឍនភាពរបស់សមាជិកម្នាក់ៗនៃគណៈគ្រប់គ្រងស្វែម និងគ្រូបង្រៀនស្វែម។

## ដំណើរការ

## គំនូសតាងលំហូរ



## ដំណើរការ

- គណៈគ្រប់គ្រងស្ទែម និងគ្រូបង្រៀនស្ទែមធ្វើស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រា (និងធ្វើការពិនិត្យតាមដានវឌ្ឍនភាពតាមពេលវេលាសមស្រប) ដើម្បីផ្ដល់ជាព័ត៌មានមូលដ្ឋានក្នុងការបំពេញផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈកម្រិតបុគ្គលបាន។
- គ្រប់ឧបករណ៍ពិនិត្យតាមដាន និងវាយតម្លៃការរៀន និងការបង្រៀនស្ទែមទាំងអស់ត្រូវបានយកទៅប្រើប្រាស់។
- លទ្ធផល និងការវិភាគចេញពីឧបករណ៍ទាំងនេះនឹងយកមកប្រើប្រាស់ដើម្បីសរសេរគោលដៅអភិវឌ្ឍវិជ្ជាជីវៈដោយប្រើប្រាស់គោលការណ៍SMART។
- សមាជិកម្នាក់នៃគណៈគ្រប់គ្រងស្ទែម និងគ្រូបង្រៀនស្ទែមម្នាក់ៗត្រូវសរសេរផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈកម្រិតបុគ្គលនេះ។
- សកម្មភាពអភិវឌ្ឍវិជ្ជាជីវៈត្រូវគ្រោងរៀបចំជាមួយវត្តមានចូលរួមពីគណៈគ្រប់គ្រងស្ទែម គ្រូណែនាំ អ្នកប្រឹក្សាយោបល់ និងក្រុមគ្រូរួមអាជីព។
- វ.ជ.អផ្ដល់ការគាំទ្របន្ថែមលើតម្រូវការនានានៃការអភិវឌ្ឍវិជ្ជាជីវៈ។
- គណៈគ្រប់គ្រងស្ទែម និងគ្រូបង្រៀនពិនិត្យតាមដានវឌ្ឍនភាពដោយផ្ទៀងផ្ទាត់នឹងផែនការអភិវឌ្ឍវិជ្ជាជីវៈ។

## អ្នកចូលរួម

- គណៈគ្រប់គ្រងស្ទែមម្នាក់ៗ៖ បំពេញផែនការសកម្មភាពកម្រិតបុគ្គលដោយប្រើប្រាស់គោលដៅ SMART
- គ្រូបង្រៀនស្ទែមម្នាក់ៗ៖ បំពេញផែនការសកម្មភាពជាមួយនឹងគោលដៅ SMART ។
- អ្នកណែនាំ គ្រូបង្វឹក និងមិត្តភ័ក្តិ៖ អាចគាំទ្រសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាមួយគ្រូបង្រៀនស្ទែមដែលមានបទពិសោធន៍។

## ពេលវេលា

- គណៈគ្រប់គ្រងស្ទែម និងគ្រូបង្រៀនស្ទែមសរសេរផែនការសកម្មភាពកម្រិតបុគ្គល - សប្ដាហ៍ទី 5 ។
- ផែនការសកម្មភាពកម្រិតបុគ្គលត្រូវធ្វើបច្ចុប្បន្នភាព និងពិនិត្យតាមដានឡើងវិញបន្ទាប់ពីបានទទួលការអភិវឌ្ឍវិជ្ជាជីវៈ និងការធ្វើការសង្កេតរួចហើយ - អនុវត្តបន្តជាប្រចាំ។

## ខ.គ្រូបង្រៀនស្នែម

### ឧបករណ៍

1. ឧបករណ៍ស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រា គ្រូបង្រៀនស្នែម ( ឧបសម្ព័ន្ធ ធ )
2. ឧបករណ៍ស្វ័យវង្វាយតម្លៃវឌ្ឍនភាព គ្រូបង្រៀនស្នែម ( ឧបសម្ព័ន្ធ ធ )
3. ឧបករណ៍ការសង្កេតលម្អិតការបង្រៀនស្នែម( ឧបសម្ព័ន្ធ គ )
4. ទម្រង់ផែនការសកម្មភាពគណៈគ្រប់គ្រងស្នែមកម្រិតសាលារៀន ( ឧបសម្ព័ន្ធ ង )

## ទិដ្ឋភាពទូទៅនៃសកម្មភាពពិនិត្យតាមដាន និងវាយតម្លៃគ្រូបង្រៀន

1. គ្រូបង្រៀនមុខវិជ្ជាស្នែមបំពេញឧបវង្វាយតម្លៃទិន្នន័យដើមគ្រាគ្រូបង្រៀនស្នែម( ឧបសម្ព័ន្ធ ធ )
2. គ្រូបង្រៀនស្នែម នឹងត្រូវបំពេញឧបករណ៍ស្វ័យវង្វាយតម្លៃលើវឌ្ឍនភាពគ្រូបង្រៀនស្នែម( ឧបសម្ព័ន្ធ ធ ) 6 ខែបន្ទាប់ពីពួកគាត់បានបំពេញឧបករណ៍ស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រាគ្រូបង្រៀនស្នែម (ក្នុងចន្លោះពេលពីរសប្តាហ៍ដែលបាន កំណត់)។ នេះនឹងជួយតាមដានវឌ្ឍនភាពនៃការអភិវឌ្ឍន៍ គ្រូម្នាក់ៗ។ ការធ្វើស្វ័យវាយតម្លៃដោយខ្លួនឯងទាំងនេះអាចប្រើរៀង រាល់ឆ្នាំលើមូលដ្ឋានជាបន្តបន្ទាប់ ដើម្បីវាយតម្លៃទំនុកចិត្តរបស់គ្រូបង្រៀនទាក់ទងនឹងស្នែម ។
3. ឧបករណ៍សង្កេតលម្អិតលើការបង្រៀនស្នែម( ឧបសម្ព័ន្ធ គ ) គណៈគ្រប់គ្រងស្នែមគ្រូប្រឹក្សាឬក្រុមគ្រូបង្រៀនស្នែមធ្វើការសង្កេតតាមពេលវេលាដែលបានព្រមព្រៀងគ្នា។ គោលបំណងរបស់ពួកគាត់គឺដើម្បីតាមដាន គុណភាពនៃការបង្រៀន ការរៀន និងការវាយតម្លៃដើម្បីកំណត់សេចក្តីត្រូវការអភិវឌ្ឍន៍វិជ្ជាជីវៈជាប្រចាំ។
4. ទម្រង់ផែនកាសកម្មភាពសម្រាប់គ្រូបង្រៀនកម្រិតសាលារៀន ( ឧបសម្ព័ន្ធ ង ) ត្រូវបានបំពេញដោយគ្រូស្នែមបន្ទាប់ពីការវាយ តម្លៃទិន្នន័យដើមគ្រា និងវឌ្ឍនភាពខ្លួនឯង។ សកម្មភាពនេះ គឺដើម្បីជួយអភិវឌ្ឍសក្តានុពល របស់គ្រូនីមួយៗ។ មានការរំពឹងទុកថាគ្រូនីមួយៗនឹងកំណត់ចំណុចខ្លាំង របស់ពួកគាត់អំពីការបង្រៀន ការរៀន និងការវាយតម្លៃលើមុខវិជ្ជាស្នែមនិងចែករំលែក បទពិសោធន៍ ទាំងនេះជាមួយអ្នកដទៃ។ ពួកគាត់ក៏ត្រូវបានគេ រំពឹងថានឹងកំណត់ផ្នែកដែលត្រូវការការកែលម្អផងដែរ។ ទម្រង់នេះអាចត្រូវបានប្រើ ឬជាជម្រើស សកម្មភាពអាចត្រូវបានបន្ថែមទៅផែនការសកម្មភាពផ្ទាល់ខ្លួន ណាមួយដែលកំពុងត្រូវបានប្រើប្រាស់នាពេលបច្ចុប្បន្ន។

## សេចក្តីលម្អិតលើសកម្មភាពពិនិត្យតាមដាន និងវាយតម្លៃគ្រូបង្រៀនស្នែម

### 1. ឧបករណ៍វង្វាយតម្លៃទិន្នន័យដើមគ្រាគ្រូបង្រៀនស្នែម( ឧបសម្ព័ន្ធ ធ )

ឧបករណ៍វង្វាយតម្លៃទិន្នន័យដើមគ្រាគ្រូបង្រៀនស្នែម( ឧបសម្ព័ន្ធ ធ ) មានទាំងជាភាសាខ្មែរ និងអង់គ្លេស ហើយត្រូវចំណាយពេលប្រហែល 15 ទៅ20នាទីដើម្បីបញ្ចប់ការបំពេញ ហើយចាំបាច់ត្រូវបញ្ចប់តែត្រឹមរពេលនៃការបំពេញនេះ។

**ចំណាំ៖** ទាំងទិន្នន័យដើមគ្រានិងវឌ្ឍនភាពស្វ័យវាយតម្លៃដោយខ្លួនឯងគឺដូចគ្នា។ច្បាប់ចម្លងជាក្រដាសក៏មាននៅក្នុងឧបសម្ព័ន្ធ(ធ) សម្រាប់អ្នកដែលមិនមានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យា។

តំណភ្ជាប់ជាភាសាខ្មែរ៖ https://forms.office.com/e/THnQQ4Czdr

លេខកូដ QR ជាភាសាខ្មែរ៖




តំណភ្ជាប់កំណែជាភាសាអង់គ្លេស៖ https://forms.office.com/e/74VT0BDS35

កូដ QR ជាភាសាអង់គ្លេស៖




### ទិដ្ឋភាពទូទៅ៖ ឧបករណ៍ស្វ័យរង្វាយតម្លៃទិន្នន័យដើមគ្រាសម្រាប់គ្រូបង្រៀនស្ទែម

ឧបករណ៍ស្វ័យរង្វាយតម្លៃទិន្នន័យដើមគ្រាសម្រាប់គ្រូបង្រៀនស្ទែមគឺជាកម្រងសំណួរស្ទង់មតិដែលប្រើប្រាស់ដោយគ្រូបង្រៀនស្ទែមដើម្បីវាយតម្លៃចំណេះដឹង និងការយល់ដឹងអំពីបច្ចុប្បន្នភាពនៃតួនាទី និងទំនួលខុសត្រូវ ក៏ដូចជាការកែលម្អរបស់ពួកគាត់ជុំវិញការអប់រំស្ទែម។ កម្រងសំណួរនេះនិងផ្តល់នូវទិន្នន័យសម្រាប់ជាព័ត៌មានមូលដ្ឋានដល់គណៈគ្រប់គ្រងស្ទែម និងវិទ្យាស្ថានជាតិអប់រំសម្រាប់យកមករៀបចំកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈដែលចាំបាច់ដល់គ្រូបង្រៀនស្ទែមដែលជាជាកិច្ចការមួយក្នុងការជួយលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សផងដែរ។

### វត្ថុបំណង

ឧបករណ៍ស្វ័យរង្វាយតម្លៃទិន្នន័យដើមគ្រាសម្រាប់គ្រូបង្រៀនស្ទែម ប្រើប្រាស់ដើម្បីពិនិត្យតាមដាន និងវាយតម្លៃចំណេះដឹង ជំនាញ និងសមត្ថភាពដំបូងរបស់គ្រូបង្រៀនស្ទែមនៅពេលបង្រៀនមុខវិជ្ជាស្ទែម។

### ដំណើរការ

## គំនូសតាងបង្ហាញលំហូរប្រើប្រាស់ឧបករណ៍




- ស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រាសម្រាប់គ្រូបង្រៀនស្នែមចាំបាច់ត្រូវបំពេញឱ្យបានឆាប់រហ័សតាមពេលវេលាសមស្របដែលគេអាចធ្វើបានក្នុងឆ្នាំសិក្សាដោយគ្រូមុខវិជ្ជាស្នែម។ ការបំពេញស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រាតម្រូវឱ្យកំណត់កាលបរិច្ឆេទចុងក្រោយសម្រាប់ការវាយតម្លៃខ្លួនឯង ដើម្បីធានាថាការវិភាគ 'ប្រព័ន្ធទាំងមូល' ត្រឹមត្រូវអាចយកជាការបាន។
- តំណភ្ជាប់ទៅនឹងស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រានឹងត្រូវបានចែកចាយទៅកាន់គណៈគ្រប់គ្រងសាលារៀននីមួយៗតាម Telegram ដោយគ្រូបង្គោលនៃវ.ជ.អ ។
- គ.គ.ស នឹងចែកចាយតំណភ្ជាប់ទៅកាន់បុគ្គលិកបង្រៀនមុខវិជ្ជាស្នែម។
- គ.គ.ស នឹងត្រូវពិនិត្យតាមដាន និងធានាថាគ្រូបង្រៀនស្នែមទាំងអស់ទទួលបានតំណភ្ជាប់ និងបំពេញស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រាក្នុងរយៈពេលមួយសប្តាហ៍បន្ទាប់។
- វ.ជ.អនឹងផ្តល់ការវិភាគទិន្នន័យសម្រាប់សាលារៀននីមួយៗ និងចែកចាយលទ្ធផលទៅគ.គ.ស។
- ភាគីទាំងអស់នឹងរក្សាទុកព័ត៌មានដោយសុវត្ថិភាព និងមិនចែករំលែកព័ត៌មានណាមួយជាមួយភាគីទីបីផ្សេងទៀតឡើយ។
- គ.គ.ស និងគ្រូបង្រៀនស្នែមនឹងពិនិត្យលទ្ធផល និងកំណត់ចំណុចខ្លាំង និងផ្នែកសំខាន់ៗសម្រាប់ការអភិវឌ្ឍន៍បន្ថែម។
- គ្រូបង្រៀនស្នែមនឹងបង្កើតផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈកម្រិតបុគ្គល ( ឧបសម្ព័ន្ធ ច ) ។
- គ្រូស្នែមនឹងពិនិត្យតាមដានវឌ្ឍនភាព ដោយផ្ទៀងផ្ទាត់នឹងផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈកម្រិតបុគ្គលនោះ។

- គ.គ.សនឹងពិនិត្យមើលវឌ្ឍនភាពដោយផ្ទៀងផ្ទាត់នឹងសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈកម្រិតបុគ្គលជាប្រចាំ ហើយចែករំលែកជាមួយគ្រូបង្គោលនៅវិទ្យាស្ថានជាតិអប់រំនៅពេលការប្រជុំពិនិត្យប្រចាំឆ្នាំ។
- គ្រូថ្មីដែលបង្រៀនមុខវិជ្ជាស្ទែមអាចធ្វើស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រាភ្លាមៗនៅពេលដែលពួកគេចាប់ផ្ដើម ចូលបង្រៀននៅសាលារៀន ដើម្បីធានាបរិយាប័ន្នការងារដោយមន្ត្រីកាន់ការងារអប់រំស្ទែមគ្រប់រូបអាចទទួល បានឱកាសអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

## អ្នកចូលរួម

- គ្រូបង្គោលវ.ជ.អ ៖ ផ្ដល់នូវតំណភ្ជាប់ស្ទង់មតិស្វ័យវង្វាយតម្លៃ និងសម្របសម្រួលរៀបចំផែនការ និង ផ្ដល់ ការបណ្ដុះបណ្ដាលវិជ្ជាជីវៈជាប្រចាំ។
- គណៈគ្រប់គ្រងស្ទែម (ក្រុមស្នូលលើការងារអប់រំស្ទែម)៖ ទទួលយកការស្ទង់មតិស្វ័យវង្វាយតម្លៃទិន្នន័យ ដើមគ្រា និងរៀបចំផែនការបណ្ដុះបណ្ដាលវិជ្ជាជីវៈជាប្រចាំកម្រិតបុគ្គល។
- គ្រូបង្រៀនស្ទែម៖ ទទួលយកការវាយតម្លៃខ្លួនឯងជាមូលដ្ឋាន

## ពេលវេលា

- ការបំពេញស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រាសម្រាប់គ្រូបង្រៀនស្ទែមធ្វើឡើងមុនសប្ដាហ៍ទី3នៃឆ្នាំសិក្សាដំបូង។
- វិទ្យាស្ថានជាតិអប់រំផ្ដល់លទ្ធផលនៃស្វ័យវង្វាយតម្លៃនេះទៅគណៈគ្រប់គ្រងស្ទែមនៅសប្ដាហ៍ទី4។
- ផែនការសកម្មភាពកម្រិតបុគ្គលរបស់គ្រូបង្រៀនស្ទែមត្រូវបំពេញឱ្យរួចរាល់ត្រឹមសប្ដាហ៍ទី 5។
- ការបណ្ដុះបណ្ដាល និងគាំទ្រលើការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំត្រូវអនុវត្តជាប្រចាំ។
- គ្រូបង្រៀនមុខវិជ្ជាស្ទែមពិនិត្យតាមដានមើលវឌ្ឍនភាព (ភ្ជាប់ទៅនឹងផែនការសកម្មភាពកម្រិតបុគ្គល) នៅចន្លោះពេលទៀងទាត់។
- គណៈគ្រប់គ្រងស្ទែម និងគ្រូបង្គោលវិទ្យាស្ថានជាតិអប់រំពិនិត្យមើលវឌ្ឍនភាព (ភ្ជាប់ទៅនឹងផែនការសកម្មភាពកម្រិតបុគ្គល) នៅចុងបញ្ចប់នៃឆ្នាំសិក្សា។

## 2. ឧបករណ៍ស្វ័យវង្វាយតម្លៃវឌ្ឍនភាពគ្រូបង្រៀនស្ទែម( ឧបសម្ព័ន្ធ ឆ)

ការធ្វើស្វ័យវង្វាយតម្លៃវឌ្ឍនភាពតាមប្រព័ន្ធអនឡាញគឺដូចគ្នានឹងការធ្វើស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រាដែរ។ គ្រូបង្រៀននឹងត្រូវបំពេញស្វ័យវាយតម្លៃវឌ្ឍនភាពនៅ6ខែបន្ទាប់ពីពួកគាត់បានបញ្ចប់ស្វ័យវាយតម្លៃទិន្នន័យដើម គ្រារួចហើយ។ លទ្ធផលនៃការវាយតម្លៃទាំងពីរអាចត្រូវបានប្រៀបធៀប ក៏ដូចជាការកំណត់នៅចំណុចត្រូវកែលម្អ ឡើងវិញបន្ថែមទៀតដែលទាមទារឱ្យគ្រូបង្រៀនទទួលស្គាល់ពីចំណុចកែលម្អទាំងនោះ នឹងដាក់បញ្ចូលទៅក្នុង ផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈរបស់ខ្លួន។

## ទិដ្ឋភាពទូទៅ៖ ឧបករណ៍ស្វ័យវង្វាយតម្លៃវឌ្ឍនភាពគ្រូបង្រៀនស្នែម

ឧបករណ៍ស្វ័យវង្វាយតម្លៃវឌ្ឍនភាពគ្រូបង្រៀនស្នែមគឺជាការស្ទង់មតិតាមអនឡាញដែលត្រូវបំពេញដោយគ្រូស្នែម។ ឧបករណ៍ស្ទង់មតិគឺដូចគ្នាដដែលទៅនឹងឧបករណ៍ស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រាដែលគ្រូបង្រៀនស្នែមបានបំពេញកាលពីដើមឆ្នាំសិក្សា។ គ្រូបង្រៀនស្នែមត្រូវការបំពេញស្វ័យវង្វាយតម្លៃនៅរៀងរាល់ពេល៦ខែម្តង បន្ទាប់ពីពេលដែលពួកគាត់បានបំពេញស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រារួចរាល់។ លទ្ធផលចេញពីការស្វ័យវង្វាយតម្លៃនេះនឹងត្រូវយកមកប្រៀបធៀបគ្នា ដើម្បីឆ្លុះបញ្ចាំងមើលពីចំណុចដែលត្រូវកែលម្អ និងគ្រោងផែនការសកម្មភាពសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅពេលខាងមុខបន្តទៀត។

### វត្ថុបំណង

ឧបករណ៍ស្វ័យវង្វាយតម្លៃប្រើប្រាស់ដើម្បីពិនិត្យតាមដាន និងវាយតម្លៃចំណេះដឹង ជំនាញ និងសមត្ថភាពរបស់គ្រូស្នែមក្រោយពេលទទួលការអភិវឌ្ឍវិជ្ជាជីវៈក្នុងពេលកំណត់ ដោយមានការផ្ទៀងផ្ទាត់គ្នាទៅនឹងផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈ និងការបង្រៀនមេរៀនស្នែមនៃឆ្នាំសិក្សា។

### ដំណើរការ

### គំនូសតាងបង្ហាញលំហូរប្រើប្រាស់ឧបករណ៍



- ស្វ័យវង្វាយតម្លៃវឌ្ឍនភាពគ្រូបង្រៀនស្ទែមចាំបាច់ត្រូវធ្វើឡើងនៅចន្លោះពេលប្រហែល 6 ខែបន្ទាប់ពីគ្រូស្ទែមបានបំពេញស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រារួចរាល់។
- គ.គ.ស នឹងធានាថាតំណភ្ជាប់ទៅនឹងការវាយតម្លៃដោយខ្លួនឯងនៃវឌ្ឍនភាពត្រូវបានចែកចាយឡើងវិញដល់គ្រូបង្រៀនស្ទែមទាំងអស់។
- គ.គ.ស នឹងពិនិត្យតាមដាន និងធានាថាគ្រូបង្រៀនស្ទែមទាំងអស់ទទួលបានតំណភ្ជាប់ និងតាមដានគ្រូទាំងអស់ថាបានបំពេញស្វ័យវង្វាយតម្លៃវឌ្ឍនភាពគ្រូបង្រៀនស្ទែមនេះ។
- វ.ជ.អ នឹងផ្ដល់នូវការវិភាគទិន្នន័យប្រៀបធៀប (ភាពខុសគ្នារវាងទិន្នន័យដើមគ្រា និងវឌ្ឍនភាពនៃស្វ័យវង្វាយតម្លៃដល់សាលារៀននីមួយៗ) និងចែកចាយលទ្ធផលទៅគណៈគ្រប់គ្រងសាលារៀននោះ។
- គ្រូបង្រៀនស្ទែមបន្ថែមសកម្មភាពទៅក្នុងផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈកម្រិតបុគ្គលរបស់ពួកគាត់ ហើយពិនិត្យមើលវឌ្ឍនភាពជាប្រចាំ។
- គ.គ.ស នឹងពិនិត្យឡើងវិញនូវការវិភាគប្រៀបធៀប និងបន្ថែមគោលដៅសម្រាប់ការធ្វើកែលម្អ ដោយផ្ទៀងផ្ទាត់ទៅនឹងផែនការសកម្មភាពកម្រិតសាលារៀន ។
- វ.ជ.អ នឹងពិនិត្យមើលវឌ្ឍនភាពនៅក្នុងកិច្ចប្រជុំពិនិត្យតាមដានប្រចាំឆ្នាំ។
- ដំណើរការនេះអាចត្រូវបានធ្វើរៀងរាល់ 6 ខែម្ដង ដើម្បីធានាថា គ.គ.ស និង វ.ជ.អ មានទំនុកចិត្តថាគ្រូបង្រៀនទទួលបានការជួយគាំទ្រ។
- គ្រូថ្មីដែលបង្រៀនមុខវិជ្ជាស្ទែមអាចធ្វើស្វ័យវង្វាយតម្លៃទិន្នន័យដើមគ្រាភ្លាមៗនៅពេលដែលពួកគេចាប់ផ្ដើមចូលបង្រៀននៅសាលារៀន និងត្រូវបំពេញនៅ៦ខែក្រោយ ដើម្បីធានាបរិយាប័ន្នការងារដោយមន្ត្រីកាន់ការងារអប់រំស្ទែមគ្រប់រូបអាចទទួលបានឱកាសអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

## អ្នកចូលរួម

- គ្រូបង្គោលវ.ជ.អ - ផ្ដល់នូវតំណភ្ជាប់ទៅនឹងការស្ទង់មតិ។ ជួយរៀបចំផែនការ និងផ្ដល់ការបណ្ដុះបណ្ដាលការអភិវឌ្ឍវិជ្ជាជីវៈ និងសំភាសន៍ គ.គ.ស កំឡុងពេលពិនិត្យចុងឆ្នាំ។
- គ.គ.ស – សម្របសម្រួលការស្ទង់មតិវឌ្ឍនភាពជាមួយគ្រូ ស្ទែម វិភាគទិន្នន័យប្រៀបធៀប ធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពសាលា និងរៀបចំផែនការបណ្ដុះបណ្ដាល ការអភិវឌ្ឍវិជ្ជាជីវៈ ផ្ទាល់ខ្លួន។
- គ្រូបង្រៀន ស្ទែម ទទួលយកការវាយតម្លៃដោយខ្លួនឯងជាមូលដ្ឋាន ធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពផ្ទាល់ខ្លួនរបស់ពួកគេ និងចូលរួមក្នុងសកម្មភាព ការអភិវឌ្ឍវិជ្ជាជីវៈ ។

## ពេលវេលា

- ការវាយតម្លៃវឌ្ឍនភាព ស្ទែម បានធ្វើឡើង 2 សប្ដាហ៍មុនពេលបញ្ចប់ឆមាសទី 1 ។
- វ.ជ.អ ចេញលទ្ធផលទៅ គ.គ.ស 1 សប្ដាហ៍មុនចុងបញ្ចប់នៃឆមាសទី 1 ។
- ផែនការសកម្មភាពផ្ទាល់ខ្លួនរបស់គ្រូ ស្ទែម បានធ្វើបច្ចុប្បន្នភាព 1 សប្ដាហ៍មុនចុងបញ្ចប់នៃឆមាសទី 1
- គ.គ.ស ពិគ្រោះជាមួយ វ.ជ.អ ប្រសិនបើ ការអភិវឌ្ឍវិជ្ជាជីវៈ ណាមួយត្រូវបានទាមទារ។

- ការអភិវឌ្ឍវិជ្ជាជីវៈ - កំពុងដំណើរការ
- គ្រូ ស្នែម ពិនិត្យមើលវឌ្ឍនភាព (ភ្ជាប់ទៅនឹងផែនការសកម្មភាពផ្ទាល់ខ្លួន) នៅចន្លោះពេលទៀងទាត់។
- គ.គ.ស និង វ.ជ.អ CT ពិនិត្យមើលវឌ្ឍនភាព (ភ្ជាប់ទៅនឹងផែនការសកម្មភាពផ្ទាល់ខ្លួន) នៅចុងបញ្ចប់នៃឆមាសទី 2 ។

### 3. ឧបករណ៍សង្កេតលម្អិតលើការបង្រៀនស្នែម( ឧបសម្ព័ន្ធ គ )

ពាក្យថា *'ការសង្កេតលម្អិត '*គឺដើម្បីជួយភាគីទាំងអស់អភិវឌ្ឍការអនុវត្តរបស់ពួកគាត់។ ពួកគេមិនត្រូវបានឱ្យនិទ្ទេស ឬដាក់ពិន្ទុទេ។ នេះគឺជាទម្រង់សង្កេតការបង្រៀនដូចគ្នាដែលប្រើដោយគណៈគ្រប់គ្រងស្នែម/គ្រូប្រឹក្សាស្នែមដើម្បី ធ្វើការសង្កេតរបស់ពួកគាត់។

គ្រូអាចប្រើឧបករណ៍នេះតាមវិធីជាច្រើនសម្រាប់គោលបំណងអភិវឌ្ឍ។ វាផ្តល់ឱកាសដើម្បីកំណត់នូវការអនុវត្តល្អ និងការអនុវត្តដែលទាមទារឱ្យមានការអភិវឌ្ឍន៍បន្ថែមទៀត។ វាអាចជា៖

ប្រើដោយគ្រូស្នែមដែលមានបទពិសោធន៍ ដើម្បីសង្កេតមើលក្រុមគ្រូស្នែមរបស់ពួកគាត់សម្រាប់គោល បំណង អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ។

ប្រើដើម្បីសង្កេតមើលក្រុមគ្រូស្នែមនៅក្នុងថ្នាក់ដើម្បីទទួលបានគំនិត និងផ្តល់មតិស្ថាបនា។

ប្រើដោយគ្រូប្រឹក្សាស្នែមឬ គណៈគ្រប់គ្រងស្នែម ដើម្បីកំណត់និងលើកទឹកចិត្តដល់ការកែលម្អ។

ផ្នែកនៃការបង្រៀន ការរៀន និងការវាយតម្លៃ ដែលត្រូវបានកំណត់ក្នុងអំឡុងពេលសង្កេតត្រូវការការអភិវឌ្ឍន៍បន្ថែមទៀតអាចត្រូវបានបន្ថែមទៅក្នុងផែនការសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំផ្ទាល់ខ្លួនរបស់គ្រូ។ នេះអាចមានន័យថាការសង្កេតគាំទ្របន្ថែមទៀតត្រូវបានអនុវត្តដើម្បីសម្រួលការអនុវត្តស្នែមយ៉ាងម៉ត់ចត់។

### 4. ទម្រង់ផែនកាសកម្មភាពគណៈគ្រប់គ្រងស្នែមកម្រិតសាលារៀន ( ឧបសម្ព័ន្ធ ង )

គ្រូបង្រៀនអាចប្រើទម្រង់ផែនកាសកម្មភាពគណៈគ្រប់គ្រងស្នែមកម្រិតសាលារៀន នេះឬបន្ថែមទៅលើផែនកាដែលពួកគាត់ កំពុងប្រើរួចហើយជាមួយគ្រូប្រឹក្សាស្នែម។ រឿងសំខាន់បីយ៉ាងដែលគួរចងចាំគឺ៖

1) គោលដៅគឺផ្តែកលើផ្នែកជាក់លាក់នៃការអនុវត្តល្អ ឬការអនុវត្តដែលតម្រូវឱ្យមានការកែលម្អដើម្បីជះឥទ្ធិពលដល់ការធ្វើឱ្យប្រសើរឡើងនូវលទ្ធផលនៃការសិក្សារបស់សិស្ស

2) គោលដៅដែលកំណត់តាមលក្ខខណ្ឌ'SMART'

3) ការពិនិត្យឡើងវិញនៃសកម្មភាពត្រូវបានអនុវត្តជាញឹកញាប់ដើម្បី ពិនិត្យតាមដានវឌ្ឍនភាព។ ផែនការសកម្មភាព គឺជាឯកសារផែនការដែលទាមទារការពិនិត្យតាមដាន និងការធ្វើបច្ចុប្បន្នកម្មជាប្រចាំ។

## គ.សិស្សសិក្សាមុខវិជ្ជាស្នែម

ឧបករណ៍

1. ឧបករណ៍ស្ទង់មតិទិន្នន័យដើមគ្រារបស់សិស្សលើមុខវិជ្ជាស្នែម (ឧបសម្ព័ន្ធ ជ)
2. ឧបករណ៍ស្ទង់មតិវឌ្ឍនភាពស្ដីការពេញចិត្តរបស់សិស្សលើមុខវិជ្ជាស្នែម (ឧបសម្ព័ន្ធ ជ)

## ទិដ្ឋភាពទូទៅនៃសកម្មភាពពិនិត្យតាមដាន និងវាយតម្លៃសិស្ស

សិស្សទាំងអស់នឹងទទួលបានការស្ទង់មតិទិន្នន័យដើមគ្រា និងវឌ្ឍនភាពស្ដីពីការពេញចិត្តរបស់សិស្សលើមុខវិជ្ជាស្នែមតាមប្រព័ន្ធអនឡាញចំនួនពីរដងក្នុងមួយឆ្នាំ (ឧបសម្ព័ន្ធ ជ)។ .

1. ការស្ទង់មតិទិន្នន័យដើមគ្រាស្ដីពីការពេញចិត្តរបស់សិស្សនឹងត្រូវបានធ្វើឡើងលើកទីមួយតាមប្រព័ន្ធអនឡាញក្នុងរយៈពេលបួនសប្ដាហ៍ដំបូងនៃឆមាសដំបូងនៃឆ្នាំសិក្សារបស់សិស្សជុំវិញប្រធានបទដែលទាក់ទងនឹងស្នែម។
2. ការស្ទង់មតិលើវឌ្ឍនភាពស្ដីពីការចិត្តរបស់សិស្សនឹងត្រូវបានធ្វើឡើងជាលើកទីពីរតាមប្រព័ន្ធអនឡាញនៅចុងឆមាសទីពីរនៃឆ្នាំសិក្សាជុំវិញប្រធានបទដែលទាក់ទងនឹងស្នែម។ លទ្ធផលដែលទទួលបានទាំងពីរលើកនៃសម្រង់មតិសម្លេងនេះគឺជាគន្លឹះក្នុងការផ្ដល់ឱកាស ដើម្បីឱ្យគណៈគ្រប់គ្រងស្នែម គ្រូបង្រៀនពិនិត្យមើលលើការរីកចម្រើន និងចំណុចកែលម្អតាមចំណុចដ៏ជាក់លាក់។

## សេចក្ដីលម្អិតអំពីសកម្មភាពពិនិត្យតាមដាន និងវាយតម្លៃនៅកម្រិតសិស្ស

### 1. ទិន្នន័យដើមគ្រានៃការស្ទង់មតិស្ដីពីការពេញចិត្តរបស់សិស្ស (ឧបសម្ព័ន្ធ ជ)

ទិន្នន័យដើមគ្រានៃការស្ទង់មតិការពេញចិត្តរបស់សិស្ស អាចរកបានទាំងភាសាខ្មែរ និងអង់គ្លេសដូចខាងក្រោម។ សូមកត់សម្គាល់ ៖ ការស្ទង់មតិទិន្នន័យដើមគ្រា និងវឌ្ឍនភាពគឺមានតំណភ្ជាប់ដូចគ្នា។ ឯកសារថតចម្លងក៏មាននៅក្នុងឧបសម្ព័ន្ធ ជ ហើយឯកសារនេះគឺសម្រាប់អ្នកដែលមិនមានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាបាន។

តំណភ្ជាប់ជាភាសាខ្មែរ: https://forms.office.com/e/KGS322Kk1c

ស្កេនកូដជាភាសាខ្មែរ:




តំណភ្ជាប់ជាភាសាអង់គ្លេស: [ស្ទែម Student Voice Baseline and Progress Satisfaction Survey ( office.com )]

ស្កេនកូដជាភាសាអង់គ្លេស:




## ទិដ្ឋភាពទូទៅ៖ ការស្ទង់មតិលើទិន្នន័យដើមគ្រានៃការស្ទង់មតិស្តីពីការពេញចិត្តរបស់សិស្ស

ការស្ទង់មតិលើទិន្នន័យដើមគ្រានៃការស្ទង់មតិស្តីពីការពេញចិត្តរបស់សិស្សគឺដើម្បីឱ្យសិស្សចែករំលែកពីបទពិសោធន៍ដំបូងនៃការអប់រំស្ទែមរបស់ពួកគេនៅសាលារៀនមុនពេលការចូលរៀនមេរៀនស្ទែមដំបូង។ គណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និង វិទ្យាស្ថានជាតិអប់រំនឹងទទួលទស្សនៈផ្សេងៗគ្នាទាក់ទងនឹងគុណភាព និងការអនុវត្តនៃការបង្រៀន ការរៀន និងការវាយតម្លៃស្ទែម ។ លទ្ធផលនៃការស្ទង់មតិការពេញចិត្តរបស់សិស្សនឹងត្រូវប្រើប្រាស់ជាទិន្នន័យដើមគ្រាដែលដើរតួនាទីជាព័ត៌មានមូលដ្ឋានសម្រាប់គ្រប់ភាគីទាំងអស់ក្នុងការកំណត់ថាមានអ្វីដែលកំពុងដំណើរការល្អ និងអ្វីដែលត្រូវកែលម្អបន្ថែម។

## វត្ថុបំណង

ដើម្បីតាមដាន និងវាយតម្លៃមតិដើមគ្រារបស់សិស្សជុំវិញទស្សនៈនៃការពេញចិត្តលើមុខវិជ្ជាស្ទែម និងបទពិសោធន៍របស់សិស្សលើការសិក្សារៀនសូត្រនៅក្នុងសាលារៀន ការស្ទង់មតិនេះនឹងបង្ហាញការអភិវឌ្ឍន៍នៃគណៈគ្រប់គ្រងសាលា និងផែនការសកម្មភាពសម្រាប់គ្រូបង្រៀនស្ទែម និងកម្រិតសាលារៀន។

## ដំណើរការ

## គំនូសតាងលំហូរប្រើប្រាស់ឧបករណ៍

គណៈគ្រប់គ្រងសាលា ធ្វើការត្រួតពិនិត្យជាបន្តនៃវឌ្ឍនភាពក្នុងកិច្ចប្រជុំ របស់ខ្លួន

| | | | | | | |
|---|---|---|---|---|---|---|
| គ្រូបង្គោល វ.ជ.អ ធានា គ.គ.ស មានតំណភ្ជាប់សម្រាប់ការស្ទង់មតិសិស្ស | សិស្ស ស្ទែម ធ្វើការស្ទង់មតិដើមគ្រា<br><br>គ្រូ ស្ទែម ត្រួតពិនិត្យ | វ.ជ.អ ចេញឱ្យនាយកសាលាជាមួយនឹងលទ្ធផលនៃការស្ទង់មតិ<br><br>គ.គ.ស និង ប្រធានក្រុមស្ទែមទទួលបានលទ្ធផល | គ.គ.ស / គ្រូ ធ្វើការវិភាគលទ្ធផលនៃការស្ទង់មតិក្នុងមួយមុខវិជ្ជាៗ | គ្រូ ស្ទែម ធ្វើបច្ចុប្បន្នភាពផែនការសកម្មភាព អភិវឌ្ឍវិជ្ជាជីវៈបន្តជាប្រចាំផ្ទាល់ខ្លួនរបស់ពួកគេ។ | គ.គ.ស ជូនដំណឹងដល់ វ.ជ.អ អំពីតម្រូវការអភិវឌ្ឍវិជ្ជាជីវៈបន្តជាប្រចាំណាមួយ ផែនការ និង ការបណ្តុះបណ្តាល<br><br>ទម្រង់ផែនកាសកម្មភាពគណៈគ្រប់គ្រងស្ទែមកម្រិតសាលារៀន ត្រូវបានធ្វើបច្ចុប្បន្នភាព | វ.ជ.អ /គ.គ.ស ពិនិត្យមើលវឌ្ឍនភាពនៃផែនការសកម្មភាពរបស់សាលា |

គ្រូបង្រៀនប្រើប្រាស់ឧបករណ៍វាយតម្លៃដើម្បីកែលម្អ

| | | | | | | |
|---|---|---|---|---|---|---|
| 1 សប្តាហ៍មុនការ ស្ទង់មតិដើមគ្រា | មើលលើសសកម្មភាពនេះ។ សកម្មភាពនេះគឺចាប់ផ្តើម 4សប្តាហ៍បន្ទាប់ពីការចាប់ផ្តើមឆមាសទី 1 | សប្តាហ៍ទី 5 | សប្តាហ៍ទី 5 | សប្តាហ៍ទី 5 | សប្តាហ៍ទី 6<br><br>ការ អភិវឌ្ឍវិជ្ជាជីវៈបន្តជាប្រចាំកំពុងដំណើរការពេញមួយឆមាសទី 1 និងទី 2 | ចុងឆមាសទី2 |

- គ្រូបង្គោលវ.ជ.អនឹងចែកចាយ តំណភ្ជាប់ទៅនឹងការស្ទង់មតិដើមគ្រា ទៅ គ.គ.ស តាមរយៈ តេឡេក្រាម ។
- សិស្សស្វែម ត្រូវតែធ្វើការស្ទង់មតិស្តីពីការពេញចិត្តរបស់សិស្សនេះ ក្នុងរយៈពេល 4 សប្តាហ៍នៃការចាប់ផ្តើមនៃ ឆមាសទី1។
- គ.គ.ស នឹងចែកចាយតំណភ្ជាប់ទៅកាន់គ្រូ ស្វែម ដែលត្រូវបានជ្រើសរើស។
- គ្រូ ស្វែម នឹងចែកចាយតំណភ្ជាប់ទៅសិស្សរបស់ពួកគេ។
- គ្រូបង្រៀន ស្វែម នឹងធ្វើឱ្យប្រាកដថាសិស្ស ស្វែម ទាំងអស់ទទួលបានតំណភ្ជាប់ និងធ្វើការតាមដានថាសិស្សទាំងអស់បានបញ្ចប់ការវាយតម្លៃទិន្នន័យដើមគ្រានៃការស្ទង់មតិស្តីពីការពេញចិត្តរបស់សិស្ស ។
- វ.ជ.អ នឹងផ្តល់ការវិភាគទិន្នន័យសម្រាប់សាលានីមួយៗ និងចែកចាយលទ្ធផលទៅកាន់នាយកសាលា។
- នាយកសាលានឹងចែករំលែកលទ្ធផលជាមួយ គ.គ.ស ។
- គ.គ.ស នឹងចែកចាយលទ្ធផលសម្រាប់ថ្នាក់នីមួយៗដល់គ្រូ ស្វែម ។
- គ្រូ ស្វែម នឹងពិនិត្យមើលលទ្ធផលស្ទង់មតិរបស់សិស្សនិងបង្កើតផែនការសកម្មភាពសមរម្យមួយសម្រាប់មុខវិជ្ជានីមួយៗ។ សកម្មភាពទាំងនេះនឹងត្រូវបានដាក់នៅលើផែនការសកម្មភាពរបស់សាលា/គ្រូ។ ពួកគាត់ពិនិត្យលើកត្តានាំមុខដែលឈានដល់ការស្ទង់មតិវឌ្ឍនភាពការពេញចិត្តរបស់សិស្សលើកទី 2 រហូតដល់ចុងបញ្ចប់នៃឆមាសទីពីរ។
- គ.គ.ស នឹងតាមដានវឌ្ឍនភាពនេះជាប្រចាំងដោយមើលលើផែនការសកម្មភាពរបស់សាលា។
- ដំណើរការសម្រាប់សកម្មភាពនឹងត្រូវបានចែករំលែករវាង គ.គ.ស និងគ្រូបង្គោលស វ.ជ.អ កំឡុងពេលការពិនិត្យប្រចាំឆ្នាំ (ការពិភាក្សា)។
- សិស្សថ្មី ស្វែមអាចបំពេញការស្ទង់មតិដើមគ្រាបានភ្លាមៗនៅពេលដែលពួកគេចាប់ផ្តើមឆមាសរបស់ពួកគេ។ ការធ្វើបែបនេះគឺធានាបាននូវការរួមបញ្ចូលរបស់ពួកគេនៅក្នុងដំណើរការ ហើយ 'ទស្សនៈ' របស់ពួកគេនឹងត្រូវបានឮ។

## អ្នកចូលរួម

- វ.ជ.អ Core Trainer - ផ្តល់នូវតំណភ្ជាប់ទៅនឹងការស្ទង់មតិ។ ចេញលទ្ធផលស្ទង់មតិ ជួយ រៀបចំផែនការ និងផ្តល់ការបណ្តុះបណ្តាល ការអភិវឌ្ឍវិជ្ជាជីវៈ និងសំភាសន៍ គ.គ.ស កំឡុងពេលពិនិត្យចុងឆ្នាំ។
- គ.គ.ស- ពិនិត្យតាមដានការស្ទង់មតិមូលដ្ឋានជាមួយគ្រូ ស្វែម វិភាគទិន្នន័យប្រៀបធៀប ធ្វើបច្ចុប្បន្នភាពផែនការ សកម្មភាពសាលា និងរៀបចំផែនការបណ្តុះបណ្តាល ការអភិវឌ្ឍវិជ្ជាជីវៈ ផ្ទាល់ខ្លួន។
- គ្រូបង្រៀន ស្វែម ពិនិត្យមើលលទ្ធផលស្ទង់មតិតាមប្រធានបទ ធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពផ្ទាល់ខ្លួនរបស់ពួកគេ និងចូលរួមក្នុងសកម្មភាព ការអភិវឌ្ឍវិជ្ជាជីវៈ ។

## ពេលវេលា

- ទិន្នន័យដើមគ្រានៃការស្ទង់មតិស្តីពីការពេញចិត្តរបស់សិស្ស - គឺមានរយៈពេល 4 សប្តាហ៍បន្ទាប់ពីការចាប់ផ្តើមនៃឆមាសទីមួយ។

- វ.ជ.អ ចេញលទ្ធផលទៅនាយកសាលា - សប្តាហ៍ទី 5 ។
- ប្រធានក្រុមស្ទែម និងគ្រូពិនិត្យលទ្ធផលសម្រាប់មុខវិជ្ជានីមួយៗ - សប្តាហ៍ទី 5 ។
- បានធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពផ្ទាល់ខ្លួនរបស់គ្រូ ស្ទែម – សប្តាហ៍ទី 5។
- បានធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពរបស់សាលា – សប្តាហ៍ទី 6 ។
- ការអភិវឌ្ឍវិជ្ជាជីវៈបន្តជាប្រចាំ - កំពុងដំណើរការ
- គ្រូ ស្ទែម ពិនិត្យមើលវឌ្ឍនភាព ដែលភ្ជាប់ទៅនឹងផែនការសកម្មភាពផ្ទាល់ខ្លួននៅចន្លោះពេលទៀងទាត់។
- គ.គ.ស និង គ្រូបង្គោលវ.ជ.អ ពិនិត្យមើលវឌ្ឍនភាព (ភ្ជាប់ទៅនឹងផែនការសកម្មភាពផ្ទាល់ខ្លួន) នៅចុងបញ្ចប់នៃកម្មវិធីសិក្សា ។

## 2. ឧបករណ៍ស្ទង់មតិវឌ្ឍនភាពស្តីការពេញចិត្តរបស់សិស្សលើមុខវិជ្ជាស្ទែម (ឧបសម្ព័ន្ធជ)

ការស្ទង់មតិវឌ្ឍនភាពស្តីការពេញចិត្តរបស់សិស្សលើមុខវិជ្ជាស្ទែមគឺមានទាំងភាសាខ្មែរ និងភាសាអង់គ្លេស។ សូមកត់សម្គាល់ថា ៖ ការស្ទង់មតិទិន្នន័យដើមគ្រា និងវឌ្ឍនភាពស្តីពីការពេញចិត្តរបស់សិស្សលើមុខវិជ្ជាស្ទែមមានតំណភ្ជាប់ដូចគ្នា។ ច្បាប់ចម្លងជាក្រដាសនៃការស្ទង់មតិនេះក៏មាននៅក្នុង (ឧបសម្ព័ន្ធ ជ) សម្រាប់អ្នកដែលមិនអាចស្វែងរកតំណស្ទង់មតិនេះតាមអនឡាញបាន។

### ទិដ្ឋភាពទូទៅ៖ ការស្ទង់មតិវឌ្ឍនភាពស្តីការពេញចិត្តរបស់សិស្សលើមុខវិជ្ជាស្ទែម

ការស្ទង់មតិដែលប្រើដោយសិស្ស ដើម្បីផ្តល់ឱកាសដល់ពួកគេអាចបង្ហាញនូវទស្សនៈអំពីបទពិសោធន៍នៃការអប់រំស្ទែមនៅសាលារៀនបន្ទាប់ទទួលបានការសិក្សានៅក្នុងឆ្នាំសិក្សារួចមក។ ការស្ទង់មតិនឹងផ្តល់ឱ្យគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន និងវិទ្យាស្ថានជាតិអប់រំអាចឈ្វេងយល់នូវទស្សនៈផ្សេងគ្នារបស់សិស្សដែលទាក់ទងនឹងគុណភាព និងការអនុវត្តនៃការបង្រៀន ការរៀន និងការវាយតម្លៃស្ទែមនៅសាលារៀន។ លទ្ធផលនៃការស្ទង់មតិការពេញចិត្តរបស់សិស្សនឹងត្រូវយកទៅប្រៀបធៀបគ្នានឹងទិន្នន័យដើមគ្រាដែលសិស្សបានបំពេញកាលពីដើមឆ្នាំសិក្សា។ លទ្ធផលនេះដើរតួនាទីជាព័ត៌មានសម្រាប់គ្រប់ភាគីទាំងអស់ក្នុងការកំណត់ថាមានអ្វីដែលកំពុងដំណើរការល្អ និងអ្វីដែលត្រូវកែលម្អបន្ថែម។

### វត្ថុបំណង

ដើម្បីពិនិត្យតាមដាន និងវាយតម្លៃមតិទស្សនៈរបស់សិស្សអំពីបទពិសោធន៍សិក្សាមុខវិជ្ជាស្ទែមបន្ទាប់ពីទទួលបានការអប់រំពេញមួយឆ្នាំនៃការទទួលបានការអប់រំស្ទែមនៅសាលារៀន។

## ដំណើរការ

## គំនូសតាងលំហូរប្រើប្រាស់ឧបករណ៍

គ.គ.ស ធ្វើការពិនិត្យតាមដានបន្តនៃវឌ្ឍនភាពនៅឯកិច្ចប្រជុំ គ.គ.ស

| | | | | | | |
|---|---|---|---|---|---|---|
| គ.គ.ស ចែកចាយតំណភ្ជាប់សម្រាប់ការស្ទង់មតិសិស្សទៅគ្រូបង្រៀនស្ទែម | សិស្សស្ទែមធ្វើការស្ទង់មតិវឌ្ឍនភាព<br>គ្រូស្ទែមពិនិ-ត្យតាមដាន | វ.ជ.អ ចេញឱ្យនាយកសាលាជាមួយនឹងលទ្ធផលនៃការស្ទង់មតិ<br>គ.គ.ស និងក្បាលទទួលបានលទ្ធផល | គ.គ.ស / គ្រូវិភាគលទ្ធផលនៃការស្ទង់មតិក្នុងមួយមុខវិជ្ជា | គ្រូ ស្ទែម ធ្វើបច្ចុប្បន្នភាពផែនការសកម្មភាព ការអភិវឌ្ឍវិជ្ជាជីវៈផ្ទាល់ខ្លួនរបស់ពួកគេ។ | គ.គ.ស ជូនដំណឹងដល់ វ.ជ.អ អំពីតម្រូវការការអភិវឌ្ឍវិជ្ជាជីវៈ ណាមួយ ផែនការ និងការបណ្ដុះបណ្ដាល<br>គ.គ.ស ធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពកម្រិតសាលារៀន | គ.គ.ស/វ.ជ.អ ពិនិត្យមើលវឌ្ឍនភាពនៃផែនការសកម្មភាពរបស់សាលា |
| | ក្នុងរយៈពេល 4 សប្ដាហ៍នៃចុងបញ្ចប់នៃឆមាសទី 2<br>+<br>រៀងរាល់ 6 ខែ | ក្នុងរយៈពេល 3 សប្ដាហ៍នៃចុងបញ្ចប់នៃឆមាសទី 2 | ក្នុងរយៈពេល 3 សប្ដាហ៍នៃចុងបញ្ចប់នៃឆមាសទី 2 | ក្នុងរយៈពេល 3 សប្ដាហ៍នៃចុងបញ្ចប់នៃឆមាសទី 2 | ក្នុងរយៈពេល 2 សប្ដាហ៍នៃការបញ្ចប់ឆមាសទី 2<br>ការអភិវឌ្ឍវិជ្ជាជីវៈគ្រោងសម្រាប់ឆមាសទី 1 នៅឆ្នាំក្រោយ | ចុងឆមាសទី2 |

គ្រូប្រើប្រអប់ឧបករណ៍ដើម្បីកែលម្អ

## ដំណើរការ

- សិស្សត្រូវចូលរួមបំពេញការស្ទង់មតិស្ដីពីការវឌ្ឍភាពការពេញចិត្តរបស់សិស្សលើមុខវិជ្ជាស្ទែមនៅចុងឆមាសទី2នៃឆ្នាំសិក្សា។ គ្រូបង្រៀនត្រូវទុកពេលចន្លោះរយៈពេល2សប្ដាហ៍ ដើម្បីបំពេញការស្ទង់មតិនេះ។
- គ.គ.ស នឹងចែកចាយតំណភ្ជាប់ដើម្បីឱ្យគ្រូបង្រៀនមុខវិជ្ជាស្ទែមទាំងអស់ចែកចាយទៅកាន់សិស្សទៅតាមថ្នាក់រៀននីមួយៗ។
- គ្រូបង្រៀនស្ទែមនឹងពិនិត្យតាមដាន និងជួយធានាថាសិស្សរបស់ខ្លួនទាំងអស់ទទួលបានតំណភ្ជាប់ និងតាមដានថាសិស្សទាំងអស់បានបំពេញការស្ទង់មតិនេះ។

- វ.ជ.អ នឹងផ្តល់ការវិភាគទិន្នន័យប្រៀបធៀប (ភាពខុសគ្នារវាងទិន្នន័យដើមគ្រា និងវឌ្ឍនភាព សម្រាប់សាលារៀននីមួយៗ និងចែកចាយលទ្ធផលទៅគណៈគ្រប់គ្រងសាលារៀន។ លទ្ធផលនៃការប្រៀបធៀបនេះនឹងជួយមើលថាតើមានវឌ្ឍនភាពវិជ្ជមានដែរឬទេ? ឬក៏ត្រូវការការកែលម្អបន្ថែម។
- គ.គ.ស នឹងចែករំលែកលទ្ធផលជាមួយនាយកសាលា និងរាយការណ៍នូវបច្ចុប្បន្នភាពនៃវឌ្ឍនភាពការងារនៅសាលារៀនខ្លួនដោយផ្ទៀងផ្ទាត់នឹងផែនការសកម្មភាពកម្រិតសាលារៀន។
- ដំណើរការនេះអាចត្រូវបានធ្វើម្តងទៀតរៀងរាល់ឆ្នាំ ដើម្បីជួយធានាថា គ.គ.ស និងគ្រូបង្គោល វ.ជ.អ មានទំនុកចិត្តថាសាលារៀនពិតជាកំពុងគាំទ្រការកែលម្អដែរឬទេ។
- សិស្សថ្មីទើបចូលរៀនថ្នាក់រៀនមុខវិជ្ជាស្ទែម នឹងធ្វើការស្ទង់មតិការពេញចិត្តចំពោះវឌ្ឍនភាពភ្លាមៗ នៅពេលដែលពួកគេឈានដល់កាលបរិច្ឆេទជាក់លាក់ចាប់ពីពេលដែលពួកគេចាប់ផ្តើមវគ្គសិក្សា។

### អ្នកចូលរួម

- គ្រូបង្គោលវ.ជ.អចេញលទ្ធផលស្ទង់មតិប្រៀបធៀប ជួយរៀបចំផែនការ និងផ្តល់ការបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈ និងសម្ភាសន៍ គ.គ.ស កំឡុងពេលពិនិត្យចុងឆ្នាំ។
- គ.គ.សស្ទែម(ក្រុមស្ទែមស្នូល) - ពិនិត្យតាមដានការស្ទង់មតិវឌ្ឍនភាពជាមួយគ្រូ ស្ទែម វិភាគទិន្នន័យប្រៀបធៀប ធ្វើបច្ចុប្បន្នភាព ផែនការ សកម្មភាពសាលា និងរៀបចំផែនការបណ្តុះបណ្តាល ការអភិវឌ្ឍវិជ្ជាជីវៈ ផ្ទាល់ខ្លួន។
- គ្រូបង្រៀនស្ទែមពិនិត្យមើលលទ្ធផលស្ទង់មតិនេះទៅតាមចំណុចនីមួយៗ និង ធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពកម្រិតបុគ្គលរបស់ពួកគេ និងចូលរួមក្នុងសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ។

### ពេលវេលា

- ការស្ទង់មតិការពេញចិត្តរបស់សិស្សស្ទែម - 4 សប្តាហ៍នៃបញ្ចប់នៃឆមាសទីពីរ។
- វ.ជ.អ ចេញលទ្ធផលប្រៀបធៀបដល់នាយកសាលា - 1 សប្តាហ៍បន្ទាប់ពីការស្ទង់មតិវឌ្ឍនភាព ។
- ប្រធាន ស្ទែម និងគ្រូពិនិត្យលទ្ធផលសម្រាប់មុខវិជ្ជានីមួយៗ។

## របាយការណ៍ពិនិត្យតាមដាននិងវាយតម្លៃស្ទែមសម្រាប់ផ្តល់មតិកែលម្អដល់សាលារៀន

របាយការណ៍នេះ (ឧបសម្ព័ន្ធ ឈ) ត្រូវបំពេញដោយគ្រូបង្គោលនៃវិទ្យាស្ថានជាតិអប់រំ ក្នុងការពិគ្រោះយោបល់ជាមួយសាលារៀន។ គណៈគ្រប់គ្រងស្ទែមបន្ទាប់ពីធ្វើកិច្ចពិភាក្សាជាមួយនឹងគ្រូបង្គោល និងត្រូវផ្តល់ព័ត៌មានសម្រាប់វិភាគអំពីវឌ្ឍនភាពដែលភ្ជាប់ទៅនឹងឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សា (ឧបសម្ព័ន្ធ ក) និងផែនការសកម្មភាពកម្រិតសាលារៀន (ឧបសម្ព័ន្ធ ង) សម្រាប់ជាមូលដ្ឋានកែលម្អបន្ថែមទៀត ហើយនឹងត្រូវបានពិនិត្យឡើងវិញនៅចុងឆ្នាំ ការពិនិត្យតាមដានរបស់គ.គ.ស និងគ្រូបង្គោល វ.ជ.អ។

# ឯកសារយោង

O'Leary, M., Cui, V., Kiem, M. T., et. al (2023) The role of classroom observation in the development and assessment of schoolteachers in Vietnam: a review of national policy and research. Available at: https://www.openaccess.bcu.ac.uk/14297/1/The%20role%20of%20classroom%20observation%20in%20the%20development%20and%20assessment%20of%20schoolteachers%20in%20Vietnam%20a%20review%20of%20national%20policy%20and%20research.pdf [accessed 30th April 2023]

O'Leary, M. (2013) Developing a National Framework for the Effective Use of Lesson Observation in Further Education. Available at: https://www.ucu.org.uk/media/6714/Developing-a-national-framework-for-the-effective-use-of-lesson-observation-in-FE-Dr-Matt-OLeary-Nov-13/pdf/ucu_lessonobsproject_nov13.pdf. [accessed 30th April 2023)

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ ក៖ ឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាគណៈគ្រប់គ្រងស្ទែម

ឈ្មោះសាលារៀន៖____________________________សមាជិកគណៈគ្រប់គ្រងស្ទែម៖____________

ឈ្មោះគ្រូបង្គោល(វ.ជ.អ)៖______________________កាលបរិច្ឆេទ៖_______________________

| ឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាគណៈគ្រប់គ្រងស្ទែម | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ចំណុច | ប្រធានបទ | ប្រធានបទរង | ទិន្នន័យ | | | | | | | |
| 1 | **វត្តមានសិស្ស និងការត្រួតថ្នាក់** *រាយការណ៍ពីស្ថិតិសិស្សស្រីប្រុស* | កម្រិតថ្នាក់ និងមុខវិជ្ជា | ចំ.ចូលរៀន | | (%)វត្តមាន | | ចំ.ត្រួតថ្នាក់ | | (%)ត្រួតថ្នាក់ | |
| | | | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស |
| | | ថ្នាក់ទី10 | | | | | | | | |
| | | គ្រប់មុខវិជ្ជាស្ទែមទាំងអស់ | | | | | | | | |
| | | ថ្នាក់ទី11 | | | | | | | | |
| | | រូបវិទ្យា | | | | | | | | |
| | | ជីវវិទ្យា | | | | | | | | |
| | | គណិតវិទ្យា | | | | | | | | |
| | | វិទ្យាសាស្ត្រផែនដី | | | | | | | | |
| | | គីមីវិទ្យា | | | | | | | | |
| | | IT | | | | | | | | |
| | | ថ្នាក់ទី12 | | | | | | | | |
| | | រូបវិទ្យា | | | | | | | | |
| | | ជីវវិទ្យា | | | | | | | | |
| | | គណិតវិទ្យា | | | | | | | | |
| | | វិទ្យាសាស្ត្រផែនដី | | | | | | | | |
| | | គីមីវិទ្យា | | | | | | | | |
| | | IT | | | | | | | | |
| 2 | លទ្ធផលសិក្សា | វាយតម្លៃដំណាក់/វាយតម្លៃចុងក្រោយ | | | | | | | | |
| 3 | ការជ្រើសរើសគ្រូបង្រៀនស្ទែម | តើមានឧបសគ្គដែរឬទេ? បើមាន តើជាឧបសគ្គអ្វីខ្លះ? | | | | | | | | |
| 4 | ការគ្រប់គ្រងបន្ទប់ពិសោធន៍ | សុខភាពនិងសុវត្ថិភាព *តើមានការវាយតម្លៃលើហានីភ័យដែរឬទេ?* *តើមានការហ្វឹកហាត់បង្ការសុវត្ថិភាព និងការប៉ះពាល់សុខភាពដែរឬទេ?* | | | | | | | | |
| | | ការរៀបចំសម្ភារៈក្នុងបន្ទប់ពិសោធន៍ស្ទែម | | | | | | | | |

<table>
<tr><td></td><td></td><td>ការប្រើប្រាស់បន្ទប់ពិសោធន៍ស្ទែម</td><td></td></tr>
<tr><td rowspan="3">5</td><td rowspan="3">ផែនការបង្រៀន</td><td>ផែនការបង្រៀន<br>• តើមានរួមបញ្ចូលខ្លឹមសារមេរៀនមុខវិជ្ជាដទៃដែរឬទេ ?<br>• តើខ្លឹមសារបង្រៀនមានផ្សារភ្ជាប់ទៅពិភពពិតដែរឬទេ ?</td><td></td></tr>
<tr><td>កិច្ចតែងការបង្រៀន<br>• តើមានបញ្ចូលសកម្មភាពផ្សេងៗគ្នាដែរឬទេ ?<br>• តើមានរួមបញ្ចូលវិធីសាស្ត្រការរៀនបែបសកម្មដែរឬទេ ? (active learning)</td><td></td></tr>
<tr><td>មតិស្ថាបនាទៅសិស្ស<br>• ញឹកញាប់កម្រិតណា ?<br>• តើការផ្ដល់មតិកែលម្អត្រូវបានអនុវត្តដូចម្ដេច ?<br>• តើបានតាមដានទេ ?</td><td></td></tr>
<tr><td>6</td><td>លទ្ធផលនៃការសង្កេត</td><td colspan="2">តើមានការធ្វើការសង្កេតពីគណៈគ្រប់គ្រងស្ទែមឫទេ ? តើមានការធ្វើការសង្កេតពីក្រុមគ្រូបង្រៀនដទៃឫទេ ?តើគ្រូបង្រៀនមានធ្វើការស្វ័យឆ្លុះបញ្ចាំងឫទេ ? តើមានអ្វីខ្លះកើតឡើងបន្ទាប់ពីការផ្ដល់មតិស្ថាបនារួច ?</td></tr>
<tr><td>7</td><td>លទ្ធផលនៃការស្ទង់មតិការពេញចិត្តរបស់សិស្ស</td><td colspan="2">តើលទ្ធផលនៃការស្ទង់មតិក្នុងមុខវិជ្ជាស្ទែមនីមួយៗមានអ្វីខ្លះ ? តើមានសកម្មភាពអ្វីខ្លះត្រូវបានគេគ្រោងទុក ឬបានកើតឡើង ?</td></tr>
<tr><td>8</td><td>តម្រូវការអភិវឌ្ឍវិជ្ជាជីវៈ</td><td colspan="2">តើមានអ្វីកើតឡើងនិងត្រូវបានគ្រោងទុក ? តើភាពប្រសើរឡើងនៃទំនុកចិត្តដែឫទេ ?</td></tr>
</table>

# ឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាគណៈគ្រប់គ្រងស្ទែម

ឈ្មោះសាលារៀន៖_______________________________ សមាជិកគណៈគ្រប់គ្រងស្ទែម៖______________

ឈ្មោះគ្រូបង្គោល(វ.ជ.អ)៖_________________________ កាលបរិច្ឆេទ៖_________________________

| ឧបករណ៍ត្រួតពិនិត្យកិច្ចពិភាក្សាគណៈគ្រប់គ្រងស្ទែម | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ចំណុច | ប្រធានបទ | ប្រធានបទរង | ទិន្នន័យ | | | | | | | |
| 1 | វត្តមានសិស្ស និងការត្រួតថ្នាក់ | កម្រិតថ្នាក់ និងមុខវិជ្ជា | ចំ.ចូលរៀន | | (%)វត្តមាន | | ចំ.ត្រួតថ្នាក់ | | (%)ត្រួតថ្នាក់ | |
| | | | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស |
| | | ថ្នាក់ទី10 | | | | | | | | |
| | *របាយការណ៍ពីស្ថិតិសិស្សស្រីប្រុស* | គ្រប់មុខវិជ្ជាស្ទែមទាំងអស់ | *186* | *250* | *95%* | *95%* | *185* | *245* | *99%* | *98%* |
| | | ថ្នាក់ទី11 | | | | | | | | |
| | | រូបវិទ្យា | | | *95%* | *93%* | | | | |
| | | ជីវវិទ្យា | *75* | *125* | *85%* | *80%* | *72* | *122* | *96%* | *98%* |
| | | គណិតវិទ្យា | | | | | | | | |
| | | វិទ្យាសាស្ត្រផែនដី | | | | | | | | |
| | | គីមីវិទ្យា | | | | | | | | |
| | | IT | | | | | | | | |
| | | ថ្នាក់ទី12 | | | | | | | | |
| | | រូបវិទ្យា | | | | | | | | |
| | | ជីវវិទ្យា | | | *87%* | *90%* | | | | |
| | | គណិតវិទ្យា | | | | | | | | |
| | | វិទ្យាសាស្ត្រផែនដី | | | 92% | 91% | | | | |
| | | គីមីវិទ្យា | *65* | *100* | 94% | 94% | *60* | *95* | *92%* | *95%* |
| | | IT | | | | | | | | |
| 2 | លទ្ធផលសិក្សា | ង្វាយតម្លៃជាដំណាក់/ង្វាយតម្លៃចុងក្រោយ | *ពិភាក្សាអំពីលទ្ធផលតេស្តណាមួយជាមួយគ្រូបង្រៀនស្ទែម ។ ពិនិត្យមើលសន្លឹកកិច្ចការតាមដានការវាយតម្លៃសម្រាប់ការកែលម្អណាមួយ។ សូមផ្តល់ចម្លើយជាលេខ។* | | | | | | | |
| 3 | ការជ្រើសរើសគ្រូបង្រៀនស្ទែម | តើមានឧបសគ្គដែរឬទេ ? បើមាន តើជាឧបសគ្គអ្វីខ្លះ ?<br>*ពិពណ៌នាអំពីស្ថានភាពនៅក្នុងសាលារបស់អ្នក។ កំណត់មូលហេតុដែលអាចកើតមាន។* | | | | | | | | |
| 4 | ការគ្រប់គ្រងបន្ទប់ពិសោធន៍ | សុខភាពនិងសុវត្ថិភាព<br>*តើមានការវាយតម្លៃលើហានីភ័យដែរឬទេ ?*<br>*តើមានការហ្វឹកហាត់បង្ការសុវត្ថិភាព និងការប៉ះពាល់សុខភាពដែរឬទេ ?* | *កំណត់និងពិភាក្សាស្តីពីបន្ទប់ពិសោធន៍ ឬ បុគ្គលអ្នកបច្ចេកទេសក្នុងបន្ទប់ពិសោធ។ ផ្តល់ការវាយតម្លៃហានីភ័យជាទិន្នន័យគុណវិស័យចំពោះការអនុវត្តសុខភាព និងសុវត្ថិភាព និងការបណ្តុះបណ្តាលជាដើម។* | | | | | | | |

*ការវិភាគលេខ ដែលបែងចែក នឹងបង្ហាញផ្នែកណាមួយនៃវានុវត្តល្អៗ និងចំណុចបញ្ហា។*

*រូបមន្តភាគរយសិស្សត្រួតថ្នាក់ = #សិស្សត្រួតថ្នាក់ ចែកនឹង #.ចុះឈ្មោះសរុប x 100 ។ សូមមើលឧទាហរណ៍ខាងក្រោម៖*

*រូបមន្តភាគរយវត្តមានសិស្ស=#ថ្ងៃវត្តមានសិស្សចែកចំនួនថ្ងៃនៃរយៈពេលសិក្សាសរុប x 100 ។*

*ទិន្នន័យសរុបសម្រាប់ # បានចុះឈ្មោះ # ត្រួតថ្នាក់ និង %ត្រួតថ្នាក់។ បែងចែកតាមមុខវិជ្ជាសម្រាប់ %នៃវត្តមាន*

| | | | |
|---|---|---|---|
| | | ការរៀបចំសម្ភារៈក្នុងបន្ទប់ពិសោធន៍ស្ទែម | *ពិនិត្យបន្ទប់ពិសោធន៍នីមួយៗ និងពន្យល់ពីស្ថានភាពបច្ចុប្បន្ន។ តើឧបករណ៍ត្រូវបានរក្សាទុកដោយសុវត្ថិភាព មានស្លាកសញ្ញា ខូច។ល។* |
| | | ការប្រើប្រាស់បន្ទប់ពិសោធន៍ស្ទែម | *សូមប្រើប្រាស់លទ្ធផលចេញពីឧបករណ៍ការសង្កេតរហ័សលើការបង្រៀនស្ទែម។ ការការសង្កេតរហ័សការសង្កេតរហ័សលើការបង្រៀនស្ទែមអាចជួយបង្ហាញពីចម្លើយបាន។ តើគុណភាពនៃការពិសោធន៍មានលក្ខណៈដូចម្ដេចនៅពេលនេះ ?* |
| 5 | ផែនការបង្រៀន | ផែនការបង្រៀន<br>• *តើមានរួមបញ្ចូលខ្លឹមសារមេរៀនមុខវិជ្ជាដទៃដែរឬទេ ?*<br>• *តើខ្លឹមសារបង្រៀនមានផ្សារភ្ជាប់ទៅពិភពពិតដែរឬទេ ?* | *សូមធ្វើការវិនិច្ឆ័យ។ តើអ្នកប្រើផែនការបង្រៀនទេ ? តើគ្រូបង្រៀនពិចារណាអំពីស្តង់ដារស្ទែម និងការរំពឹងទុកបានល្អកម្រិតណា ? តើគ្រូបង្រៀនមានគម្រោងសម្រាប់ការពិសោធន៍ផ្សេងៗដែលរួមបញ្ចូលមុខវិជ្ជាផ្សេងៗដែរឬទេ ?* |
| | | **កិច្ចតែងការបង្រៀន**<br>• *តើមានបញ្ចូលសកម្មភាពផ្សេងៗគ្នាដែរឬទេ ?*<br>• *តើមានរួមបញ្ចូលវិធីសាស្ត្រការរៀនបែបសកម្មដែរឬទេ ? (active learning)* | *សូមវិនិច្ឆ័យបន្ទាប់ពីពិនិត្យមើលឧទាហរណ៍ពីមុខវិជ្ជានីមួយៗ។ តើគ្រូបង្រៀនបានពិចារណាអំពីស្តង់ដារស្ទែម និងការរំពឹងទុកក្នុងកិច្ចតែងការបង្រៀនបានល្អកម្រិតណា ? តើក្នុងកិច្ចតែងការបង្រៀនមានសកម្មភាពផ្សេងៗគ្នា និងការវាយតម្លៃដែរឬទេ ?* |
| | | មតិស្ថាបនាទៅសិស្ស<br>• *ញឹកញាប់កម្រិតណា ?*<br>• *តើការផ្តល់មតិកែលម្អត្រូវបានអនុវត្តដូចម្តេច ?*<br>• *តើបានតាមដានទេ ?* | *តើគ្រូបង្រៀនស្ទែមផ្តល់យោបល់ស្ថាបនាទៅសិស្សបែបយ៉ាងណា ? ពេលណា ? តើមតិកែលម្អនោះមានប្រសិទ្ធភាពទេ ? តើសិស្សដឹងពីអ្វី និងរបៀបកែលម្អដែរឬទេ ?* |
| 6 | លទ្ធផលនៃការសង្កេត | តើមានការធ្វើការសង្កេតពីគណៈគ្រប់គ្រងស្ទែមទេ ? តើមានការធ្វើការសង្កេតពីក្រុមគ្រូបង្រៀនដទៃទេ ?តើគ្រូបង្រៀនមានធ្វើការស្វ័យឆ្លុះបញ្ចាំងទេ ? តើមានអ្វីខ្លះកើតឡើងបន្ទាប់ពីការផ្តល់មតិស្ថាបនារួច ?<br>*ពិពណ៌នាអំពីអ្វីដែលកើតឡើងនៅក្នុងសាលារបស់អ្នកនៅពេលបច្ចុប្បន្ន។ ចំនួនសកម្មភាពដែលបានកែលម្អ។ យោងទៅលើគុណភាពនៃវិធីសាស្ត្របង្រៀន។ ការគ្រប់គ្រងថ្នាក់រៀន* | |
| 7 | លទ្ធផលនៃការស្ទង់មតិការពេញចិត្តរបស់សិស្ស | តើលទ្ធផលនៃការស្ទង់មតិក្នុងមុខវិជ្ជាស្ទែមនីមួយៗមានអ្វីខ្លះ ? តើមានសកម្មភាពអ្វីខ្លះត្រូវបានគេគ្រោងទុក ឬបានកើតឡើង ?<br>*តើលទ្ធផលនៃការស្ទង់មតិក្នុងមុខវិជ្ជាស្ទែមនីមួយៗមានអ្វីខ្លះ ? តើការរកឃើញសំខាន់ៗមានអ្វីខ្លះ ? តើមានអ្វីដែលត្រូវដោះស្រាយទេ ?- សូមផ្តល់ចម្លើយដោយជាក់លាក់។ តើមានសកម្មភាពអ្វីខ្លះត្រូវបាន គ្រោងទុក ឬបានកើតឡើង ?* | |
| 8 | តម្រូវការអភិវឌ្ឍវិជ្ជាជីវៈ | តើមានអ្វីកើតឡើងនិងត្រូវបានគ្រោងទុក ? តើភាពប្រសើរឡើងនៃទំនុកចិត្ត ?<br>*ពិពណ៌នាអំពីអ្វីដែលកើតឡើងនៅក្នុងសាលារបស់អ្នកនៅពេលបច្ចុប្បន្ន។ តើអ្វីត្រូវបានផ្តល់ជូន ? តើការចូលរួមមានលក្ខណៈយ៉ាងណា ? តើអ្វីទៅជាគុណភាពនៃការអភិវឌ្ឍវិជ្ជាជីវៈ ?* | |

